00800299

E1/57.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Apr-2012, 15:30
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសជ

**ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១២**

**ម៉ោង ០៩:៣១ នាទី**

**សវនាការលើកទី៤៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក ប៉ាក ច័ន្ទលីណូ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*
លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក ហុង គឹមសួន

កញ្ញា លី ម៉ាញៀន *(Ms.Lyma NGUYEN)*

លោកស្រី ជេត វណ្ណលី

លោក វ៉ែន ពៅ

លោក បាណាបេ ណេគ្វី
*(Mr. Barnabé NEKUIE)*

លោកស្រី ម៉ារី ហ្គីរ៉ូដ
*(Ms. Marie GUIRAUD)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាន ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ហុង គីមសួន | ខ្មែរ |
| កញ្ញា លី ម៉ាញឿន | អង់គ្លេស |
| លោក កាំង ហ្កេកអ៊ាវ | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅសាក្សី៖ លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច

សួរបន្តដោយលោក វីល្លៀម ស្មីត ផ្តើមពី....................ទំព័រ ០១
សួរដោយលោក ហុង គឹមសួន ផ្តើមពី....................ទំព័រ ២១
សួរដោយកញ្ញា លី ម៉ាញៀន ផ្តើមពី....................ទំព័រ ៤២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:៣១:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។ តាមកាលវិភាគដែលបានគ្រោងទុក គឺអង្គជំនុំជម្រះនឹងបន្តស្តាប់នូវសក្ខីកម្មរបស់សាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលនឹងបន្តការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញារយៈពេលមួយម៉ោង ហើយនិងពេលវេលាសល់ប៉ុន្មានសម្រាប់ថ្ងៃនេះគឺជា-- អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[០៩:៣២:២៩]

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានលទ្ធភាពក្នុងការបន្តបញ្ចប់នូវការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ ប្រសិនបើមាន។ សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម សូមគោរពអស់លោក លោកស្រីភាគី និងសាធារណជន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ កាលពីសប្តាហ៍មុន យើងបានលើកឡើងនូវប្រធានបទបញ្ហាមួយចំនួន ក្នុងពេលលោកផ្តល់ចម្លើយ លោកបានលើកឡើងអំពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាចូលរួមនៅក្នុងមីទ្ទិង ឬក៏កិច្ចប្រជុំនានា។ តើមីទ្ទិងចំនួនប៉ុន្មាន? កិច្ចប្រជុំបក្សកុម្មុយនីស្តចំនួនប៉ុន្មានដែលលោកខ្លួនឯងបានចូលរួមនៅចន្លោះ៧៥ ដល់៧៩?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន មីទ្ទិងមានពីរប្រភេទ។ មីទ្ទិង ១៧ មេសា ហើយនិងមីទ្ទិង៣០ កញ្ញា។ ខ្ញុំចាប់ផ្តើមចូលរួមមីទ្ទិង១៧ មេសា ពីឆ្នាំ១៩៧៦។ ដោយឡែក មីទ្ទិង៣០

កញ្ញា ខ្ញុំចូលរួមពីឆ្នាំ១៩៧៧ អំ ៧៦ ដែរ។

[០៩:៣៤:២៤]

ឯចំណែកមីទ្ទិង ១៧ មេសា ចុងក្រោយ គឺមីទ្ទិង ១៧ មេសា ១៩៧៨ ធ្វើនៅពហុកីឡាដ្ឋានជាតិអូឡាំពិក មិនមែនធ្វើនៅបុរីកីឡាដូចមុនទេ។ មីទ្ទិង ១៧ មេសា លើកមុនៗធ្វើនៅបុរីកីឡា។ ដោយឡែកផងដែរ មីទ្ទិង១៧ មេសា ១៩៧៨ ធ្វើនៅពហុកីឡាដ្ឋានជាតិ ក៏ប៉ុន្តែមិនមែននៅព្រលានបាល់ទាត់ទេ គឺធ្វើនៅព្រលានបាល់បោះ។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

**សៈ** លោកនិយាយថា លោកបានចូលរួមមីទ្ទិងពីរ។ ទីមួយឆ្នាំ១៩៧៦ និងមួយទៀតនៅឆ្នាំ១៩៧៨ តើលោកមានធ្លាប់ចូលរួមនៅក្នុងមីទ្ទិងនៅក្នុងឆ្នាំ១៩៧៧ ទេ គឺមីទ្ទិង១៧ មេសា ៧៧?

**ឆៈ** ខ្ញុំចូលរួម!

**សៈ** លោកបានលើកឡើងផងដែរ លោកបានចូលរួមមីទ្ទិង ៣០ ខែកញ្ញា។ តើមីទ្ទិង ៣០ កញ្ញានោះ លោកបានចូលរួមប៉ុន្មានដងដែរ ហើយក្នុងរយៈពេលបីឆ្នាំកន្លះនេះ លោកបានចូលរួមមីទ្ទិងសរុបចំនួនប៉ុន្មានដង?

**ឆៈ** មីទ្ទិង ៣០ កញ្ញា មើលខ្ញុំចូលរួមតាំងពី៧៦, ៧៧, ៧៨។ មីទ្ទិង ១៧ មេសា ក៏ដូច្នោះ ៧៦, ៧៧, ៧៨។ ដោយឡែក ក្នុងរយៈពេលនេះមានមីទ្ទិងពិសេសមួយ គឺមីទ្ទិងថ្ងៃ ០៦ មករា ១៩៧៨ ដែលប៉ុល ពត ធ្វើឡើងដើម្បីផ្សព្វផ្សាយអំពីជ័យជម្នះរបស់កងទ័ពបដិវត្តន៍កម្ពុជាទៅលើកងទ័ពវៀតណាម។ កងទ័ពវៀតណាមឈ្មោះផ្លូវការដូចគេហៅថា កងទ័ពប្រជាជនវៀតណាម ខ្ញុំមិនច្បាស់ទេ។ ដូច្នេះពេលហ្នឹង ខ្ញុំចូលរួម។

**សៈ** នៅក្នុងមីទ្ទិងទាំងអស់នោះ តើលោកធ្លាប់ឃើញ ខៀវ សំផន, អៀង សារី, នួន ជា បានចូលរួមក្នុងមីទ្ទិងទាំងអស់នោះដែរឬទេ?

[០៩:៣៧:៣៥]

**ឆៈ** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន មីទ្ទិង ១៧ មេសា ១៩៧៦, មីទ្ទិង ១៧ មេសា ១៩៧៧ មានតែពីរនាក់ទេនៅលើវេទិកាអធិបតី គឺបង ប៉ុល ពត និងបង នួន ជា។ មីទ្ទិង ៣០ កញ្ញា ១៩៧៦ៗ មីទ្ទិង ៣០ កញ្ញា ១៩៧៧ តែសូមសង្កេតថា មីទ្ទិង៣០ កញ្ញា ១៩៧៧ នេះ ប៉ុល ពត ធ្វើតាំងពីថ្ងៃ២៧ ម្ល៉េះ។ ថ្ងៃ៣០ កញ្ញា គាត់ទៅដល់ស្រុកចិនបាត់ទៅហើយ។ នៅក្នុងមីទ្ទិង ២៧ កញ្ញា ១៩៧៧ នេះ មានតែពីរនាក់-- អំ! ៧៦ និង ៧៧ នេះ មានតែពីរនាក់ទេ គឺបង ប៉ុល ពត និងបង នួន ជា នៅលើ

វេទិកាអធិបតី។ ដោយឡែក មីទ្និងថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៨ ប៉ុល ពត អញ្ជើញទៅមានគ្នាច្រើន មានគ្នាប្អូននាក់អមទៅជាមួយ។ ទីមួយគឺមានបង នួន ជា អញ្ជើញទៅជាមួយ មានបង វន វេត អញ្ជើញទៅជាមួយដែរ ហើយមាន ជួន ជឿន ដុកទ័រ ជួន ជឿន អញ្ជើញទៅជាមួយដែរ។ ម្នាក់ទៀតខ្ញុំច្រឡំហើយច្រឡូកច្របល់មិនដឹងអ្នកណាទេ។ ឬមួយបង អៀង សារី ឬមួយបង ខៀវ សំផន ខ្ញុំអត់ច្បាស់ទេ។ ខ្ញុំច្រឡូកច្របល់ក្នុងអារម្មណ៍បាត់ទៅហើយ។ ដោយឡែក មីទ្និង ៣០ កញ្ញា ១៩៧៨ នៅលើវេទិកាអធិបតីមានដល់ទៅបីនាក់ គឺបងលេខា ប៉ុល ពត បងអនុលេខាទីមួយ នួន ជា និងបងអនុលេខាទីពីរ អ៊ុង ជឿន ហៅ ម៉ុក។ ពេលនុំងធ្វើនៅពហុកីឡាដ្ឋានជាតិអូឡាំពិក នៅព្រលានបាល់បោះ។ សូមបញ្ចប់។

**ស៖** សូមអរគុណ។ លោកបានលើកឡើងថា ផ្នែកការងាររបស់លោកគឺផ្តល់ការបណ្តុះបណ្តាល ហើយលោកត្រូវពិនិត្យមើលទង់បដិវត្ត និងយុទ្ធបដិវត្តផងដែរ។ ដូច្នេះ ខ្ញុំសូមមើលឯកសារមួយគឺ D243/2.1.12 បន្ទាប់មកខ្ញុំនឹងសួរសំណួរមួយចំនួន ចង់សូមលោកសួរ។

**លោក វីណ្ស៊ៀម ស្មីត៖**

លោកប្រធានខ្ញុំមានឯកសារនេះជាក្រដាស ដូច្នេះខ្ញុំអនុញ្ញាតផ្តល់ជូនសាក្សី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាជូនទៅសាក្សីពិនិត្យ។

[០៩:៤១:២០]

**លោក វីណ្ស៊ៀម ស្មីត៖**

E3/11 ឯកសារនេះមានលេខអ៊ីចឹងផងដែរ។

**សួរដោយលោក វីណ្ស៊ៀម ស្មីត៖**

**ស៖** លោកសាក្សីសូមលោកមើលឯកសារ ដែលក្នុងនោះបានលើកឡើងថា បទឧទ្ទេសនាមក្រោយថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលធ្វើការប្រកាសជាសាធារណៈស្តីអំពី "អត្ថិភាពនៃបក្ស" តើឯកសារមួយនេះ សុន្ទរកថាដែលលោកបានលើកឡើងខាងដើមកាលពីលើកមុន ដែលក្នុងនោះលើកឡើងពីការប្រកាសជាសាធារណៈអំពីបក្សកុម្មុយនីស្តកម្ពុជា កើតមានឡើង តើអ៊ីចឹងមែនដែរឬទេ? វាដូចហ្នឹងសុន្ទរកថាមុនដែលលោកលើកឡើងដែរឬទេ?

[០៩:៤២:២២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនចង់ជំទាស់ៗ ក៏ប៉ុន្តែខ្ញុំអត់មានអេក្រង់ នៅលើអេក្រង់របស់ខ្ញុំ អត់មានបញ្ចាំងឯកសារនេះទេ។ ដូច្នេះ សូមឲ្យបញ្ចាំងផង។

[០៩:៤២:៤៧]

**លោក វីណ្ស៊ៀម ស្មីត៖**

ជាការពិត លោកប្រធាន យើងខ្ញុំនឹងព្យាយាមធ្វើការបញ្ចាំងនៅតាមរយៈអេក្រង់ផងដែរ។

លោកប្រធាន ខណៈដែរខាងមន្ត្រីតុលាការកំពុងតែរៀបចំដាក់បញ្ចាំងនៅលើអេក្រង់ ដូច្នេះខ្ញុំ សូមបន្តទៅលើការសួរសំណួររបស់ខ្ញុំ។

**សួរដោយលោក វីណ្ស៊ៀម ស្មីត៖**

**ស៖** លោកសាក្សី តើនេះហើយជាទង់បដិវត្តដែលលោកបានលើកឡើង ដែលក្នុងនោះធ្វើការ ប្រកាសចេញជាចំហរអំពីបក្សកុម្មុយនីស្តកម្ពុជា តើមែនដែរឬទេ?

[០៩:៤៣:៥២]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** លោកប្រធាន បញ្ហាសំណួរសួរនេះគឺ មិនជាប់ស្ដែងប៉ុន្មានពេកទេ។ សេចក្ដីប្រកាសកាល នោះ មានពីរលើក មួយលើកជាសម្ងាត់នៅក្នុងចំណោមបក្ខជន កម្មាភិបាល នៅបុរីកីឡា។ ឯកសារនេះ អត់ផ្សាយនៅទង់បដិវត្តទេ ខ្ញុំកត់បានជាសង្ខេបខ្លឹមសារខ្លះ នៅក្នុងស-២១ គ្មានដែលឃើញបង្ហាញឲ្យខ្ញុំ ពន្យល់ទេ។ ខ្លឹមសារលើសពីនេះបន្តិច។ ឯកសារទង់បដិវត្តនេះ គឺជាឯកសារដែល បងប៉ុល គាត់សូត្រ នៅមន្ទីរមជ្ឈិមក្នុងចំណោមកងការពារ។ ខ្ញុំឃើញទង់បដិវត្តនេះ តែដល់ខ្ញុំដឹងអាសម្ងាត់ ខ្ញុំមិនសូវដែល បានយកចិត្តទុកដាក់អានអានេះទេ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** ឯកសារដែលលោកឃើញនៅចំពោះមុខនេះ តើវាជាឯកសារចម្លងចេញពីទង់បដិវត្តច្បាប់ ដើម ដែលលោកបានឃើញនៅក្នុងអំឡុងពេលលោកធ្វើការនៅស-២១ ដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនជឿសោះ ថាមានថតចម្លងពីណាក្រៅ ទង់បដិវត្តច្បាប់ដើមរបស់វា។

**ស៖** សូមអរគុណ។ ក្នុងនេះគឺខ្ញុំនិយាយអំពីឯកសារថតចម្លងនេះ តើឯកសារដែលមាននៅចំពោះមុខលោកនេះ គឺជាឯកសារថតចម្លងចេញពីច្បាប់ដើមនៃទង់បដិវត្តមែនដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាន៍លោកប្រធាន ខ្ញុំអត់ឃើញថាគេចម្លងទេ។ ក៏ប៉ុន្តែខ្ញុំជឿ ថាគេពិតជាចម្លងពីអាច្បាប់ដើមនុ៎ង។

**ស៖** សូមអរគុណ។ លោកសាក្សីនៅក្នុងសុន្ទរកថានៃទង់បដិវត្តនេះ ប្រសិនៗបើលោកមើលនៅក្នុងទំព័រ៣៦ 00063138 បារាំងគឺ 00492814។ តើលោកសាក្សីឃើញទេ ត្រង់ចំណុចដែលខ្ញុំគូសពណ៌លឿងនោះ គឺ00063138? នៅក្នុងឯកសារនេះ តើលោកបានឃើញចំណុចទីពីរ ដែលក្នុងនោះ ខ្ញុំគូសបានគូសពណ៌លឿងហើយ ត្រង់ឯកសារនៃភាសាខ្មែរទំព័រ៣៩ ចំណុច២ លោកឃើញពណ៌លឿងទេ?

[០៩:៤៧:៤៥]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំឃើញ។

**ស៖** ប្រសិនបើសូម លើកឡើងឲ្យលើកឡើងអានដោយសង្ខេប ឬខ្លីៗ “ខ២” បន្ទាប់មកគឺខ្ញុំនឹងសូមសួរលោកសំណួរមួយចំនួន។ អ៊ីចឹង សូមឲ្យលោកជួយអាន “ខ២” ចាប់ពី “ខ២” នេះទៅ។

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមអានដូចតទៅ តាមសំណូមពររបស់ព្រះរាជអាជ្ញា៖

“ខ២៖ មហាសន្និបាតបានវិភាគ និងសម្រេចអំពីទំនាស់នៅក្នុងសង្គមកម្ពុជា ខាងក្នុងសង្គមកម្ពុជាផ្ទាល់។ សង្គមកម្ពុជាយើង-- អ៎ ជំនាន់ដែលយើងរៀបចំមាគ៌ា គឺមានការបែងចែកវណ្ណៈច្បាស់។ វណ្ណៈកម្មករ វណ្ណៈកសិករ វណ្ណៈអនុធន វណ្ណៈនាយទុន វណ្ណៈសក្តិភូមិ។ មានប្រាំវណ្ណៈច្បាស់។ នៅក្នុងប្រាំវណ្ណៈនេះ គឺមានសមាភាពទំនាស់យ៉ាងម៉េច។ មានទំនាស់ស្មុគស្មាញ។ ទំនាស់កម្មករជាមួយមេទុន។ ទំនាស់អនុធនជាមួយនាយទុនក៏មាន។ ទំនាស់កសិករជាមួយម្ចាស់ដីក៏មាន។ ទំនាស់កសិករជាមួយនាយទុនក៏មាន។ល។ ទំនាស់វាស្មុគស្មាញចាក់ស្រែះ ក៏ប៉ុន្តែតាត-- សូមទោស ក៏ប៉ុន្តែទំនាស់ណាដែលវាដើរតួជាងគេ វាគ្របដណ្តប់ជាងគេ នៅក្នុងសង្គមកម្ពុជាជំនាន់នោះ ដើម្បីរកឲ្យឃើញ ត្រូវរកឲ្យឃើញថា ទំនាស់ជាមួយប្រជាជនច្រើនជាងគេ វណ្ណៈជិះជាន់ វណ្ណៈណាច្រើនជាងគេ។ ពិនិត្យមើលទៅក្នុងសង្គមកម្ពុជាពេលនោះ គឺកសិករមាន៨៥ភាគរយ ក្នុងប្រជាជនទូទាំងប្រទេស។

ដូច្នោះកសិករមានភាគច្រើនដាច់ខាត។ កសិករនេះត្រូវទទួលការជិះជាន់ពីនរណា? ជិះជាន់ពី

វណ្ណៈ ពីម្ចាស់ដីក៏ត្រូវជិះជាន់ នាយទុនក៏ត្រូវជិះជាន់ ប៉ុន្តែកសិករទទួលការជិះជាន់ពីម្ចាស់ដីខ្លាំងជាងគេ ស្អេកស្កះជាងគេ ផ្ទាល់ជាងគេ។ ដូច្នោះ ប្រជាជនចំនួន៨៥ភាគរយ គឺវណ្ណៈកសិករនេះឯង។ ទំនាស់ជាមួយវណ្ណៈជិះជាន់ ដែលជិះជាន់ខ្លួនផ្ទាល់ គឺវណ្ណៈសក្តិភូមិម្ចាស់ដី"។ សូមអរគុណ។

[០៩:៥១:២៤]

**ស៖** សូមអរគុណ។ ប្រសិនបើខ្ញុំឲ្យលោកឈប់អានត្រឹមចំណុចនេះ ហើយខ្ញុំសូមឲ្យលោកចូលទំព័រមួយទៀត គឺ00063140 ជាភាសាខ្មែរ។ អង់គ្លេសគឺ 004860-- ក្នុងអង់គ្លេសគឺ 00492816។ នៅក្នុងចំណុចនេះ គឺថាការទំនាស់គ្នានោះ គឺជំទាស់គ្នាស្លាប់រស់ ហើយឃើញមាននៅក្នុងសង្គមកម្ពុជា ដែលវាបះពាល់ទៅដល់ប្រជាជន៨៥ភាគរយ។ ដូច្នេះហើយ យើងឃើញថានៅក្នុងបក្ស គឺមានការខ្ទាស់គ្នានៅក្នុងនេះ។ លោក កាំង ហ្កេកអ៊ាវ សំណួររបស់ខ្ញុំនៅត្រង់ចំណុចនេះ សូមឲ្យលោកជួយពន្យល់អត្ថន័យនៅក្នុងឯកសារនេះ ដែលគេនិយាយថា ទំនាស់នោះ គឺទំនាស់ស្លាប់រស់។ តើវាមានន័យយ៉ាងម៉េចចំពោះទំនាស់ស្លាប់រស់?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន នៅក្នុងទស្សនវិជ្ជាសម្ភារនិយមបដិចសមុប្បាត ទំនាស់មានពីរ។ ទំនាស់មួយគេហៅថាទំនាស់ផ្ទៃក្នុង មិនស្លាប់រស់ទេ។ ទំនាស់ទីពីរ គឺទំនាស់រវាងយើងនិងខ្មាំងជាទំនាស់ស្លាប់រស់។ បានន័យថា បើមួយនៅរស់ត្រូវតែមួយទៀត ចង់ឲ្យមួយរស់ មួយរីកចម្រើនបាន ត្រូវតែអត់មានមួយទៀត។ នេះមានន័យអ៊ីចឹង ខ្ញុំសូមបញ្ចប់។

[០៩:៥៣:៣៤]

**ស៖** សូមអរគុណ។ ពាក្យថា "ទំនាស់ផ្ទៃក្នុង"នោះ តើវាមានលក្ខណៈខុសគ្នាយ៉ាងម៉េចទៅនឹងទំនាស់ស្លាប់រស់?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ទំនាស់ផ្ទៃក្នុងគឺ ជំទាស់រវាងភាគីពីរ។ ភាគីទាំងពីរនេះពឹងអាស្រ័យគ្នាទៅវិញទៅមក ដើម្បីឲ្យចលនាវារីកចម្រើនទៅមុខ។ ឧទាហរណ៍ទំនាស់រវាងកម្មាភិបាល និងយុទ្ធជន នេះជាទំនាស់ផ្ទៃក្នុង គេដោះស្រាយតាមការតស៊ូមតិ តាមការរៀនសូត្រ។ នេះទំនាស់ផ្ទៃក្នុង វាមានអ៊ីចឹង។ ខ្ញុំសូមបញ្ចប់។

[០៩:៥៤:៤៤]

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរទៅលើប្រធានបទមួយទៀត។ ប្រធានបទនេះគឺពាក់ព័ន្ធទៅនឹងតួនាទីរបស់ ខៀវ សំផន ដែលលោកបានលើកឡើងកាលពីសប្តាហ៍មុន ហើយនិងតួនាទីរបស់ ខៀន

ដែលបានពិភាក្សាកាលពីសប្តាហ៍មុនផងដែរ។ លោកបាននិយាយថា លោក ខៀវ សំផន គឺជាប្រធានមន្ទីរគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ហើយលោកក៏បានលើកឡើងផងដែរថា ឌឿន ក៏មានតួនាទីនោះដែរ មុនពេលដែលគាត់បញ្ជូនទៅក្រសួងពាណិជ្ជកម្ម។ លោកបានលើកឡើងថា ទោះបីជា ឌឿន ជាប្រធានមន្ទីរគណៈមជ្ឈិមក៏ដោយ គាត់ក៏ទទួលខុសត្រូវតែទៅលើការថែរក្សាឯកសារតែប៉ុណ្ណោះ គាត់មិនមានអំណាចជាក់ស្តែងពិតប្រាកដនោះទេ។ លោកបានលើកឡើងថា នៅពេលដែល ឌឿន ចាកចេញពីគណៈមន្ទីរមជ្ឈិម តួនាទីរបស់លោក ខៀវ សំផន មិនមានការប្រែប្រួល ផ្លាស់ប្តូរនៅក្នុងគណៈមន្ទីរមជ្ឈិមនោះទេ។ ដូច្នេះខ្ញុំសូមសួរថា តើនរណាគេមានតំណែងខ្ពស់ជាងគេបំផុតនៅក្នុងមន្ទីរគណៈមជ្ឈិម។ តើ ឌឿន ឬក៏ ខៀវ សំផន?

[០៩:៥៦:២០]

**ផ៖** អរគុណ។ ខ្ញុំជម្រាបប្រសាសន៍លោកប្រធាន ការពន្យល់នេះទាល់តែពឹងផ្អែកលើការយល់ដឹងបច្ចុប្បន្ន បើសិនជាឲ្យខ្ញុំនិយាយត្រឹមតែការយល់ដឹងជំនាន់នុ៎ង ចង្អៀតណាស់។ ដូច្នេះ ខ្ញុំសូមនិយាយត្រឹមការយល់ដឹងជំនាន់នុ៎ងសិន។ បញ្ញាជនទាំងអស់នៅក្នុងជួរ ដែលមានចិត្តស្រឡាញ់បក្ស ស្រឡាញ់ប្រជាជន ហើយនិងពេញចិត្តលោក ខៀវ សំផន ដឹងច្បាស់ថាលោក ខៀវ សំផន ទទួលភារកិច្ចជាប្រធានមន្ទីរមជ្ឈិមតាំងពីឆ្នាំ១៩៧១ ហើយជឿជាក់ថា ជាសិស្សម្នាក់របស់បង ប៉ុល ពត ដែលបង ប៉ុល ពត បណ្តុះបណ្តាល ហើយពេលនោះយើងខ្ញុំមើលពីក្រោមទៅឃើញថា តួនាទីនេះត្រឹមតែក្រដាសទេ។ បង ខៀវ សំផន កាន់កាប់តែក្រដាសទេ។ ដល់ក្រោយមក នៅពេលដែលមានការចាត់តាំង ឌឿន ឲ្យទៅធ្វើជាប្រធានមន្ទីរមជ្ឈិម យើងខ្ញុំដែលនៅខាងក្រោម ហើយដែលស្គាល់អត្តចរិតរបស់ ឌឿន ហើយស្គាល់ខ្សែអនុធនរបស់ កុយ ធួន ដឹងថា ចាត់តាំង ឌឿន ជាប្រធានមន្ទីរមជ្ឈិម ដើម្បីបំបែកកម្លាំងនេះ ដើម្បីកុំឲ្យប្រមូលផ្តុំគ្នា គឺកម្លាំង កុយ ធួន កុំឲ្យប្រមូលផ្តុំគ្នា។ កុយ ធួន នៅពាណិជ្ជកម្ម យក ឌឿន ទៅដាក់នៅមន្ទីរមជ្ឈិម។ តាមពិតប្រធានមន្ទីរមជ្ឈិមនេះ វាមានឈ្មោះអីចឹងមែន។ បើតាមការយល់ដឹងរបស់ខ្ញុំជំនាន់នុ៎ងដែរ ប្រធានមន្ទីរមជ្ឈិមរបស់ ឌឿន នេះ មានន័យថាលេខាធិដ្ឋានរបស់ ប៉ុល ពត។ មានន័យ ត្រឹមប៉ុននុ៎ង។ ឯចំណែកបង ខៀវ សំផន តាមដំណឹងទៅក្រៅ ខ្ញុំអត់ដឹងជាបងកាន់កាប់ស្អីទេ ក៏ប៉ុន្តែខ្ញុំដឹងថា ខ្ញុំឮៗក្រៅផ្លូវការទេ តែខ្ញុំដឹងថា បង ខៀវ សំផន កាន់កាប់ចែកចាយម៉ាស៊ីនស្អីៗទៅឲ្យមូលដ្ឋាន។ នេះមួយ។ ទីពីរទៀត មានភស្តុតាងខ្លះផង បង ខៀវ សំផន ជាអ្នកនាំសម្តេច សីហនុ និង ប៉ែន នុត ទៅទស្សនកិច្ចនៅជនបទ។ មានឃើញរូបថតថែមទៀត។ នេះខ្ញុំដឹងប៉ុននុ៎ងកាលណោះ។

[០៩:៥៩:១៣]

**ស៖** សូមអរគុណ។ នៅពេលដែល ខឿន ចេញទៅធ្វើការនៅក្រសួងពាណិជ្ជកម្មវិញ តើ ខៀវ សំផន នៅតែមានតំណែងតួនាទីដដែល ឬក៏យ៉ាងម៉េច?

**ឆ៖** អរគុណ។ នៅពេលដែល ខឿន ចេញទៅខាងពាណិជ្ជកម្ម ហើយក្រោយមកចាប់ ខឿន ខ្ញុំនៅតែជឿថាបង ខៀវ សំផន នៅតែមានតួនាទីដដែល។ ប៉ុន្មានថ្ងៃមុននេះ ខ្ញុំបានជម្រាបបញ្ជាក់ជូនអង្គជំនុំជម្រះយើងហើយ ថាគ្មាននរណាទៅធ្វើអីឲ្យរង្គើបង ខៀវ សំផន បានទេ។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

**ស៖** ខ្ញុំត្រឡប់ទៅសំណួរខាងដើមរបស់ខ្ញុំវិញ តើលោកដឹងថាអ្នកណាមានឋានៈខ្ពស់ជាងគេនៅបក្សកុម្មុយនីស្តកម្ពុជា? តើ ខឿន ឬក៏ ខៀវ សំផន?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បើតាមខ្ញុំចាំ ខ្ញុំបានអានកំណត់ហេតុសួរចម្លើយរបស់បង ខៀវ សំផន នៅការិយាល័យសហចៅក្រមស៊ើបអង្កេត វាស្របគ្នានឹងដំណឹងដែលខ្ញុំបានដឹងពីមុនមកដែរ។ បង ខៀវ សំផន ជាសមាជិកមជ្ឈិមពេញសិទ្ធិ។ ឯចំណែក ខឿន ខ្ញុំជឿថាថ្មីឬមួយយ៉ាងច្រើនណាស់ ត្រឹមសមាជិកមជ្ឈិមត្រៀមប៉ុណ្ណឹង។ បើទោះជាពេញសិទ្ធិក៏មិនមានឥទ្ធិពលដូចបង ខៀវ សំផន ព្រោះបង ខៀវ សំផន ក្តាប់នយោបាយបានច្បាស់ជាង ច្រើនជាង។

គាត់នៅធ្វើជាសិស្សរបស់ ប៉ុល ពត ផ្ទាល់តាំងពី៧១។ សរុបមកវិញ បង ខៀវ សំផន ក្នុងបក្សក៏នៅតែធំជាង ខឿន។ ខឿន ក្មេងស្រករខ្ញុំតើ!

[១០:០២:០១]

**ស៖** តើលោកដឹងទេ អ្នកណាជាអ្នកស្នងតំណែងរបស់ ខឿន នៅពេលដែល ខឿន គាត់បានចេញទៅខាងពាណិជ្ជនោះទៅនោះ?

**លោក អាកទួរ វែកគែន៖**

លោកប្រធាន។ បាទ ខ្ញុំសូមអន្តរាគមន៍ ពីព្រោះថា-- បាទ ចង់ជម្រាបជូនខាងសហព្រះរាជអាជ្ញាថា គួរតែរំឭកឲ្យសាក្សីហ្នឹងនិយាយឲ្យបានច្បាស់លាស់ ហើយ-- ព្រោះនៅពេលដែលថា សក្ខីកម្មគាត់ហ្នឹងទាក់ទងទៅនឹងអ្វីដែលគាត់ដឹងនៅសម័យនោះ ឬក៏ថា គាត់ផ្អែកលើមូលដ្ឋាននៃព័ត៌មានដែលគាត់បានដឹង តាមរយៈការអានសំណុំឯកសារនេះការស៊ើបអង្កេតនេះឬទេ? ខ្ញុំមិនចង់ឲ្យថា មិនចង់ឲ្យយើងចោទសំណួរគាត់ហើយ ធ្វើឲ្យគាត់មិនអាចបែងចែកនូវអ្វីដែលគាត់ដឹងពីសម័យនោះច្បាស់លាស់នោះ ហើយនិងអ្វីដែលគាត់បានសិក្សាដឹងនៅពេលក្រោយ នៅក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត។

[១០:០៣:៣៨]

**លោក វីណ្ឌៀម ស្មីត៖**

លោកប្រធាន ខ្ញុំនឹងធ្វើបែបនោះ សំណួរតទៅនេះ។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** នៅពេលដែលលោកនៅស-២១ ក្នុងសម័យនោះ នៅពេលដែល ឌឿន បានចេញទៅធ្វើខាងពាណិជ្ជកម្ម តើលោកដឹងទេនៅពេលនោះ អ្នកណាជាអ្នកមកស្នងតំណែងរបស់ ឌឿន ឬក៏តួនាទី ឬក៏ភារកិច្ចរបស់ ឌឿន នោះបាទ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំមិនច្បាស់ទេ។ បញ្ហានេះ ខ្ញុំអត់ច្បាស់ទេ។ ប៉ុន្តែអ្នកដែលរៀងដឹងរឿងដឹងរ៉ាវច្រើន ហើយនាំពាក្យ ប៉ុល ពត ទៅបញ្ជា ស-២១ គឺ ប៉ង់។ នេះខ្ញុំគ្រាន់តែ សូមជូនជាការរំឭកឡើងវិញអំពីរឿងការដែលខ្ញុំដឹងឮជំនាន់នុ៎ង។

[១០:០៥:០៤]

**ស៖** សូមអរគុណ។ សំណួរបន្ទាប់នេះគឺ នៅក្នុងសក្ខីកម្មរបស់លោកពីខាងមុននោះ នៅដំណាក់កាលមួយលោកនិយាយថា គណៈមជ្ឈិម គណៈអចិន្ត្រៃយ៍មជ្ឈិមគឺថា ដូចជាមន្ទីរ៨៧០ នោះដែរ តើវាមានភាពខុសគ្នាទេនៅពេលដែលលោកដឹងកាលនោះ? តើមានភាពខុសគ្នាទេរវាងមន្ទីរ៨៧០ ហើយនិងគណៈអចិន្ត្រៃយ៍មជ្ឈិម? តើជាកន្លែងតែមួយធ្វើការងារតែមួយជាមួយគ្នា ឬក៏ដូចម្ដេច តាមអ្វីដែលលោកដឹងកាលពីសម័យនោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន អចិន្ត្រៃយ៍មជ្ឈិម ខ្ញុំបានបញ្ជាក់ហើយថាមានគ្នាប្រាំពីរនាក់ គឺទី១) បង ប៉ុល, ទី២ បង នួន, ទី៣ បងសោ ភឹម, ទី៤ បង អ៊ុង ជឿន ហៅ ម៉ុក ទី៥ បង អៀង សារី, ទី៦ បង វន វ៉េត ហើយនិងទី៧ បង សុន សេន។ ក្នុងប្រាំពីរនាក់នេះមានពីរនាក់នៅក្រៅ គឺបង សោ ភឹម លេខាភូមិភាគបូព៌ា គាត់នៅខាងក្រៅ កាន់កាប់ភូមិភាគបូព៌ាមួយទាំងមូល ហើយនិងបង អ៊ុង ជឿន ហៅ ម៉ុក នៅខាងក្រៅដែរ កាន់កាប់ភូមិភាគនិរតីមួយទាំងមូល។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

[១០:០៦:៥៥]

**ស៖** សូមអរគុណ។ នៅក្នុងសក្ខីកម្មរបស់លោកៗបានបញ្ជាក់ថា គណៈអចិន្ត្រៃយ៍ដែលលោក

បានបញ្ជាក់អំមិញនេះ ហើយលោកក៏បានបញ្ជាក់ដែរថា មានមន្ទីរអចិន្ត្រៃយ៍មជ្ឈិម ឥឡូវនេះខ្ញុំនិយាយពីអចិន្ត្រៃយ៍មជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា។ សំណួរខ្ញុំចំពោះលោកគឺថា តាមអ្វីដែលលោកដឹងកាលពីសម័យនោះ ថាតើមន្ទីរគណៈអចិន្ត្រៃយ៍មជ្ឈិមហ្នឹង និងមន្ទីរ៨៧០ នោះ វាខុសគ្នាដូចម្តេច? ឬក៏វាតែមួយទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន គណៈអចិន្ត្រៃយ៍មជ្ឈិមមានប្រាំពីរនាក់ ដូចខ្ញុំបានរៀបរាប់ហើយ។ ឯចំណែក មន្ទីរ៨៧០ ជាកន្លែងធ្វើការជាប្រចាំរបស់បងៗប្រាំរូបគឺ បងប៉ុល បងនួន បងវ៉ាន់ បងវន និង បងខៀវ។

**ស៖** អ៊ីចឹងលោកចង់ជម្រាបតុលាការថា នៅពេលដែលលោកនិយាយថា មន្ទីរគណៈមជ្ឈិមនោះគឺ នៅក្នុងនោះមាន ខៀវ សំផន មាន ឌឿន ជាប្រធាន ហើយវាខុសគ្នាពីមន្ទីរ៨៧០ តាមអ្វីដែលលោកដឹងកាលពីសម័យនោះ។

[១០:០៩:០២]

**ឆ៖** អរគុណ។ ការដែលខុសគ្នាវានៅត្រង់នេះ។ បុគ្គលទាំងប្រាំរូប ដែលប្រចាំការនៅភ្នំពេញ គេមានសិទ្ធិអំណាចរបស់គេ ក្នុងឋានៈគេជាសមាជិកអចិន្ត្រៃយ៍។ ឯចំណែកបង ខៀវ សំផន ហើយនិងមិត្តឌឿន គ្មានអំណាចពេញដៃដូចក្នុងគណៈអចិន្ត្រៃយ៍មជ្ឈិមទេ។ បើសិនជាបង ខៀវ សំផន បើនិយាយអំពីគាត់ជាប្រធានមន្ទីរ-- ប្រធានគណៈមន្ទីរ៨៧០ គឺគាត់មានសិទ្ធិលើអង្គភាពមួយចំនួនដែលគាត់គ្រប់គ្រង។ អង្គភាពដែលខ្ញុំដឹងច្បាស់ជំនាន់នុ៎ងគឺ ដូចខ្ញុំនិយាយអ៊ីចឹង យ៉ាងហោចណាស់អគ្គិសនីចាក់អង្រែមួយដែរ។ ដូច្នេះ គាត់មានអង្គភាពគ្រប់គ្រង ក៏ប៉ុន្តែភស្តុតាងដែលខ្ញុំបានពីជំនាន់នោះពិតប្រាកដ គឺអគ្គិសនីចាក់អង្រែ។

[១០:១០:១៥]

**ស៖** សូមអរគុណ។ ទំនាក់ទំនងការងាររវាង ខៀវ សំផន ហើយនិង ប៉ុល ពត លោកបានជម្រាបតុលាការពីមុនថា គាត់ហ្នឹងមានទំនាក់ទំនងនឹងគ្នាល្អណាស់។ តើអ៊ីចឹងមែនឬទេ?

**លោក អាកទូរ វែកកែន៖**

លោកប្រធានសូមអរគុណ។ បាទខ្ញុំគិតថាសំណួរមុនអម្បាញ់មិញនេះ គឺយើងបានចេញពីការធ្វើសក្ខីកម្មស្តីអំពីចំណេះ ការដឹងឮរបស់គាត់កាលពីសម័យនោះទៅហើយ មកៗចូលដល់អ្វីដែលថា ដូចជាមិនការដឹងច្បាស់លាស់ ហើយឥឡូវនេះសហព្រះរាជអាជ្ញាបែរជាកាន់តែចោទសំណួរហ្នឹង កាន់តែ

វាឃ្លាតឆ្ងាយទៅៗ ដោយសួរទៅសាក្សីអំពីទំនាក់ទំនងរវាងកូនក្តីរបស់ខ្ញុំ ហើយនិងលោក ប៉ុល ពត នេះទៅវិញ ក្នុងខណៈដែលលោកសាក្សីនោះ គាត់ថា គាត់មិនដែលបានជួបគាត់ទេ ជាបុគ្គលនោះ។ យ៉ាងហោចណាស់ គឺថាមិនដែលជួបកូនក្តីខ្ញុំដែរ។ អ៊ីចឹងខ្ញុំចង់សួរថា តើគាត់ លោកសាក្សីនេះគាត់មាន មូលដ្ឋានអី ចំណេះដឹងអី ដែលឆ្លើយតបទៅនឹងសំណួរសហព្រះរាជអាជ្ញានោះ? ដូច្នេះ អ៊ីចឹងខ្ញុំពិបាក យល់ណាស់ ហើយពីព្រោះថា នៅពេលក្រោយយើងនឹងសរសេរធ្វើការកត់សម្គាល់ចុងក្រោយជាដើម នោះ។ អ៊ីចឹងវាធ្វើឲ្យមានការភាពស្រពេចស្រពិលជាច្រើន លោកសាក្សីហ្នឹងត្រូវបានគេស្តាប់ ៦៥ដងនៅ ក្នុងដំណាក់កាលស៊ើបអង្កេតនេះ ហើយនៅក្នុងសវនាការនេះក៏មានដែរ។ អ៊ីចឹង ខ្ញុំគិតថាប្រហែលជា ការសមស្របក្នុងផ្តល់សក្ខីកម្មឲ្យបានច្បាស់លាស់លើមូលដ្ឋាននៃចំណេះដឹង ដែលគាត់បានដឹងពីសម័យ នោះ ហើយដែលគាត់ជម្រាបជូនមកអង្គជំនុំជម្រះ។ នេះជាមូលហេតុនៃការជំទាស់របស់ខ្ញុំ នៃការ កត់សម្គាល់របស់ខ្ញុំ។

[១០:១២:២៤]

**លោក វីណ្លៀម ស្មីត៖**

ខ្ញុំនឹងអនុញ្ញាតពន្យល់អំពីទំនាក់ទំនងរវាងបុគ្គលទាំងពីរនៅកាលនោះ ហើយនិងនៅពេលក្រោយ។ ហើយខ្ញុំនឹងសួរសាក្សី លោកប្រធាន។

**សួរដោយលោក វីណ្លៀម ស្មីត៖**

**ស៖** លោកសាក្សី នៅក្នុងសម័យកាលដែលលោកធ្វើការនៅស-២១ តើលោកបានដឹងដែរឬទេ អំពីទំនាក់ទនង ឬទំនាក់ទំនងណាមួយរវាង ប៉ុល ពត និង ខៀវ សំផន? ប្រសិនបើលោកបានដឹងអំពី ទំនាក់ទំនងនោះ តើលក្ខណៈនៃទំនាក់ទំនងនោះយ៉ាងដូចម្តេច?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ពាក្យទំនាក់ទំនងរវាងបង ប៉ុល ពត និង បង ខៀវ សំផន ខ្ញុំជឿថាទាំងផ្ទៃក្នុងបក្សយើងទាំងមូលយល់។ ក្នុងនោះមានរូប-- រួមរូបខ្ញុំផងដែរ ដែល ខ្ញុំយល់។ ឯចំណែកយ៉ាងនេះហើយបានជាខ្ញុំចង់ដឹងថា មនុស្សបាក់ឌុបប៉ុនខ្ញុំ ម៉េចក៏គោរព ខៀវ សំផន អ៉ាន៎! គោរព ប៉ុល ពត? ចុះមនុស្សដល់ទៅថ្នាក់ដុកទ័រ ម៉េចក៏គោរព ប៉ុល ពត ដែរ? គោរពខ្លាំងម្ល៉េះ? ហ្នឹងហើយជាមូលហេតុដែលខ្ញុំហៅបង តូច ភឿន មកសួរ។ ដូច្នេះ ទំនាក់ទំនងរវាងខាងក្រោម និងខាង លើគឺវាអ៊ីចឹង។ ខ្ញុំហៅបង តូច ភឿន មកសួរ ដើម្បីចង់ដឹងថាមូលហេតុអីបានៗជាបង ខៀវ សំផន គោរពបង ប៉ុល ខ្លាំងម្ល៉េះ? ដល់ទៅ តូច ភឿន គាត់មិននិយាយអ៊ីចឹងទេ គាត់និយាយថាការគោរពហ្នឹង

វាមានសភាពយ៉ាងណាទៅវិញ? នេះសរុបមកផ្ទៃក្នុងបក្សរួមទាំងបង ខៀវ សំផន ផង គោរព ប៉ុល ពត។ ទុកសម្ដី ប៉ុល ពត ជាមាគ៌ាបក្ស ដែលល្មើសមិនបាន។ ខ្ញុំសូមបញ្ចប់។

[១០:១៤:៣៩]

**ស៖** នៅពេលនោះ តើលោកបានដឹងទេកាលពីលោកធ្វើការនៅស-២១ ថាតើ ប៉ុល ពត មានការគោរព ឬក៏សម្ដែងការគោរពទៅលោក ខៀវ សំផន ដែរឬទេ?

**ឆ៖** អរគុណ។ ខ្ញុំគ្មានភស្តុតាងណា និយាយពីបង ប៉ុល គោរពបង ខៀវ សំផន ក៏ប៉ុន្តែជាទូទៅ ខ្ញុំជឿថាមេ ហើយនិងកូន វាតែងមានការយកចិត្តទុកដាក់ដល់កូនណាដែលខ្លួនបណ្ដុះបណ្ដាល។ ដូចមេខ្ញុំ សុន សេន គាត់យកចិត្តទុកដាក់ដល់ខ្ញុំ ដែលគាត់ចង់បណ្ដុះបណ្ដាល។

**ស៖** តើលោកបានដឹងដែរឬទេ ទំនាក់ទំនងរវាង ខៀន ហើយនិង ប៉ុល ពត នៅក្នុងសម័យនោះ តើទំនាក់ទំនងនោះមានលក្ខណៈដូចម្ដេចដែរ?

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំបានឆ្លើយរួចមកហើយថា ខៀន មកនៅធ្វើការនៅក្នុងមន្ទីរមជ្ឈិម ក្នុងឋានៈជាអ្នកកាន់កាប់ខាងលេខាធិការដ្ឋាន នេះបើតាមខ្ញុំដឹង។ ហើយនិយាយតាមភាសានេះនៅពេលនេះ ហើយខ្ញុំបានជម្រាបអង្គប្រជុំរួចហើយថា ខៀន នេះដែលបង ប៉ុល គាត់យកមកធ្វើការនៅមន្ទីរមជ្ឈិម គឺដើម្បីបំបែកកម្លាំង កុយ ធួន កុំឲ្យវានៅជុំគ្នា តែប៉ុននុ៎ងឯងទេ។ នេះខ្ញុំដឹងប៉ុននុ៎ង។ ផ្ទៃក្នុងបក្ស វិភាគបក្ខជនខាងក្រោមៗដូចខ្ញុំ ក៏វិភាគអ៊ីចឹង។

[១០:១៦:៥៧]

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំចូលទៅប្រធានបទថ្មីមួយ គឺទំនាក់ទំនងរវាងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយនិងរណសិរ្សរួបរួមជាតិកម្ពុជា មុនឆ្នាំ១៩៧៥ ហើយនិងក្រោយ១៩៧៥។ សំណួរគឺថា តើលោកដឹងទេ ថាមាននយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងទៅនឹងសមាជិកដែលមិនមែនជារបស់បក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែអ្នកនុ៎ងចេញមកពីរាជរដ្ឋាភិបាលរួបរួមកម្ពុជា តើគេមានគោលនយោបាយដូចម្ដេចចំពោះអ្នកទាំងនោះ?

**ឆ៖** អរគុណ។ ខ្ញុំសូមនិយាយអំពីពាក្យរណសិរ្ស។ ពាក្យរណសិរ្សគឺជាការប្រមូលកម្លាំងមកដើម្បីបំពេញភារកិច្ចជាយុទ្ធវិធីណាមួយ ក្នុងនោះបើនិយាយតាមន័យជាយុទ្ធសាស្ត្រយូរអង្វែង វាមានអ្នកខ្លះជាមិត្ត អ្នកខ្លះមិនមែនជាមិត្ត ហើយអ្នកខ្លះជាខ្មាំង។ នេះជាបញ្ហាធំ។ ខ្ញុំសូមរំឭកថា នៅឆ្នាំ១៩៧៣ មានវគ្គសិក្សាមួយ អង្កាល់នោះ វន វេត គាត់ឲ្យឧទ្ទេសនាម គាត់ថា "យើងធ្វើ យើងហូប

ម្ល៉ោះហើយយើងខំធ្វើ ទុកឲ្យ សីហនុ គាត់អង្គុយធ្វើប្រធានរបស់យើង"។ ពាក្យខ្លីប៉ុន្មានម៉ាត់នេះ ខ្ញុំជឿថាអ្នកណាក៏យល់ដែរអំពីតួនាទីរបស់រណសិរ្ស ជាពិសេស សីហនុ។ នេះខ្ញុំសូមនិយាយប៉ុណ្ណឹងមុនឆ្នាំ ១៩៧៥។

[១០:១៩:០៩]

ដល់ក្រោយឆ្នាំ១៩៧៥ មានវគ្គឧទ្ទេសនាមមួយដែរ។ សុន សេន គាត់ឧទ្ទេសនាម គាត់ថាបក្សយើងធ្វើខុសប្លែកពីគេ។ គេមានចាត់តាំងប្រមុខរដ្ឋ ឯចំណែកយើងចាត់តាំងប្រធានគណៈ-- អ៊ូ! ឯចំណែកបក្សយើងចាត់តាំងគណៈប្រធានរដ្ឋ។ ហ្នឹងប្លែកគេ។ នៅពេលនុ៎ង គឺសម្រេចអ៊ីចឹង។ ដល់ក្រោយមកបាន១ឮតាមវិទ្យុផ្សាយថា សីហនុ គាត់សុំលាលែងចូលនិវត្តន៍។ ខាងបក្សកុម្មុយនីស្តកម្ពុជាគេឲ្យចូលនិវត្តន៍។ នេះជារឿងពិតមួយនៅចំពោះតួអង្គ នរោត្តម សីហនុ។ ដោយឡែក ទូតចាស់ សមាជិករាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាចាស់ គេយកមកចូលនៅក្នុងជំរំអប់រំនានា មានជំរំបឹងត្របែក ហើយនិងជំរំនៅច្រាំងចំរេះជាដើម។ យូរ១ឃើញប្រគល់ទៅឲ្យស-២១ ម្នាក់។ ខ្ញុំសូមរំឭក នៅពេលដែលប្រគល់ ហួត សម្បត្តិ ទៅឲ្យស-២១ សុន សេន គាត់ថា ហ៊ឺ! អង្កាល់ ហួត សម្បត្តិ ធ្វើកុង្សីយ៍ អប់រំគាត់វេទនាចង់ងាប់។ ហួត សម្បត្តិ ផ្តាច់*ប៊ូក* គាត់។ នេះជាអនុស្សាវរីយ៍មួយដែលខ្ញុំចងចាំ ពីសម្តីមេខ្ញុំដែលគាត់កំប្លុកកំប្លែងលេង។ តើគំនុំវាយ៉ាងម៉េច ដែលបក្សកុម្មុយនីស្តប្រើ? នេះអង្គប្រជុំជ្រាបហើយ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

**ស៖** តើលោកយល់ស្របដែរឬទេ រដ្ឋមន្ត្រីថ្នាក់ខ្ពស់មួយចំនួនមកពីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ទីបំផុតក៏ត្រូវបានគេបញ្ជូនទៅស-២១ ដែរនោះ? តើដូច្នោះឬទេ?

[១០:២១:២៧]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន កាលណោះ រដ្ឋមន្ត្រីដូចចាត់តាំងតែខាងក្នុងទេ ខាងក្រៅសុទ្ធតែទូត។

**ស៖** តើលោកយល់ស្របទេគឺថា អតីតសមាជិកនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលមានថ្នាក់ខ្ពស់១នោះក៏ត្រូវបានគេបញ្ជូនមកស-២១ ដែរ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ទូតដែលជា-- ចាត់តាំងដោយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឃើញបញ្ជូនទៅស-២១ បណ្តើរ១។ ក្នុងនោះមាន ហួត សម្បត្តិ នេះដែលខ្ញុំនៅចាំឈ្មោះជាងគេ។

[១០:២២:៤៩]

**ស៖** តើគោលនយោបាយនោះ គឺសំដៅប្រឆាំងចំពោះសមាជិករបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានោះឬទេ ដែលលោកនិយាយថាដំបូងគេចាប់ផ្តើមពីការអប់រំ កែប្រែឡើងវិញ មានមណ្ឌលប៉ុន្មានអំមិញនោះ ហើយទីបំផុតគេបញ្ជូនទៅស-២១ នោះបាទ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន មែន ដំបូងចាត់តាំងនៅក្នុងជំរំអប់រំសាឡើងវិញ ជំរំអប់រំបញ្ញាជន។ ដល់ក្រោយមកមួយរយៈក៏បញ្ជូនទៅវិញ ដោយគណៈកម្មាធិការមន្ទីរអប់រំហ្នឹងគេសង្កេតឃើញសភាពមិនល្អ។ នេះខ្ញុំនិយាយជារួម។ ត្រង់សភាពមិនល្អរឿងអីខ្លះ ខ្ញុំហួសពីការយល់ដឹងរបស់ខ្ញុំហើយ ខ្ញុំមិនជាក់ស្តែងជាមួយនឹងបញ្ហាអស់នុ៎ងទេ ឲ្យតែគេបញ្ជូនមកអាហ្នឹងត្រូវតែសួរហើយ។

[១០:២៤:០៧]

**ស៖** សូមអរគុណ។ ប្រធានបទមួយចុងក្រោយ នៅពេលដែលលោកបានចាកចេញពីស-២១ នៅ ខែមករា ឆ្នាំ១៩៧៩។ តើលោកបានទុកឯកសារទាំងអស់នោះចោលនៅទីនោះឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ថ្ងៃ០៧ មករា យើងខ្ញុំចេញ។ ពេលនោះរថក្រោះ គេមកដល់មុខផ្ទះទៅហើយ រត់ចេញ។ ផ្ទាល់ខ្លួនខ្ញុំបានតែស្លាបប៉ាកកាមួយ ហើយនិងកាំភ្លើងខ្លីមួយដើម អត់ទាំងស្បែកជើងទៅទៀត។ ដូច្នេះ ខ្ញុំជឿថា នៅក្នុងអង្គភាពខ្ញុំគ្មាននរណាយកបានស្អីទេ ឯកសារនៅទាំងអស់ នៅនុ៎ង។

**ស៖** លោកបាននិយាយថា កាលណោះ លោក នួន ជា ជាមេរបស់លោក។ ថាតើលោកបានប្រាប់-- គាត់បានប្រាប់អ្វីថាប្រាប់ឲ្យកម្ទេចឯកសារចោល ឬក៏ឲ្យទុកឯកសារចោលនៅស-២១ តើគាត់បានផ្តល់ការណែនាំអ្វីចំពោះលោកទេ ទាក់ទងទៅនឹងឯកសារនោះ មុននឹងឲ្យលោកចេញពីភ្នំពេញនោះ?

[១០:២៥:៣២]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំនិយាយលើកមុនម្តងរួមកហើយ ពីរឿងជួបបងនួន ជាចុងក្រោយបំផុត។ ខ្ញុំស្រពេចស្រពិល ដល់គិតចុះគិតឡើង គឺសង្ស័យថានៅថ្ងៃ០១ ឬថ្ងៃ០២ ប្រហែលជាថ្ងៃ០១ មករា ១៩៧៩ ពេលនោះ បងនួន ណែនាំឲ្យតែកម្ទេចអ្នកទោសឲ្យអស់។ នេះ ខ្ញុំមិននិយាយពីរឿងល្អិតនេះឡើងវិញទេ។ ឯចំណែករឿងឯកសារ បងនួន អត់មានណែនាំទេ អត់មានណែនាំសោះ។ នេះ ខ្ញុំសូមបញ្ជាក់តែប៉ុណ្ណឹង។

**ស៖** តើអ្នកទោសនៅសល់ប៉ុន្មាននាក់នៅកាលណោះ នៅពេលដែលគាត់បានបញ្ជាលោកថាឲ្យលោកកម្ទេចឲ្យអស់នោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន អ្នកទោសមិនតិចទេ មិនមែនមួយរយទេ លើស ប្រហែលជាបួនប្រាំរយក៏មិនដឹង ឬក៏លើសហ្នឹងទៀតមិនដឹង។

[១០:២៦:៥៤]

**ស៖** ថាតើលោកបានគោរពបញ្ជានោះដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំទទួលបញ្ជាមកភ្លាម ខ្ញុំហៅ មិត្តហ៊ី មកប្រាប់ភ្លាម។ មិត្តហ៊ី ចាប់ផ្ដើមដំណើរការភ្លាម។ បីថ្ងៃក្រោយមកអាច ប្រហែលជាបីថ្ងៃក្រោយមក មិត្តហ៊ី មករាយការណ៍ថាចប់ទៅហើយ ភារកិច្ចបានអនុវត្តចប់សព្វគ្រប់ហើយ។ នេះរឿងពិត។

**ស៖** ត្រឡប់ទៅឯកសារវិញ ថាតើលោកបាន-- លោកនិយាយថាមិនបានទទួលការណែនាំទេទាក់ទងទៅនឹងឯកសារ។ ចុះនៅពេលក្រោយ បន្ទាប់ពី១៩៧៩មក តើលោកធ្លាប់បានការពិភាក្សាអ្វីជាមួយលោក នួន ជា ទេ ថាតើឯកសារទាំងអម្បាលម៉ាននៅស-២១ នោះ វាយ៉ាងម៉េច? តើលោកបានពិភាក្សាជាមួយគាត់ពីរឿងហ្នឹងទេ?

[១០:២៨:០៩]

**ឆ៖** អរគុណ។ រឿងនេះ វាជារឿងកើតឡើងនៅក្នុងឆ្នាំ១៩៨៣ ឬក៏៨៤ តាមចាំមែនទែនប្រហែលជា៨៣។ បងនួន គាត់អញ្ជើញចុះទៅប្រចាំការនៅសមរភូមិសំឡូត។ ថ្ងៃមួយនោះ គាត់ហៅខ្ញុំទៅជួប។ គាត់ថា ថ្ងៃរៀបចេញហ្នឹង មិត្តអត់បានជួបធ្វើការជាមួយខ្ញុំណ៎ះ។ មិត្តជួបធ្វើការជាមួយអ៊ំហែម។ ខ្ញុំថាបាទ។ អង្គាល់ហ្នឹង គេលែងហៅបងហើយ គេហៅអ៊ំ។ អ៊ំហែម ហ្នឹង សាធារណជនស្គាល់ហើយ តុលាការក៏ស្គាល់ដែរ គឺបងខៀវ សំផន។ ខ្ញុំថាបាទ។ រួចចុះឯកសារ មិត្ត។ ខ្ញុំថា ឯកសារនៅស្រមាមប៉ាកអ៊ីចឹងបង។ ន៎ែ ខាងខ្ញុំន៎ែ កម្ទេចខ្ទេចអស់ហើយណាស់។ មិត្តអន់ណាស់ ប៉ុណ្ណឹងមិនម្ចាស់ការ។ ហ្នឹងភាសាគាត់។ ដូច្នេះ ខ្ញុំពេលនេះ អាចខុសមួយម៉ាត់ពីរម៉ាត់ ពីភាសាដើម។

[១០:២៩:៣៦]

ហើយខ្ញុំសូមរំឭកទៅមុខបន្តិចទៀត។ ដល់ថ្ងៃ២៥ មិថុនា ១៩៧០-- អ៎ ៨៦ ខ្ញុំទៅជួបមេខ្ញុំ សុន សេន។ ខ្ញុំរាយការណ៍រឿងទាំងអស់នេះ។ បងសុន សេន គាត់ធ្វើ អ៊ឺះ! ចាំតែអស់ចុះ។ នេះអំពីឯកសារខាងមជ្ឈិម។ នេះ សូមរាយការណ៍អំពីឯកសារតាមដំណើរការវិវត្តន៍ក្រោយ១៩៧៩។

**ស៖** នៅពេលដែលជួបពិភាក្សាបែបនោះ តើអាកប្បកិរិយា ចិត្តអារម្មណ៍របស់គាត់នោះ ពេលដែលលោកឆ្លើយថា អ្អឺ!អត់បានទេ នៅស្រមាមប៉ាកអ៊ីចឹង តើមើលអារម្មណ៍គាត់នោះបែបណាកាលនុ៎ង?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន តើលោកព្រះរាជអាជ្ញាសួរខ្ញុំ ពីអារម្មណ៍អ្នកណា អារម្មណ៍ បងនួន ឬអារម្មណ៍ បងខៀវ? អារម្មណ៍លោក នួន ជា ឬអារម្មណ៍លោក សុន សេន?

**ស៖** បាទ អារម្មណ៍របស់លោក នួន ជា?

[១០:៣១:០០]

**ឆ៖** អរគុណ។ តាមខ្ញុំធ្លាប់ចុះឡើងធ្វើការជាមួយ បងនួន អារម្មណ៍គាត់តែប៉ុណ្ណឹង។ មិនសូវទទួលស្គាល់ចំណុចខ្សោរបស់ខ្លួនទេ។ មិនសូវអ៊ី មិនទទួលស្គាល់ចំណុចខ្សោយរបស់ខ្លួនផង ច្រើនតែសង្គ្រុបខាងក្រោម។ ឲ្យតែខាងក្រោម ឃើញចំណុចខ្វះខាតរបស់ខ្លួន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក សុន អរុណ៖**

ចម្លើយ-- សូមគោរពលោកប្រធាន ចម្លើយចុងក្រោយរបស់សាក្សី គឺចម្លើយសន្និដ្ឋាន។ សូមប្រឆាំង។

[១០:៣១:៥៣]

**ប្រធានអង្គជំនុំ៖**

ឈប់! តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ តើលោកមានប៉ុន្មានសំណួរទៀត?

**លោក វីណ្ឌៀម ស្មីត៖**

ប្រហែលជាមានមួយ ឬក៏ពីរទេ ហើយសំណួរនោះខ្លីៗទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមបន្ត បញ្ចប់សំណួរ។ សូមអញ្ជើញ!

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** លោកសាក្សី លោកបានលើកឡើងថា នៅពេលដែលលោកផ្តល់ចម្លើយដល់សហចៅក្រមស៊ើបអង្កេត និងនៅក្នុងតុលាការនេះកាលពីសប្តាហ៍មុន តាមការពិនិត្យមើលឯកសារ លោកបានដឹងអំពីការងាររបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ដូច្នេះ សំណួរដែលខ្ញុំចង់សួរ

នោះ គឺថាក្នុងរយៈពេលដែលលោកផ្ដល់ចម្លើយ ប្រាំមួយថ្ងៃនេះ តើវាជាការដឹងឮអ្វីដែលលោកបានដឹងក្នុងអំឡុងពេលនោះមែនដែរឬទេ? ហើយក្នុងនោះ គឺយើងមិនពិចារណាទៅលើចម្លើយដែលលោកបានដឹង និងមើលឯកសារកាលពីលើកមុននោះទេ?

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមធ្វើការជំទាស់។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

[១០:៣៣:២០]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ អរុណសួស្ដីអស់លោក លោកស្រីទាំងអស់នៅក្នុងបន្ទប់សវនាការ និងនៅជុំវិញបន្ទប់សវនាការ។ លោកសាក្សីតែងតែបញ្ជាក់ហើយថា តើគាត់បានដឹងអ្វីខ្លះក្រោយពីពេលនោះមក។ ដូច្នេះនៅពេលនេះ សហព្រះរាជអាជ្ញាហាក់ដូចជាធ្វើការសរុបការផ្ដល់សក្ខីកម្មរបស់លោកសាក្សីក្នុងរយៈពេលប៉ុន្មានថ្ងៃមកនេះ តើជាអ្វីដែលលោកបានដឹងចងចាំដែរឬទេ?

ដូច្នេះហើយ វាជាមិនការគប្បីនោះទេ ប្រសិនបើឲ្យសាក្សីបញ្ជាក់សុពលភាពទៅលើសក្ខីកម្មរបស់ខ្លួននោះ។ គឺសាក្សីគាត់បានបញ្ជាក់ហើយនូវអ្វីដែលគាត់បានដឹងក្រោយមក ក៏ប៉ុន្តែបើសិនជាសួរដូច្នេះ ខ្ញុំសូមជំទាស់ សំណួរដែលបានសួរឡើងនេះ គឺវាមិនគួរទេ គួរឲ្យមានលក្ខណៈឆ្គង ហើយគ្មានតម្លៃជាច្បាប់-- ជាសំណួរត្រឹមត្រូវតាមច្បាប់នោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មេធាវីជាតិការពារក្ដីលោក ខៀវ សំផន!

[១០:៣៤:២៦]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ តាមការស្ដាប់ចម្លើយរបស់សាក្សីកន្លងមក យើងឃើញថាសាក្សីបានគូសបញ្ជាក់ជាច្រើនប្រាប់ថា សំណួរណាដែលជា-- ចម្លើយណាដែលជាប្រភេទការសន្និដ្ឋានរបស់គាត់ ហើយយើងក៏បានស្ដាប់ចម្លើយរបស់គាត់តាមរយៈការសន្និដ្ឋាននេះជាច្រើនដែរ។ ហើយនៅពេលដែលចុងបញ្ចប់ បើសហព្រះរាជអាជ្ញាលើកសំណួរមួយ ដើម្បីឲ្យសាក្សីឆ្លើយបញ្ជាក់ថា ជាចម្លើយ

ដែលដឹងក្នុងព្រឹត្តិការណ៍មុនឆ្នាំ១៩៧៩ ឬក៏ទើបដឹងក្រោយនោះ គឺសាក្សីមិនអាចផ្តល់ចម្លើយនេះបានថាចម្លើយណាមួយពិតប្រាកដទេបាទ។ សូមអរគុណ។

[១០:៣៥:០៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** បាទ ខ្ញុំសូមសួរសំណួរឡើងវិញរយៈពេលប្រាំមួយថ្ងៃកន្លងមកនេះ តើលោកបានជម្រាបតែការពិតជូនអង្គជំនុំជម្រះដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ម៉្ងៃនោះខ្ញុំបាននិយាយទាំងអស់ ថាខ្ញុំទទួលស្គាល់ពាក្យគ្រប់ម៉ាត់របស់ខ្ញុំ ទាំងនៅរយៈពេលស៊ើបអង្កេត ទាំងនៅពេលសវនាការសំណុំរឿងលេខ ០០១។ ពេលខ្លះ គ្រាន់តែពេលខ្លះខ្ញុំជម្រាបជាគោលការណ៍ ដូចខ្ញុំជម្រាបជូនចៅក្រម ឡាវែន៍ ហើយខ្ញុំចូលជាក់ស្តែងលម្អិតបញ្ហា។ ដូច្នេះ ខ្ញុំទទួលស្គាល់ពាក្យខ្ញុំ គឺខ្ញុំគោរពតាមការដែលបានដឹង បានឮ និងបានឃើញ និងបានធ្វើ។

[១០:៣៦:១៩]

**លោក វីល្លៀម ស្មីត៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ បាទ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ ហើយមន្ត្រីអនុរក្សមន្ទីរឃុំឃាំងសូមសម្រួលដល់សាក្សី ក្នុងការសម្រាកនៅកន្លែងសម្រាកសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅមុនពេលអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមអរគុណ ហើយសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ដោយសារបញ្ហាសុខភាព ជាពិសេសបញ្ហាចង្កេះ ខ្នង និងជើង លោក អៀង សារី ថ្ងៃនេះស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ក៏ប៉ុន្តែសូមចូលរួមដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោមសម្រាប់ថ្ងៃពេញតែម្តង។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាអនុញ្ញាតតាមសំណើ។ សូមអរគុណ។

[១០:៣៧:២៦]

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលធ្វើឡើងតាមរយៈការពារក្តីរបស់គាត់សុំលះបង់សិទ្ធិមិនចូលរួមតាមដានក្នុងកិច្ចដំណើរសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយសុំទៅបន្តតាមដានកិច្ចដំណើរសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ ពីបន្ទប់មួយនៅក្រោមបន្ទប់សវនាការនេះ ដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយតាមដានផ្ទាល់នៅក្នុងដំណើរការសវនាការយូរបាន។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ សុំលះបង់សិទ្ធិមិនចូលរួមដោយផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការ ក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅខាងក្រោមបន្ទប់សវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់កិច្ចដំណើរការសវនាការពេញមួយថ្ងៃនេះ។

ហើយអង្គជំនុំជម្រះបង្គាប់ឲ្យមន្ត្រី អ៎!ឲ្យមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ត្រូវផ្តល់មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយចុះហត្ថលេខា ឬផ្តិតម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ អៀង សារី និងបង្គាប់ឲ្យមន្ត្រីខាងប្រព័ន្ធសោតទស្សន៍ភ្ជាប់ខាងប្រព័ន្ធសោតទស្សន៍ឲ្យជនជាប់ចោទរូបនេះអាចបន្តតាមដានកិច្ចដំណើរការនេះពីចម្ងាយសម្រាប់កិច្ចដំណើរការសវនាការជាបន្តទៅសម្រាប់ថ្ងៃនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោម ដែលបានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ តាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៩ នាទី ដល់ម៉ោង ១១:០០ នាទី)*

[១១:០០:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តនេះ គឺអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ កាលពីសប្ដាហ៍មុនខ្ញុំបាទ បានជម្រាបជូនលោក លោកស្រីចៅក្រមថា មេធាវីនាំមុខប្រគល់សិទ្ធិជូនលោកស្រី ស៊ីន សុវ៉ន ហើយនិងលោកស្រីមេធាវី លី ម៉ាញៀន។ ពេលនេះ យើងខ្ញុំមានការផ្លាស់ប្ដូរ ដោយប្រគល់សិទ្ធិជូនទៅលោក ហុង គីមសួន ជំនួសឲ្យលោកស្រី ស៊ីន សុវ៉ន ហើយនាឱកាសនេះ លោក ហុង គីមសួន នឹងចាប់ផ្ដើមជាដំបូងនៅក្នុងការសួរ-- លើកជាសំណួរ ហើយបន្ទាប់មកបានលោកស្រីមេធាវី លី ម៉ាញៀន នឹងបន្តទៀត។ សូមអរគុណលោកប្រធាន។

[១១:០១:០៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ ហើយសូមផ្ដល់វេទិកាទៅមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលសិទ្ធិ។ សូមអញ្ជើញ!

**លោក ហុង គីមសួន៖**

សូមអរគុណបាទ។ បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** សួស្តីលោកសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច! ថ្ងៃនេះ ខ្ញុំមានពាក្យពេចន៍បន្តិចដើម្បីជាការគួរសមជាមួយលោកបន្តិចសិន នឹងឈានចូលទៅដល់សំណួរ។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។

**ស៖** យើងខ្ញុំជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ហើយក្នុងថ្ងៃនេះ ក្នុងនាមជាតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីគឺ ខ្ញុំបាទសូមសួរលោកទាក់ទងជាមួយនឹងការចោទប្រកាន់ទៅលើមេដឹកនាំ ឬក៏ជនត្រូវចោទដែលកំពុងតែមានវត្តមាននៅទីនេះខ្លះ និងគាត់សម្រាកខ្លះ។ ទោះបីថានៅក្នុងសំណុំរឿង ០០១ ដែលលោកបានបំភ្លឺ ឬក៏លោកបានឆ្លើយក្នុងនាម-- ក្នុងសំណុំរឿង ០០១ រួចមកហើយក៏ដោយក៏លោកបានថ្លែង អំពីវិប្បដិសារីរបស់លោកកាលនៅក្នុងជំនាន់សម័យកម្ពុជាប្រជាធិបតេយ្យ ដែលមានជនរងគ្រោះបាត់បង់ជីវិតជាមួយ ១២.០០០នាក់ នៅពេលនោះ ហើយលោកថែមទាំងបាន ធ្វើសេចក្តីថ្លែងសូមទោស ហើយលិខិតដែលប្រមូលផ្តុំនូវពាក្យពេចន៍ការសុំទោសរបស់លោកនោះ ក៏បានចងក្រងនៅក្នុងសាលដីការបស់សំណុំរឿង០០១ រួចមកហើយដែរ។

[១១:០៣:២១]

ពាក្យទាំងអស់នេះ ពាក្យអភ័យទោសរបស់លោកនោះ គឺលោកទទួលស្គាល់ និងទទួលខុសត្រូវខាងផ្លូវសីលធម៌ និងខាងផ្លូវចិត្តដែលបានកើតឡើងផងដែរ។ ហើយទាំងអស់នេះ គឺសបញ្ជាក់ឲ្យឃើញថា អ្វីដែលមានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩ គឺជាការបង្ហាញភាពយកចិត្តទុកដាក់ និងការសហការរបស់លោកជាមួយនឹងតុលាការនេះបានយ៉ាងល្អបំផុត។ ហើយយើងខ្ញុំនៅក្នុងនាមតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ក៏មានសេចក្តីត្រេកអរ និងអរគុណជាពន្លឺកដែលលោកបានថ្លែង និងបើកចំហឲ្យប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ក៏ដូចជា មនុស្សលោកនៅក្នុងពិភពលោកទាំងមូលបានដឹងអំពីហេតុផល ដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ។

[១១:០៤:១៣]

ហើយបន្តទៅទៀតនេះ យើងខ្ញុំសង្ឃឹមថា លោកនឹងសហការបំភ្លឺទាក់ទងជាមួយនឹងការ--

សវនាការសំណុំរឿង០០២ ក្នុងវគ្គទី១ ដែលយើងហៅថា សំណុំរឿង០០២/០១ នេះ ទាក់ទងជាមួយនឹងការបង្កើតបក្សកុម្មុយនីស្តកម្ពុជា ឬក៏ប្រវត្តិនៃកម្ពុជា អ៎! ប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជា បង្កើតបរិបទរដ្ឋបាល និងទំនាក់ទំនងរចនាសម្ព័ន្ធការងារជាដើម។ ជំនួសមុខឲ្យជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ខ្ញុំសូមជម្រាបជូនលោកថា អ្វីដែលលោកបានសន្យាចំពោះពួកគេនៅពេលកំពុងដំណើរការនីតិវិធីរឿងក្តី ដែលធ្វើការជំនុំជម្រះលើលោកក្នុងសំណុំរឿង០០១ សង្ឃឹមថា លោកនឹងទទួលសហការ និងបំភ្លឺ ទាក់ទងជាមួយនឹងជនជាប់ចោទផ្សេងៗទៀតយ៉ាងល្អប្រសើរ។ ដូច្នេះតទៅនេះខ្ញុំសូមសួរលោកទាក់ទងជាមួយនឹងសំណួរផ្សេងៗខ្លះទៀត ដោយសារខាងសហព្រះរាជអាជ្ញាលោកបានធ្វើការសាកសួរលោកច្រើនហើយ។ អ៊ីចឹង ខ្ញុំចាប់អារម្មណ៍ទៅលើរចនាសម្ព័ន្ធ និងទំនាក់ទំនងការងារខាងក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ។ សំណួរទីមួយ សួរថាតើលោកនៅចាំបានទេក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រសួងការបរទេស តើមេធំ ឬក៏ប្រធាន ឬយើងហៅថា រដ្ឋមន្ត្រីក្រសួងការបរទេសជានរណាគេ?

[១១:០៥:៤៨]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន រដ្ឋមន្ត្រីក្រសួងការបរទេសគឺ លោក អៀង សារី ហៅ វ៉ាន់។

**ស៖** បាទ សូមអរគុណ។ លោកបានជម្រាបអង្គសវនាការរួចមកហើយថា កាលពីក្នុងជំនាន់របបកម្ពុជាប្រជាធិបតេយ្យ លោកមិនដឹងថា ទីតាំងរបស់ក្រសួងការបរទេសនៅត្រង់ណានោះទេ ប៉ុន្តែលោកបានដឹងថា ក្រសួងការបរទេស គឺមានលោក អៀង សារី ហៅ វ៉ាន់ ជារដ្ឋមន្ត្រី។ សំណួរតទៅទៀត សុំសួរលោកថា តើលោកបានដឹងទេថា កាលដែលខាងមជ្ឈិមបក្ស ឬក៏បក្សកុម្មុយនីស្តកម្ពុជា ក្នុងសម័យនោះសម្រេចចាត់តាំង ឬសម្រេចជ្រើសតាំងអ្នកដែលមានមុខងារជារដ្ឋមន្ត្រី ឬក៏ទទួលបន្ទុកតាមអង្គភាពធំៗនោះ តើគេធ្វើឡើងនៅពេលណាដែរទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឲ្យដឹងថ្ងៃខែកាលបរិច្ឆេទពិតប្រាកដមិនដឹងទេ ក៏ប៉ុន្តែខ្ញុំជឿថា ក្រោយពីសម័យបោះឆ្នោតសភា ដែលគេហៅថា បោះឆ្នោតសភានោះ តាមពិតវាអត់មានបោះឆ្នោតទេ។ ដូច្នេះ បានជាខ្ញុំនិយាយថា ដែលគេហៅថា បោះឆ្នោតសភា។

[១១:០៧:៣០]

**លោក ហុង គីមសួន៖**

សូមអរគុណ។ កាលពីសប្ដាហ៍មុន ខាងសហព្រះរាជអាជ្ញាបានសុំអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះ បង្ហាញលោកនូវឯកសារមួយចំនួន ហើយខ្ញុំនឹងសូមអនុញ្ញាតលោកប្រធានបង្ហាញឯកសារដដែលឡើងវិញ ដើម្បីធ្វើការសាកសួរលោក ឌុច នូវចំណុចមួយចំនួនដែលខុសប្លែកគ្នាពីខាងសហព្រះរាជអាជ្ញាបង្ហាញលោកសាក្សីបាទ ទាក់ទងនឹងឯកសារ IS13.2 ERN00019108 ដែលក្នុងចំណងជើងថា "ការប្រជុំអចិន្ត្រៃយ៍ ថ្ងៃ០៩ ខែ១០ ឆ្នាំ៧៥"។

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត ហើយមន្ត្រីរដ្ឋបាលតុលាការបង្ហាញឯកសារ នៅលើអេក្រង់ទូរទស្សន៍តាមសំណើសុំរបស់មេធាវី!

[១១:០៨:៤៦]

**សួរដោយលោក ហុង គីមសួន៖**

បាទ សូមអរគុណ។

**ស៖** លោក កាំង ហ្កេកអ៊ាវ តើលោកមើលឃើញឯកសារបញ្ចាំងលើអេក្រង់បានច្បាស់ទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមើលឃើញច្បាស់។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរលោកបន្ថែមបន្តិច តែមួយសំណួរទេ ដែលវាស្រដៀងគ្នាឬក៏ដូចគ្នាក្នុងទំព័រទីមួយនេះ ដែលគូសរង្វង់ក្រហម លោកមើលឃើញ លោកអានបានទេ? លោកបង្វិល *ម៉ៅស៍* លោកបានទេ?

**ឆ៖** ខ្ញុំអត់ចេះទេ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការជួយ!

**លោក ហុង គីមសួន៖**

លោកប្រធាន ខ្ញុំបាទសូមអានជំនួសគាត់បានទេ?

លោកបានឃើញច្បាស់ហើយទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

អត់មានសិទ្ធិផ្ដល់ឯកសារដើមមកខ្ញុំទេ?

[១១:១០:២៥]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអាចផ្តល់ឯកសារដើមជាក្រដាស ដែលមានគូសរង្វង់ក្រហមតាមបំណងប្រាថ្នារបស់លោក ដែលក្នុងបំណងតាំងសំណួរ ដើម្បីផ្តល់ជូនទៅសាក្សី ដូចអ្វីដែលតំណាងសហព្រះរាជអាជ្ញាបានធ្វើកន្លងមកហើយ ប៉ុន្មានថ្ងៃហើយ។ ឯកសារដទៃទៀតដូចគ្នា បើសិនជាមានបំណងធ្វើដូច្នេះ ពីព្រោះយើងឃើញទាំងអស់គ្នាហើយ មានចំណុចឃើញ ហើយនិងចំណុចឃើញដែលមើលមិនច្បាស់។ ឧទាហរណ៍ដាក់នៅអេក្រង់នៅទូរទស្សន៍ម្ខាងទៀតហ្នឹង គឺមើលគ្រាន់តែបានឃើញទេ ព្រិល មើលមិនច្បាស់ទេ ងាយស្រួលគឺធ្វើតាមបច្ចេកទេស ដែលលំនាំតំណាងសហព្រះរាជអាជ្ញាបានអនុវត្តច្រើនលើកច្រើនសាមកហើយ។

**លោក ហុង គីមសួន៖**

បាទអរគុណបាទ។ អ៊ីចឹង ខ្ញុំបាទសូមអនុញ្ញាតអានតែមួយចំណុចដែលមានរង្វង់ក្រហមនៅចំពោះមុខតែម្តងទៅ ដើម្បីសន្សំពេលវេលាផងដែរ ព្រោះឯកសារនេះបានបង្ហាញម្តងហើយបាទ។ ហើយខ្ញុំបាទគ្រាន់តែសួរលោកសាក្សី បើសិនជាលោកមើលឃើញលើអេក្រង់ហើយ ខ្ញុំនឹងអានជូនបន្តិច។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** តើលោកបានពិនិត្យឃើញហើយនៅបាទ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំបានឃើញហើយ។

**ស៖** បាទលោកអានក្នុងរង្វង់ពណ៌ក្រហមនេះបានទេបាទ?

[១១:១២:០៨]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមអានដូចតទៅ៖ "៣) សមមិត្ត វ៉ាន់ ការងារបរទេស ទាំងបក្សទាំងរដ្ឋ"។ អរគុណ។

**ស៖** បាទសូមអរគុណបាទ។ ខ្ញុំបាទសូមបន្តសំណួរទៅទៀត។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺក្នុងចន្លោះថ្ងៃ១៧ មេសា ១៩៧៥ ដល់០៦ មករា ១៩៧៦ (ស៊ីក) លោកបានជម្រាបជូនអង្គសវនាការស្តីពីការចូលរួមប្រជុំជាមួយនឹងអចិន្ត្រៃយ៍ ឬគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមជាច្រើនលើកច្រើនសា។ ក្នុងនេះអ្វីដែលខ្ញុំបាទចង់សួរសំណួរទៅលោកទៀតនោះ គឺទាក់ទងជាមួយនឹងកិច្ច

ការងាររបស់ក្រសួងការបរទេសជាមួយនឹងបជ្ឈិមបក្ស ឬជាមួយនឹងអចិន្ត្រៃយ៍ដែលលោកបានដឹង។ តើលោកអាចជម្រាបជូនអង្គសវនាការបានខ្លះទេបាទ?

[១១:១៣:១៦]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន សម្រាប់ខ្លួនខ្ញុំមិនដែលបានចូលទៅប្រជុំជាមួយនឹងអចិន្ត្រៃយ៍ ឬជាមួយមជ្ឈិមទេ។ ដូច្នេះខ្ញុំមិនៗឆ្លើយទេ សូមលោកមេធាវីមេត្តារៀបចំសំណួរឲ្យស្រួលស្តាប់ ស្រួលឆ្លើយ។

**ស៖** បាទសូមអរគុណ។ តើលោកដែលបានដឹងទេថា ការបញ្ជូនឈ្មោះមនុស្សដែលជាជនជាតិខ្មែរនៅបរទេស ត្រូវបានបញ្ជូនទៅលោកនៅមន្ទីរស-២១ ថាជាមនុស្សរបស់ក្រសួងការបរទេសដោយរបៀបណាបាទ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បើនិយាយអំពីមនុស្សរបស់ក្រសួងការបរទេស មនុស្សដែលមានថ្នាក់ខ្ពស់ជាងគេ គឺទូតៗរបស់កម្ពុជាប្រជាធិបតេយ្យតំណាងឲ្យនៅ-- ដែលបំពេញភារកិច្ចនៅក្រៅប្រទេស។ ទូតជំនាន់សម័យរាជរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ គេប្រមូលចូលក្នុងស្រុក។ ហើយខ្ញុំបានជូនឧទាហរណ៍មួយហើយ គឺ ហួត សម្បត្តិ បន្ទាប់ពីមួយរយៈមក ក៏បញ្ជូនទៅស-២១ ឈ្មោះផ្សេងទៀតខ្ញុំភ្លេច។ ក៏ប៉ុន្តែដោយឡែក ទូតដែលជាសាច់ ជាឈាមរបស់កម្ពុជាប្រជាធិបតេយ្យខ្លួនឯង ដែលបញ្ជូនទៅបរទេសក៏ត្រូវហៅមកដែរ។ ឈ្មោះដែលនៅខ្ញុំចាំ-- ដែលខ្ញុំនៅចាំគឺ មាឃ ទូច និង ហេង សុខឃាង ក៏បញ្ជូនមកដែរ។ នេះសូមនិយាយតែប្រភេទពីរនេះ មនុស្សរបស់ក្រសួងការបរទេសគឺអ៊ីចឹង។ ឯចំណែកក្រៅពីនោះ គឺភ្នាក់ងាររបស់ក្រសួងការបរទេស ដែលបំពេញភារកិច្ចផ្សេងទៀត។ បញ្ញាជនសំខាន់មានពីររូប ដែលបញ្ជូនទៅស-២១ គឺ ចៅ សេង នេះមួយ និង វ៉ាន់ ពីនី នេះពីរ។ នេះខ្ញុំនៅចាំ។ ក្រៅពីនោះមានច្រើន ដែលខ្ញុំមិនចាំ។ សូមអរគុណ។ សូមបញ្ចាក់ជូនប៉ុណ្ណេះ។

[១១:១៥:៥៣]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមបន្តសំណួរទៅលោកថែមទៀត។ សហព្រះរាជអាជ្ញាលោកបានបង្ហាញលោកនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី ទាំងអស់ដែលលោកបានធ្វើក្នុងរយៈពេលប៉ុន្មានឆ្នាំមកហើយនោះ។ ក្នុងចំណោមកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំងហ្នឹងមានកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលមានលេខឯកសារ E3/107 ដែលជាកិច្ចសម្ភាសលើកទី២៤ របស់លោក។ ក្នុង

នោះតើលោកមានដែលបានអាន ឬក៏នៅចាំខ្លះទេ កំណត់ហេតុស្តាប់ចម្លើយសាក្សី មានន័យថាកាលលោកឆ្លើយនៅចៅក្រមស៊ើបអង្កេត កំណត់ហេតុលើកទី២៤ ដែលនិយាយអំពីទំនាក់ទំនងលោក អៀង សារី បញ្ជូនលិខិតទាក់ទងនានាទៅមន្ទីរសន្តិសុខ ស-២១?

[១១:១៧:១៦]

ខ្ញុំសូមជម្រាបជូនឯកសារដែលមានលេខ E3/107 លេខ ERN 00197970។ ខ្ញុំសូមជូនឯកសារនេះទៅសាក្សី ដើម្បីឲ្យគាត់ពិនិត្យមើលខ្លួនគាត់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ហុង គីមសួន៖**

**ស៖** សូមលោកពិនិត្យមើលក្នុងខ្ញុំគូសរង្វង់ ក្នុងប៊ិក *ហៃឡៃ* ចំណាំ!

**ប្រធានអង្គជំនុំ៖**

លោកមេធាវី តើចុះភាសាបរទេស ភាសាពីរផ្សេងទៀត អង់គ្លេស និងបារាំង? អាចផ្តល់នូវលេខទំព័របានដែរឬទេ ដើម្បីឲ្យភាគីពាក់ព័ន្ធផ្សេងទៀត ទាំងអស់ជំនុំជម្រះផង ដែលមិនអាចមើលអានភាសាខ្មែរបានហ្នឹង គាត់អាចមើលឃើញ ឬក៏រកឃើញដោយខ្លួនឯងបាន?

[១១:១៨:៥៤]

**លោក ហុង គីមសួន៖**

បាទ សូមអរគុណលោកប្រធាន។ នៅក្នុងឯកសារជាភាសាអង់គ្លេស ERN 00198219 ហើយខ្មែរ 00197970 ខ្ញុំបាទឥតមានជាភាសាបារាំងទេបាទ។

**ស៖** សូមលោកកាំង ហ្កេកអ៊ាវ ពិនិត្យមើលក្នុងខ្ញុំគូសរង្វង់នៃភាសាខ្មែរហើយតើលោកមានជាមតិយ៉ាងម៉េចបាទ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ ព្រឹត្តិការណ៍នេះខ្ញុំចងចាំរហូត ប៉ុន្តែបើនិយាយពីលិខិតទាក់ទងរបស់ អៀង សារី មកស-២១ គ្មានទេ។ ប៉ុន្តែបើនិយាយពីព្រឹត្តិការណ៍នេះ ខ្ញុំចងចាំរហូត។ ដូច្នេះសរុបមកវិញ គឺខ្ញុំសូមអនុញ្ញាតលោកប្រធាន សូមលោកមេធាវីមេត្តាសួរសំណួរឲ្យចំបញ្ហា។

[១១:២០:២០]

**ស៖** បាទ សូមអរគុណ។ នេះគឺទាក់ទងជាមួយនឹងការងារពីមជ្ឈិមបក្ស ឬអចិន្ត្រៃយ៍បក្សមកតាមឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា។ សំណួររបស់ខ្ញុំអម្បាញ់មិញសួរថា តើការដឹង ឬក៏ការនៅចងចាំរបស់លោកទាក់ទងនឹងការទំនាក់ទំនងរវាងលោក អៀង សារី បញ្ជូនលិខិតនានាទាក់ទងនឹងអ្នកទោសនៅមន្ទីរសន្តិសុខស-២១ នោះ គឺមានន័យថា មុនពេលដែលបញ្ជូនអ្នកទោសដែលជាមនុស្សនៅក្នុង--

[១១:២១:១០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន និងសូមអភ័យទោសលោកមេធាវី ខ្ញុំសូមរំខាន គឺថា នេះគឺជាអង្គហេតុ មិនមែនជាភស្តុតាងទេ ប៉ុន្តែដូច្នេះគឺត្រូវតែសួរទាក់ទងទៅនឹងអ្វីដែលនៅក្នុងករណីនេះ គឺបើយើងនិយាយពីកំណត់ហេតុពីមុននឹងមិនទាក់ទងទេ។ ហើយខ្ញុំសូមជំទាស់ដោយសារថា បើសិនជាយើងប្រើវិធីសាស្ត្រនេះគឺថានៅក្នុងឯកសារមិនអាចប្រើបានទេ។ ហើយមិនមានសេចក្តីសន្និដ្ឋានណាដែលអាចនឹងឯកសារនេះមកប្រើទេ ដូច្នេះបើសិនជាមេធាវីស្នើបែបនេះគឺមិនសមស្រប។ ហើយសាក្សីបានកែតម្រូវ ហើយយើង-- គាត់ថាគាត់មិនបានទទួលអ្វីទេ ហើយបើមេធាវីបន្តសួរបែបនេះគឺថា ខ្ញុំយល់ថាអាចនឹងសួរឡើងវិញឲ្យច្បាស់ ឬក៏សួរសំណួរថ្មី។ ពីព្រោះថា បើយើងៗយោងទៅរកអង្គហេតុដែលមិនមែនជាភស្តុតាង អាហ្នឹងគឺថាមិនជាត្រឹមត្រូវទេ។ ប៉ុន្តែយើងនិយាយទីនេះគឺឲ្យសាក្សីគាត់ផ្តល់សក្ខីកម្មជាភស្តុតាង។

[១១:២២:២៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ការកត់សម្គាល់ និងជំទាស់នេះសូមមេធាវីទទួលសិទ្ធិរៀបចំនូវការតាំងសំណួរឲ្យបានជាក់ច្បាស់ ហើយត្រឹមត្រូវ។ ចៀសវាងការមិនជាក់ច្បាស់ ឬក៏មានការច្របូកច្របល់ នាំឲ្យឈានទៅដល់ការជំទាស់ ឬក៏សាក្សីមិនអាចឆ្លើយរួចនឹងសំណួរដែលលោកតាំងសួរនោះឡើយ។ ដូចសាក្សីបានបញ្ជាក់ហើយអំមិញថា សូមឲ្យលោកមេធាវីតាំងសំណួរឲ្យបានត្រឹមត្រូវ ហើយនិងជាក់

ច្បាស់ ដែលនឹងអាចយល់ ហើយនិងអាចឆ្លើយតបបាន។

[១១:២៣:០០]

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទនឹងដូរសំណួរ។

**សួរដោយ លោក ហុង គឹមសួន៖**

**ស៖** លោក កាំង ហ្គេកអ៊ាវ ខ្ញុំសូមសួរលោកបន្តទៅទៀត។ នៅសប្តាហ៍មុន លោកបានជម្រាបជូនអង្គសវនាការហើយថា ការសម្រេចចាប់ ឬក៏បញ្ជូនជនណាមួយ ដែលនៅក្នុងអង្គភាពណាមួយនោះគឺមជ្ឈិមជាអ្នកសម្រេច តើអ៊ីចឹងមែនទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន រឿងសម្រេចចាប់ គឺពិតជាមជ្ឈិមសម្រេចនេះនិយាយទូលាយ។ ក៏ប៉ុន្តែបើនិយាយឲ្យចំគឺ បងប៉ុល ជាអ្នកសម្រេច នៅក្នុងករណីខ្លះ បងនួន ជាអ្នកសម្រេច។

[១១:២៣:៥២]

**លោក ហុង គឹមសួន៖**

បាទ សូមអរគុណ។ អ៊ីចឹងត្រឡប់មកវិញ ដោយឡែកក្រសួង ឬមន្ទីរនានាដែលនៅជុំវិញមជ្ឈិម។ ខ្ញុំចង់សុំអនុញ្ញាតលោកប្រធាន សូមបង្ហាញឯកសារដែលលោកព្រះរាជអាជ្ញាបានបង្ហាញពីសប្តាហ៍មុនទៅឲ្យសាក្សី ហើយខ្ញុំបាទបង្ហាញតែទំព័រទីមួយឡើងវិញ គឺឯកសារ IS6/3 ដែលមានលេខ ERN ភាសាខ្មែរ 00003136 ហើយនៅក្នុងភាសាអង់គ្លេសលេខ-- សូមទោស ភាសាអង់គ្លេស។ សូមភ័យទោសលោកប្រធាន។ បាទ ជម្រាបជូនអម្បាញ់មិញនេះឯកសារ--

**ប្រធានអង្គជំនុំ៖**

បើកក្បាលមីក្រូហើយ សឹមនិយាយ។

**លោក ហុង គឹមសួន៖**

បាទ សូមអភ័យទោស។ ឯកសារ IS6.3 ENR ជាភាសាខ្មែរ 00003136 ហើយERN ជាភាសាអង់គ្លេស 0-- សូមទោស។ សូមទោស លោកប្រធាន ដោយសារមើលទៅលេខ វាច្រឡំគ្នា។ ERN អង់គ្លេសលេខ0ពីរដង មានន័យថា 00182814។ តើខ្ញុំបាទ ខ្ញុំសូមអនុញ្ញាតជូនទៅលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

លោកសុំអ្វីខ្លះហ្នឹង? សូមបញ្ចាំងឯកសារនៅលើអេក្រង់ទូរទស្សន៍ទេ?

**លោក ហុង គីមសួន៖**

បាទ មានបញ្ចាំងឯកសារនៅលើអេក្រង់ទូរទស្សន៍ និងបញ្ជូនឯកសារទៅ--

**ប្រធានអង្គជំនុំ៖**

សូមម្តងទៀតមើល៍ លោកមេធាវីសុំម្តង ឲ្យច្បាស់ ស្រួលអង្គជំនុំជម្រះសម្រេច។ ជួនកាល អង្គជំនុំជម្រះសម្រេចហួសពីសំណើសុំរបស់ខ្លួន។ ប្រសិនបើលោកមេធាវីមិនបញ្ជាក់ច្បាស់លាស់ទេ។

[១១:២៦:៤៥]

**លោក ហុង គីមសួន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមអនុញ្ញាតសូមបញ្ចាំងឯកសារនេះ លើអេក្រង់ទូរទស្សន៍ និងសូមជូនឯកសារទៅសាក្សីផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីជូនទៅសាក្សីពិនិត្យ ហើយបុគ្គលិកជំនួយការបញ្ចាំងឯកសារនៅលើកញ្ចក់អេក្រង់ទូរទស្សន៍។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** លោកសាក្សី ថាតើលោកបានឃើញឯកសារនៅលើអេក្រង់ទូរទស្សន៍ដែរទេ?

[១១:២៧:៣៨]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំបានឃើញឯកសារនៅលើអេក្រង់ទូរទស្សន៍ ហើយនិងឯកសារដែលប្រគល់មកនៅក្នុងដៃខ្ញុំ។

**ស៖** បាទ សំណួររបស់ខ្ញុំចង់បញ្ជាក់ឡើងវិញបន្តិច ទាក់ទងជាមួយនឹងសេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួនដែលកំពុងបញ្ចាំងជូននេះ។ ខ្ញុំសួរនៅក្នុងចំណុចទីមួយ ដែលនិយាយអំពីសិទ្ធិសម្រេចកម្មេចក្នុងជួរ និងក្រៅជួរ។ តើ លោកធ្លាប់បានអាន ឬក៏ធ្លាប់បានជ្រាបអំពីន័យនៃឯកសារនេះ ក្នុងទំព័រទីមួយនេះ ស្តីអំពីចំណុចទីមួយ សិទ្ធិសម្រេចកម្មេចនេះដែរទេ?

[១១:២៨:២៦]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ក្នុងការអនុវត្តជាក់ស្តែង ខ្ញុំបាទផ្ទាល់ធ្លាប់តែគោរពសេចក្តីសម្រេចរបស់អចិន្ត្រៃយ៍ភាគ ចាប់តាំងពីឆ្នាំ១៩៧១ រហូតមក។ នេះ-- វាជាឯកសារនេះវាបន្តទេ បន្តក្រោយ១៧ មេសា ១៩៧៥ (ស៊ីក) ដោយសារមានឯករាជ្យ-- មានអំណាចគ្រប់គ្រងទូទាំងប្រទេសហើយ វាមានស្ន៊ីផ្សេងទៀតលើសអំពីអចិន្ត្រៃយ៍ភាគ។ ដូច្នេះ អា"បីខ"ខាងក្រោយនេះ វាបន្ថែមក្រោយមកទេ។ បន្ថែមក្រោយនៅថ្ងៃ៣០ មីនា ១៩៧៦។

**ស៖** បាទសូមអរគុណ។ ពីព្រោះសំណួរខ្ញុំ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១១:២៩:៣០]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណ លោកប្រធាន។ ហើយសូមអភ័យទោស លោកមេធាវីសួរសំណួរជាក់លាក់ហើយ។ គាត់មក គាត់បន្ត គាត់បង្ហាញភស្តុតាងអ្វីទៀត ចង់ឲ្យសាក្សីបង្ហាញ? ហើយសាក្សីមិនឆ្លើយដូច្នេះហើយធ្វើឲ្យយើងមានការលំបាកថាត្រូវជំទាស់ ឬមិនជំទាស់នោះ។ សំណួរសួរថាតើលោកបានគិត? ហើយគាត់មិនបានឆ្លើយទេ ហើយៗសាក្សីបានសហការជាមួយលោកមេធាវីហើយ ដើម្បីឲ្យគាត់ទៅមួយជំហានម្តង ដើម្បីធ្វើម៉េចកុំឲ្យខ្ញុំអាចនឹងសង្ស័យ ហើយខ្ញុំជំទាស់។ បើមិនអ៊ីចឹងទេ ខ្ញុំជំទាស់អាចជាការរំខានដល់សាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បញ្ហាមានពីរ។ ទីមួយ ការកត់សម្គាល់របស់យើងឃើញថា មេធាវីគួរតែត្រូវបានពិនិត្យ និងចៀសឲ្យផុតពីសំណួរច្រំដែល ដែលតំណាងសហព្រះរាជអាជ្ញាបានសួររួចហើយ អំពីលិខិត ឬក៏ឯកសារនេះ ដែលមុននឹងដាក់ដេញដោលដោយសហព្រះរាជអាជ្ញា គឺបានសួរអំពីការឃើញ ការដឹង ការធ្លាប់បានអាននូវឯកសារនេះ នៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏ក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យ និយាយរួម គឺមុនពេលកោះហៅសាក្សីមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនេះ ដើម្បីសម្រេចថាតើដាក់ឯកសារនៅចំពោះមុខសាក្សី ដើម្បីដេញដោល ឬយ៉ាងណា? បញ្ហានេះយើងបានដោះស្រាយគ្នាយ៉ាងតឹងតែង ហើយបានដោះស្រាយបានជ្រះស្រឡះហើយ។ ដូច្នេះ សំណួរបញ្ជាក់របៀបនេះ អង្គជំនុំជម្រះយល់ថា មិនចាំបាច់សួរថា ពីព្រោះសំណួរច្រំដែល។

[១១:៣១:០៩]

បញ្ហាទីពីរ សូមសាក្សីត្រូវត្រាប់ស្ដាប់នូវខ្លឹមសារ និងគោលបំណងនៃការតាំងសំណួររបស់ភាគីជាពិសេសមេធាវី។ អម្បាញ់មិញនេះ គឺមេធាវីជាតិ អឺ!តំណាងឲ្យមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតាំងសំណួរ តាំងសំណួរពាក់ព័ន្ធជាមួយនឹងការដឹង ការបានឃើញ ធ្លាប់បានឃើញ ធ្លាប់បានដឹង ធ្លាប់បានអាននូវឯកសារនេះ ដែលសំណួរនេះសហព្រះរាជអាជ្ញាបានសួររួចហើយ។ ប៉ុន្តែទោះបីយ៉ាងណា គឺសាក្សីអាចឆ្លើយតបថា បានឆ្លើយរួចហើយ ឬក៏ឆ្លើយតាមសំណួរដែលសួរ ហើយជំនួសបញ្ហាដែលលោកសួរអម្បាញ់មិញនេះ គឺជារឿងសំណួរទំនងជាខាងមេធាវីមិនទាន់បានសួរទេ។ គឺសួរគ្រាន់តែបញ្ជាក់អំពីទម្រង់នៃឯកសារនោះធ្លាប់បានឃើញ បានដឹងពីមុនមកដែលតំណាងសហព្រះរាជអាជ្ញាបានសួររួចហើយ។ អង្គជំនុំជម្រះសង្ឃឹមថា ភាគីពាក់ព័ន្ធ ហើយនិងសាក្សីនឹងផ្ដល់នូវការស្ដាប់សំណួរ ហើយនិងឆ្លើយឲ្យត្រូវនឹងសំណួរ ហើយចៀសវាងនូវការសួរដេញដោលតាំងសំណួរឯណាដែលច្បាប់ហាមឃាត់ សំណួរច្រំដែល សំណួរដឹកមុខ សំណួរឧបមាណវិធី សំណួរក្រៅអង្គហេតុ ឬក៏សំណួរដែលមិនពាក់ព័ន្ធជាដើម។

សូមអញ្ជើញ!

[១១:៣២:៣៣]

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមអរគុណ ដែលលោកប្រធានជម្រាបជូនភាគីដូចអ្វីដែលខ្ញុំបាទរំពឹងទុកថានឹងសួរ។ តាមពិតខ្ញុំបាទបានជម្រាបជូនហើយ ថាឯកសារនេះ គឺសហព្រះរាជអាជ្ញាបានបង្ហាញហើយ ហើយខ្ញុំបាទសួរគាត់ដើម្បីរំឭកឡើងវិញ និងឈានទៅដល់សំណួរមួយទៀត។ សូមអរគុណលោកប្រធាន។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** លោកសាក្សីដោយថា ការពន្យល់លោកប្រធានអម្បាញ់មិញ ហើយលោកមេធាវី គាត់ចង់ឲ្យលោកឆ្លើយឲ្យជាក់លាក់។ តាមពិតទៅ គឺលោកបានឆ្លើយច្រើនដងហើយ អ៊ីចឹងលោកមិនចាំបាច់ទៀត លោកប្រធានសម្រេចហើយ។ សំណួររបស់ខ្ញុំបន្តគឺចង់សួរថា ប្រជាជនខ្មែរ ឬក៏យើងហៅថាបញ្ញាជនដែលតែងតែលោកបានមានប្រសាសន៍នោះ ដែលបញ្ជូនពីបរទេសចូលមកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានន័យថាចូលមកក្នុងប្រទេសកម្ពុជាវិញ។ តើជនទាំងនោះត្រូវតែឆ្លងកាត់ការដឹងឮ

ពីក្រសួងការបរទេសដែរឬទេ បើតាមលោកដឹងនៅក្នុងរបបនោះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអាចឆ្លើយបានត្រឹមតែជាគោលការណ៍នៃការងារ ទូតដែលមកពីបរទេស វាស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងការបរទេស។ ក៏ប៉ុន្តែក្រសួងការបរទេសនេះ វាស្ថិតនៅក្រោមការគ្រប់គ្រងរបស់លេខា និងអនុលេខបក្ស។ នេះខ្ញុំសូមបញ្ជាក់ជូនជាគោលការណ៍ប៉ុណ្ណេះ។

[១១:៣៤:១៤]

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកបន្តទៅទៀត ដោយសារលោកបានឆ្លើយជូនអង្គសវនាការហើយ។ ទាក់ទងជាមួយនឹងអ្នកដែលត្រូវបានបញ្ជូនពីបរទេសចូលមកដល់មន្ទីរស-២១ ដដែល។ លោកមាននៅចងចាំបានទេ ដែលលោកបានធ្លាប់ឆ្លើយពីមុនមក។ ខ្ញុំបាទនឹងជម្រាបជូនទាក់ទងទៅនូវឯកសារដូចតទៅនេះ។ ហើយខ្ញុំបាទសូមអនុញ្ញាតលោកប្រធាន ជូនឯកសារលោកសាក្សីជាមុន ទើបខ្ញុំបាទនឹងសួរគាត់តាមក្រោយទៀតបាទ គឺឯកសារលេខ D120។ បាទ ខ្ញុំបាទសូមអនុញ្ញាតបញ្ចាំងនៅលើអេក្រង់ទូរទស្សន៍ផងដែរ។ ឯកសារ D120 ជាភាសា ខ្មែរ ហើយដែលមានលេខ ERN 00242920, ERN ជាភាសាអង់គ្លេស 00242931។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ហើយមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីជូន យកជូនទៅសាក្សី ហើយនិងជំនួយការបញ្ចាំងឯកសារនៅលើកញ្ចក់អេក្រង់ទូរទស្សន៍!

**សួរដោយលោក ហុង គីមសួន៖**

**ស៖** សូមលោកសាក្សីពិនិត្យមើលឯកសារនៅលើអេក្រង់ដែលមានគូសរង្វង់ពណ៌ក្រហម។ នេះជាភាសាខ្មែរ សូមលោកពិនិត្យ ហើយនិងលោកមានជាយោបល់ឡើងវិញ។

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** លោកសួរថាម៉េច?

**ស៖** បាទសូមអរគុណ។ ខ្ញុំភ្លេចគិតលោកកំពុងពិចារណាមើលលើឯកសារ។

**លោក ហុង គីមសួន៖**

សូមអនុញ្ញាតលោកប្រធាន ឲ្យលោកសាក្សីគាត់អាននៅក្នុងរង្វង់ ពណ៌ក្រហមតែម្តងបាទ។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** "ខ្ញុំសូមបញ្ជាក់ថា ខ្ញុំនៅឆ្ងាយពី អៀង សារី ណាស់ ហើយខ្ញុំបានឃើញគាត់តែពីរដងទេ។ ដូចដែលខ្ញុំបាននិយាយកន្លងមក ប៉ុន្តែខ្ញុំអាចអះអាងថា តាមគោលការណ៍នៃទម្លាប់ការងារមុននឹងមានការចាប់ខ្លួននៅក្រសួងការបរទេស សេចក្តីសម្រេចពី អៀង សារី ជាការចាំបាច់។ មានករណីលើកលែងតែមួយគត់ ដែលខ្ញុំបាននិយាយរួចហើយ គឺករណីរបស់ ចៅ សេង ដែលត្រូវចាប់ខ្លួនក្រោមឈ្មោះមួយទៀត ដោយ អៀង សារី មិនដឹងទេ។ ខ្ញុំបានទទួលបញ្ជីឈ្មោះអ្នកដែលត្រូវចាប់ខ្លួនមុនពេលដែលពួកគេ មកដល់ស-២១"។

[១១:៣៨:២៥]

"ខ្ញុំបានទទួលបញ្ជីឈ្មោះអ្នកដែលត្រូវចាប់ខ្លួនមុនពេលពួកគេមកដល់ស-២១ រហូតដល់ថ្ងៃទី ១៥ ខែសីហា ឆ្នាំ១៩៧៧ បញ្ជីនេះបានត្រូវផ្តល់មកឲ្យខ្ញុំដោយ សុន សេន ហើយក្រោយមកគឺ ដែលទូទៅ ប៉ង់ ជាអ្នកបញ្ជូនមកឲ្យខ្ញុំ ហើយពេលនោះគឺ លីន"។ អរគុណ។

**លោក ហុង គីមសួន៖**

សូមអរគុណបាទ។

បាទសូមអនុញ្ញាតលោកប្រធាន សូមជូនឯកសារមួយទៀតទៅលោកសាក្សី ដែលជាប្រតិចារឹកដែលមាន D288/4.65.1 ហើយដែលជាឯកសារប្រតិចារឹកក្នុងសំណុំរឿង០០១ ធ្វើនៅថ្ងៃ១៩ ខែសីហា ឆ្នាំ២០០៩ នៅក្នុងទំព័រទី៥៦។ សូមបញ្ចាំងលើអេក្រង់ទូរទស្សន៍ និងជូនឯកសារទៅគាត់បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីយកទៅជូនសាក្សីពិនិត្យ ហើយនិងជំនួយការបញ្ចាំងឯកសារនៅលើកញ្ចក់អេក្រង់ទូរទស្សន៍តាមសំណើសុំរបស់មេធាវី។

[១១:៤០:០៣]

**លោក ហុង គីមសួន៖**

ខ្ញុំបាទ សូមអនុញ្ញាតលោកប្រធាន ឲ្យសាក្សីអានត្រង់ចំណុចដែលខ្ញុំបាទជូនទៅគាត់ ដែលគូសបង្ហាញរួចហើយបាទ។

**ប្រធានអង្គជំនុំ៖**

មិនទាន់ឃើញឯកសារនៅលើអេក្រង់ទូរទស្សន៍ទេ។ ហើយបញ្ជាក់លេខជាភាសាអង់គ្លេស

ERN ជាភាសាអង់គ្លេសផង ដើម្បីភាគីពាក់ព័ន្ធពិនិត្យ។ យ៉ាងហោចណាស់ក៏ភាសាអង់គ្លេសដែរ បើមិនមានភាសាបារាំង។

[១១:៤២:០៦]

**លោក ហុង គីមសួន៖**

សូមទោសលោកប្រធាន។ ដោយសារខាងបច្ចេកទេសបញ្ចាំងភាសាអង់គ្លេស មិនទាន់ពេលវេលា តើខ្ញុំបាទអនុញ្ញាតអានជាភាសាខ្មែរជូនបានទេ បាទ?

**ប្រធានអង្គជំនុំ៖**

ឲ្យលេខ ERN ដើម្បីឲ្យភាគីដែលប្រើប្រាស់ភាសាផ្សេងទៀតហ្នឹង គាត់ស្ដាប់បាន ហើយគាត់អាចបើកមើល រកមើលដោយខ្លួនឯងបាន។ យើងខ្ញុំបានជម្រាបរួចហើយថា ការរៀបចំបង្ហាញឯកសារដេញដោលនៅក្នុងដំណើរការនេះ ត្រូវតែរៀបចំទាំងបីភាសា។ យ៉ាងហោចណាស់ក៏ពីរភាសាដែរ ក្នុងករណីពុំមានការបកប្រែភាសាបារាំង។ ត្រូវតែត្រៀមជាមុនឲ្យស្រេច ដើម្បីសន្សំពេលវេលាក្នុងការដេញដោល។

[១១:៤៣:០២]

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមសួរសំណួរទៅមួយផ្សេងទៀត ទម្រាំខាងបច្ចេកទេសរកឃើញបាទ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** លោកសាក្សីខ្ញុំនឹងសួរសំណួរលោកមួយផ្សេងទៀត ដោយសារយើងមានពេលវេលាតិចទៀត។ តាមការចងចាំរបស់លោក កាលលោកនៅជាលេខានៃមន្ទីរស-២១ តើលោកស្គាល់ឈ្មោះ ចៅ សេង ដែរទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ឈ្មោះ ចៅ សេង នេះវាជាប់នៅក្នុងអារម្មណ៍ខ្ញុំខ្លាំងណាស់ ដូច្នេះគាត់អញ្ជើញទៅដល់ស-២១ ក៏ខ្ញុំដឹង។ ខ្ញុំនៅចាំរឿងរ៉ាវច្រើន។

**ស៖** សូមអរគុណ។ សូមលោកបញ្ជាក់ជូនអង្គសវនាការបន្តិចថា តើ ចៅ សេង ជាមនុស្សប្រភេទណា ដែលត្រូវបានមជ្ឈិម ឬក៏ខាងអចិន្ត្រៃយ៍ចាប់បញ្ជូនទៅស-២១?

[១១:៤៤:១៩]

**ឆ៖** អរគុណ។ ចៅ សេង នេះ គាត់ជាជនចម្រើនម្នាក់ សកម្មដែរក្នុងសង្គមសីហនុ គាត់ប្រយុទ្ធជាមួយ លន់ នល់ ក្នុងសមាជ។ យើងខ្ញុំស្គាល់ គាត់ជាអ្នកបង្កើតវិទ្យាស្ថានជាតិគរុកោសល្យខាងត្បូង ដើម្បីកសាងសាស្ត្រាចារ្យ។ ដល់ក្រោយមកមានចម្លើយឆ្លើយដាក់ ចៅ សេង បន្ទាប់មកនៅថ្ងៃខែមួយ រវាងខែសីហា ១៩៧៧ សុន សេន ប្រាប់ខ្ញុំថា គេ-- អចិន្ត្រៃយ៍នឹងបញ្ជូន ចៅ សេង ទៅឲ្យ ស-២១ ក៏ប៉ុន្តែដោយសារ ចៅ សេង ល្បីពេកក្នុងអន្តរជាតិ។ ដូច្នេះ ឲ្យខ្ញុំ ឲ្យស-២១ ប្រែឈ្មោះ។ ដូច្នេះ ឈ្មោះ ចិន សួន ហ្នឹងក៏គាត់ជាអ្នកផ្តើមគំនិតឲ្យប្រែ។ នេះចំពោះបញ្ហា ចៅ សេង ដែលចាប់ខ្លួន។ ដល់ក្រោយមកសួរចម្លើយរួចហើយ ខ្ញុំក៏ទុក ចៅ សេង ឲ្យនៅជួយការងារ ព្រោះខ្ញុំ នៅមានជាប់អាឡោះអាល័យនឹងគាត់ខ្លាំងណាស់។ ហើយដល់ក្រោយមកបាន១ ខាងលើសម្រេចឲ្យខ្ញុំកម្ទេច ខាងលើហ្នឹងគឺបងនួន ដែលពេលនោះនៅពេលស៊ើបអង្កេតហ្នឹង ខ្ញុំហៅគាត់ពូ នួន ព្រោះគាត់អាយុតិចជាងម្តាយខ្ញុំទៅទៀត។ គាត់សម្រេចឲ្យខ្ញុំកម្ទេច ចៅ សេង ទៅ។

[១១:៤៦:០៤]

**លោក ហុង គឹមសួន៖**

សូមអរគុណ។ លោកប្រធាន សូមអនុញ្ញាតជូនលេខកូដឯកសារ ដែលខ្ញុំបាទជូនអម្បាញ់មិញគឺ ឯកសារ D288/4.65.1 ERN ជាភាសាអង់គ្លេស 00367432 ទៅដល់លេខ 00367530 ជាភាសាខ្មែរ ERN 00367632 ទៅដល់ 00367708។ ហើយខ្ញុំបាទសូមអនុញ្ញាតឲ្យសាក្សីអាននៅត្រង់ ខ្ញុំគូសនៅឯកសារដាក់ជូន ហើយសូមបង្ហាញលើអេក្រង់តែម្តងទៀតបាទ។

**ប្រធានអង្គជំនុំ៖**

បុគ្គលិកជំនួយការអាចបង្ហាញឯកសារអម្បាញ់មិញនេះ ដែលតាមសំណើសុំរបស់មេធាវីនៅលើកញ្ចក់អេក្រង់ទូរទស្សន៍!

[១១:៤៨:១២]

**សួរដោយលោក ហុង គឹមសួន៖**

សូមអនុញ្ញាតលោកប្រធាន ខ្ញុំបាទសូមតសំណួរទៅមុខ ដោយខាងអ្នកជំនាញរកមិនទាន់បាទ។

**ស៖** លោកសាក្សី ខ្ញុំសូមសួរលោក ក្នុងនាមលោកជាលេខាស-២១ លោកនៅចងចាំបានទេ ទាក់ទងជាមួយនឹងអ្នកទោសឈ្មោះ រស់ សារិន ម្នាក់ទៀត?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំរកនឹកមិនឃើញទេ រស់ សារិន មនុស្សនេះខ្ញុំមិនធ្លាប់ស្គាល់ពីមុនមកទេ។

[១១:៤៨:៥២]

**លោក ហុង គឹមសួន៖**

បាទសូមអនុញ្ញាតលោកប្រធាន ជូនឯកសារទៅសាក្សី ដែលជាឯកសារមិនមែនថា សួរដដែលទេ គ្រាន់តែបង្ហាញគាត់ ព្រោះអីខ្លាចគាត់មិនចាំ ព្រះរាជអាជ្ញាបានបង្ហាញពីសប្តាហ៍មុន។ ឯកសារលេខ ERN 00086716 D108/26.282។ បាទ សូមជូនជា ERN។

សូមទោសលោកប្រធាន។ សូមលោតទៅសំណួរមួយផ្សេង ដោយសារកុំឱ្យខាតពេលការរកឯកសារមិនទាន់ពេលបាទ។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** ខ្ញុំសូមសួរបន្តមួយទៀតទៅលោកសាក្សី ទាក់ទងជាមួយនឹងប្រជាពលរដ្ឋខ្មែរម្នាក់ទៀតដែលជា-- នៅក្នុងសំណុំរឿង០០១ គឺឈ្មោះ អ៊ុក កេត លោកនៅចាំបានទេ? ទាក់ទងនឹងការគ្រប់គ្រងរបស់លោកនៃក្នុងមន្ទីរស-២១?

[១១:៥០:៤០]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន អ៊ុក កេត ខ្ញុំនៅចាំ។ ទាំងប្រពន្ធ អ៊ុក កេត កូន អ៊ុក កេត មកធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅទីនេះផង។ សូមបញ្ចប់ប៉ុណ្ណេះ។

**ស៖** សូមលោកបញ្ជាក់ជូនអង្គសវនាការបន្ថែមបន្តិច ព្រោះថាសំណុំរឿង០០១គឺជារឿងមួយផ្សេងដែលខាងអង្គសវនាការ និងអ្នកតាមដាននៅក្នុងដំណើរការសវនាការហ្នឹងគឺគាត់មិនទាន់បានដឹងទាំងអស់គ្នា។ តើលោកអាចបញ្ជាក់បានទេថា តើ អ៊ុក កេត ដែលលោកបានដឹងជាមនុស្សដែលត្រូវបានបញ្ជូនទៅ ស-២១ នោះតើទាំង រស់ សារិន ទាំងឈ្មោះ ចៅ សេង ជាអ្នកទោសប្រភេទទូទៅធម្មតា ឬក៏ប្រភេទយ៉ាងម៉េចដែរ?

[១១:៥១:៣៦]

**ឆ៖** អរគុណ។ អ៊ុក កេត នេះខ្ញុំមិនស្គាល់ទេពីមុនមក ក៏ប៉ុន្តែខ្ញុំនៅចាំបានច្បាស់ ដោយសារក្នុងសវនាការនោះមានដើមបណ្តឹងរដ្ឋប្បវេណី ដែលជាប្រពន្ធអ៊ុក កេត ហើយនិងកូនក្រមុំ អ៊ុក កេត មកនាង អ៊ុក ណារី។ ហើយពេលនុ៎ង ខ្ញុំបានជម្រាបជូនហើយថា អ៊ុក កេត ត្រូវចូលមក ស-២១ មុន

រយៈពេលខ្ញុំធ្វើលេខា គឺនៅលើ ណាត។ ក៏ប៉ុន្តែខ្ញុំទទួលស្គាល់ថា ពិតជាគ្នាមកស្តាប់នៅក្នុងកន្លែងនុំងមែន។ ឯចំណែកលោក រស់ សារិន ខ្ញុំមិនធ្លាប់ស្គាល់ពីមុនមក។ ដូច្នេះ ខ្ញុំសន្និដ្ឋានថា អ៊ុក កេត និង រស់ សារិន គឺជាអ្នកការទូតរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

[១១:៥២:៣០]

ឯចំណែក ថៅ សេង មនុស្សផ្សេង ជាជនចម្រើន ហើយក៏ប្រហែលជាចូលបក្សនៅស្រុកបារាំងនៅ ម៉ុងពើលីយេ៉ ទៅទៀត។ មនុស្សពីរនាក់នុំងប្លែកគ្នា។ ហើយ ថៅ សេង ទទួលការគោរពពីខ្ញុំ ដោយសារគាត់បង្កើតវិទ្យាស្ថានគរុកោសល្យខាងត្បូង នាំឲ្យមានការកសាងសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ។ នេះខ្ញុំសូមបញ្ចាក់ប៉ុណ្ណេះ។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមសួរលោកបន្តទៅទៀតថា តើលោកនៅចាំបានទេថា ថៅ សេង និង អ៊ុក កេត អ្នកទាំងពីរនេះមុននឹងបញ្ជូនមក ស-២១ តើលោកដឹងថា ថៅ សេង ធ្វើការនៅទីណា ហើយ អ៊ុក កេត ធ្វើការនៅទីណាដែរទេ?

[១១:៥៣:២៧]

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់-- ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមបញ្ជាក់ថា អ៊ុក កេត ខ្ញុំដឹងរឿងអ៊ុក កេត នៅពេលសវនាការសំណុំរឿងលេខ០០១ នេះទេ។ ដូច្នេះ ឯកសារវាផ្តល់គ្រប់គ្រាន់ ហើយបញ្ជូនចេញពីក្រសួងការបរទេស។ ឯចំណែក ថៅ សេង ខ្ញុំដឹង ដោយវាមានចម្លើយទាក់ទងជាហូរហែ ហើយមុននឹងចាប់ ថៅ សេង មេប្រាប់ខ្ញុំ សុន សេន គាត់ប្រាប់ខ្ញុំ។ ដូច្នេះ ចេញពីក្រសួងការបរទេស។

**ស៖** ពាក្យថា ចេញពីក្រសួងការបរទេស មានន័យថា ធ្វើការនៅក្រសួងការបរទេស ដូច្នេះមែនទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន សំណួរនេះត្រឹមត្រូវហើយ។ ចេញពីក្រសួងការបរទេស គឺពីលើកមុនគាត់ធ្វើការនៅក្រសួងការបរទេស។ នេះ ថៅ សេង។ ឯចំណែក អ៊ុក កេត ហើយនិង រស់ សារិន ប្រហែលជាគ្នាមិនបានធ្វើការអីទេ។ ក្រោយ១៧ មេសា គេប្រមូលគាត់ចូលមកនៅពួកមន្ទីរអប់រំសាឡើងវិញ។ នេះខ្ញុំសូមបញ្ចាក់ប៉ុណ្ណេះ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកបន្តទៅទៀតថា នេះគ្រាន់តែជាសំណួររំឭកបន្តិចទេ ព្រោះខ្ញុំបាទបានស្តាប់ពីមុនហើយគ្រាន់តែថា រាល់អ្នកការទូត និស្សិត បញ្ញាជន ដែលឆ្លងកាត់ពីបរទេសចូល

មកក្នុងប្រទេសកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើឈ្មោះអ្នកទាំងអស់នោះត្រូវតែឆ្លងកាត់ក្រសួងការបរទេសទើបមកដល់មជ្ឈិមហើយឆ្លងកាត់មកដល់មេរបស់លោក និងមកដល់លោក តើអ៊ីចឹងមែនទេ?

**ផ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ជាគោលការណ៍នៃការអនុវត្ត គឺអ៊ីចឹង។

**ស៖** សូមអរគុណ។ សំណួរខ្ញុំសួរថា សូមរំឭកបន្តិច លោកបានមានប្រសាសន៍ជូនទៅខាងអង្គជំនុំជម្រះពីសប្តាហ៍មុនទាក់ទងនឹងការចាប់ភូមិភាគបូព៌ា។ មនុស្សនៅក្នុងកងពលនៃភូមិភាគបូព៌ា លោកថា បើសិនជាមេអង្គភាពគេជំទាស់ ឬគេសុំទុក ដូច្នេះថ្នាក់លើមិនយកអ្នកនោះមកទេ តើអ៊ីចឹងមែនទេ?

[១១:៥៦:១៩]

**ផ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន គឺអ៊ីចឹងមែន។ នេះនៅខាងកងទ័ពដែលខ្ញុំឃើញជាក់ស្តែង។

**ស៖** សូមអរគុណ។ ទាក់ទងមកឈ្មោះអ្នកទាំងពីរនាក់ដដែលអម្បាញ់មិញ ដែលខ្ញុំបានជម្រាបសួរលោកគឺ ថៅ សេង ជាមួយនឹង អ៊ុក កេត នេះ។ ដូច្នេះ ការយល់របស់លោក ឬការដឹងរបស់លោកមុននឹងបញ្ជូន ថៅ សេង មក មុននឹងបញ្ជូន អ៊ុក កេត មក គឺត្រូវតែមានការយល់ព្រមពីប្រធាន ឬក៏ក្រសួងការបរទេស តើមែនឬទេ?

**ផ៖** អរគុណ។ បញ្ហាបញ្ជូន អ៊ុក កេត ខ្ញុំអាចជម្រាបថាជាគោលការណ៍បាន ព្រោះខ្ញុំមិនជាក់ស្តែង។ ដោយឡែកចំពោះ ថៅ សេង ខ្ញុំជាក់ស្តែងខ្លាំងណាស់ ប្រហែលជាពេលនោះ អៀង សារី អត់នៅ ដូច្នេះអចិន្ត្រៃយ៍សម្រេចយកតែម្តង។ បញ្ហាមកមេខ្ញុំ ហើយមេខ្ញុំបញ្ហាមកឲ្យខ្ញុំឲ្យរៀបចំកន្លែងចាំទទួល ដូច្នេះក្នុងករណី ថៅ សេង មួយ គឺ អៀង សារី អត់នៅទេ។

**ស៖** បាទ សូមអរគុណ។

[១១:៥៧:៤៥]

**លោក ហុង គីមសួន៖**

លោកប្រធាន ដោយសារពេលវេលាដល់ពេលសម្រាកហើយ តើនឹងសម្រាកសិន ឬបន្តទៅទៀតបាទ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំ

ជម្រះប្រកាសសម្រាកត្រឹមនេះ ហើយនិងសវនាការលើកបន្តទៅធ្វើនៅរសៀលនេះចាប់ផ្តើមពីម៉ោងមួយកន្លះ។ ហើយអនុរក្សមន្ទីរឃុំឃាំងអញ្ជើញសាក្សីទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅរសៀលនេះឲ្យបាននៅម៉ោងមួយកន្លះ។

សូមអញ្ជើញលោកមេធាវី!

[១១:៥៨:៣១]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណ លោកប្រធាន។ កូនក្តីរបស់ខ្ញុំចង់ទៅតាមដានពីបន្ទប់ខាងក្រោម ដើម្បី-- សម្រាប់ពេលល្ងាចនេះ បន្ទាប់ពីសវនាការនេះទៅលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ដោយសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ពីបន្ទប់មួយនៅខាងក្រោមបន្ទប់សវនាការនេះសម្រាប់រយៈពេលរសៀលនេះ ពេញមួយរសៀល ដោយលះបង់សិទ្ធិមិនចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការនៅរសៀលនេះ ដោយគាត់លះបង់សិទ្ធិមិនចូលរួមកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្តី នួន ជា ត្រូវប្រគល់មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ នួន ជា ហើយនិងបង្គាប់ឲ្យផ្នែកខាងសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ឲ្យជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រសៀលនេះ។

[១១:៥៩:៥០]

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយរសៀលនេះសូមបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំតែជនជាប់ចោទ ខៀវ សំផន មកកាន់បន្ទប់សវនាការឲ្យបានមុនម៉ោងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញ ក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០០ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:២១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលសិទ្ធិពីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ហុង គីមសួន៖**

សូមជម្រាបលោកប្រធាន ខ្ញុំបាទអស់សំណួរសួរហើយ ប៉ុន្តែបន្តទៅទៀត សូមឲ្យលោកប្រធានអនុញ្ញាតមេធាវីសហការី កញ្ញា លី ម៉ាញៀន តាំងសំណួរសួរទៅសាក្សីបន្តទៀតបាទ។ សូមអរគុណ។

[១៣:៣៤:២០]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញកញ្ញា!

**កញ្ញា លី ម៉ាញៀន៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ជាទីគោរព ហើយនិងសាក្សី ហើយនិងសាធារណជន ភាគីទាំងអស់។ លោក លោកស្រីចៅក្រម មុននឹងខ្ញុំចាប់ផ្តើម ខ្ញុំគិតថា អាចនឹងមានប្រយោជន៍ដើម្បីសុំបំភ្លឺ ថាតើដើមបណ្តឹងរដ្ឋប្បវេណីនៅមាន សល់ម៉ោងប៉ុន្មាន? ហើយយើងគប្បីប្រើប៉ុន្មាន? ខ្ញុំបានយល់ថា យើងមានម៉ោងប្រាំមួយ-- ប្រាំមួយម៉ោងក្នុងមួយថ្ងៃ។ យើងបានផ្តល់មួយម៉ោងជូនទៅសហព្រះរាជអាជ្ញា ហើយយើងសល់ប្រាំម៉ោង។ មួយម៉ោងបានប្រើដោយលោកមេធាវី សហមេធាវីខ្ញុំហើយ ប៉ុន្តែយើងនៅសល់ពីរម៉ោងកន្លះនៅល្ងាចនេះ។ ហើយអ្វីដែលខ្ញុំយល់នោះ គឺថាយើងមិនបានមានមួយម៉ោងកន្លះទេ នៅថ្ងៃស្អែក ហើយយើងអាចនឹងបញ្ចប់ត្រឹមតែពេលមុនសម្រាកទីមួយ។ ខ្ញុំសូមតុលាការបញ្ជាក់ពីបញ្ហានេះ មុននឹងខ្ញុំចាប់ផ្តើមសំណួរនៅថ្ងៃនេះ។ សូមអរគុណ។

[១៣:៣៥:២៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក-- លោកៗមេធាវីការពារក្ដីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន។ សូមអរគុណ។ តុលាការយើងប្រគល់សិទ្ធិសម្រេចទៅតុលាការ ប៉ុន្តែយើង-- ឥឡូវនេះ យើងបានបួនថ្ងៃ ឥឡូវនេះ យើងចាប់ម៉ោង ដូច្នេះគឺថាជាវិធីមួយ ប៉ុន្តែមិនជាដំណើរការនោះទេ។ យើងមិនបាន-- យើងបានឲ្យមួយម៉ោងទៅសហព្រះរាជអាជ្ញាហើយ តើមេធាវីចង់បានប៉ុន្មាននោះ? គឺថាដូច្នេះ បើសិនណាមួយម៉ោងកន្លះស្អែកទៀត ដើម្បីបន្ថែមគឺថាដើម្បីបំពេញមួយម៉ោងដែលបាត់ព្រឹកនេះ។ ប៉ុន្តែដែលទាក់ទងទៅនឹងគណិតវិទ្យាដែលយើងបានគណនាម៉ោងនោះ គឺថាដូច្នេះមេធាវីដូចស្នើសុំមួយថ្ងៃ ហើយបានផ្ដល់មួយម៉ោងទៅផ្សេង ហើយឥឡូវនេះ ប្រើពេលថ្ងៃនេះ ហើយបើសិនជាតុលាការអនុញ្ញាត គឺចង់បានមួយម៉ោងបន្ថែមសម្រាប់ស្អែកនោះទៀតនោះ។ ប៉ុន្តែអ្វីដែលថាបន្ថែមលើសពីអ្វីដែលបានសម្រេចពីមុននោះ ដូចជាច្រើនពេកសម្រាប់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។

[១៣:៣៦:៣៥]

**កញ្ញា លី ម៉ាញឿន៖**

តាមដែលខ្ញុំយល់ គឺថាមួយថ្ងៃពេញនោះ គឺថាប្រាំមួយម៉ោង។ ដូច្នេះ ការគណនាយើងបានធ្វើហើយ ដើម្បីជួយដល់តុលាការ។ លោក លោកស្រីចៅក្រម មិនចាំបាច់ឆ្លើយពេលនេះទេ ប៉ុន្តែរហូតដល់ចុងម៉ោងនេះ យើងខ្ញុំចង់បានការបំភ្លឺពីបញ្ហានេះ។ ឆ្លើយតប--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនឆ្លើយទេ គឺអង្គជំនុំជម្រះផ្ដល់ឱកាសគឺពេញមួយរសៀលនេះ ត្រឹមម៉ោងបួនចប់។ ស្អែក គឺត្រូវប្រគល់វេនដល់អង្គជំនុំជម្រះ និងសួរបន្តិចបន្តួច ហើយនិងផ្ដល់ឲ្យទៅភាគីការពារក្ដីសម្រាប់សួរដេញដោលសាក្សីរូបនេះ បីថ្ងៃ។

**កញ្ញា លី ម៉ាញឿន៖**

សូមអរគុណលោកប្រធានដែលបានបំភ្លឺ។

[១៣:៣៧:២៥]

**ស្តួរដោយកញ្ញា លី ម៉ាញៀន៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ មុននឹងខ្ញុំចាប់ផ្តើមសួរទៅលោក ប្រហែលថាខ្ញុំស្នើសុំឱ្យលោកដោយឆ្លើយឱ្យជាក់លាក់ខ្លីៗតាមដែលអាច-- ទៅតាមធ្វើបាន ហើយប្រសិន បើខ្ញុំសូមឱ្យពន្យល់លម្អិតសូមលោកពិពណ៌នាទៅតាមនោះ តើលោកអាចធ្វើបែបនោះបានទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំនឹងគោរពតាមសំណូមពររបស់មេធាវី។

**ស៖** សូមអរគុណលោកសាក្សី។ សាក្សីលោកបាននិយាយពីម្សិលមិញនៅស-២១ គឺជារបស់វរសេនារបស់បក្សកុម្មុយនីស្តកម្ពុជា ថាតើកងពលណាមួយដែលស្ថិតនៅក្នុងផ្នែកនៃកងអាកាសនោះ?

[១៣:៣៨:២៧]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន កងពល៥០២ ជាកងទ័ពអាកាស។

**អ្នកបកប្រែ៖**

មីក្រូហ្វូនរបស់មេធាវីមិនបើក លោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

បើកក្បាលមីក្រូហ្វូន!

**ស្តួរដោយកញ្ញា លី ម៉ាញៀន៖**

**ស៖** សាក្សីនោះ ខ្ញុំសួរថាតើអ្នកណាជាប្រធាននៃកងពល៥០២ នោះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ស៊ូ ម៉េត ជាប្រធានកងពល៥០២។

[១៣:៣៩:១៩]

**ប្រធានអង្គជំនុំ៖**

លោក ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ពីខាងដើមគឺថា គាត់បានស្នើពេលបន្ថែម ឥឡូវនេះ សំណួរគាត់សួរប៉ុន្តែសំណួរនេះ ដូចជាមិនពាក់ព័ន្ធទេ។ សូមឱ្យមេធាវីសួរតែសំណួរទៅទាក់ទងរឿងក្តីនេះ កុំសួរ០០៣, ០០៤។ ដូច្នេះ បើដូច្នោះ លោកស្រីបានប្រាប់មេធាវីលើសពីពេលព្រំដែនដែលបានកំណត់នោះ។

ខ្ញុំសូមស្នើតុលាការថា សូមឲ្យតែទាក់ទងទៅរឿងក្តី០០២/០១ បានហើយ។ សូមអរគុណតុលាការ។

[១៣:៤០:០០]

**កញ្ញា លី ម៉ាញឿន៖**

លោក លោកស្រីចៅក្រម! សំណួររបស់ខ្ញុំគឺទាក់ទងទៅនឹងរឿងក្តី០០២/១ គឺទាក់ទងទៅនឹងរចនាសម្ព័ន្ធ ហើយនិងទំនាក់ទំនង ហើយនិងរចនាសម្ព័ន្ធនៃកងទ័ពបដិវត្តន៍កម្ពុជា។ សំណួរនេះមិនត្រូវតែទាក់ទងទៅនឹងខ្សែទំនាក់ទំនងបណ្តោយទេ ហើយនិងរដ្ឋបាលប៉ុណ្ណោះទេ ក៏ប៉ុន្តែទាក់ទងទៅនឹងខ្សែទទឹងផងដែរ។ ខ្ញុំសូមជម្រាបតុលាការថា គឺជាសំណួរដែលពាក់ព័ន្ធទៅនឹងរឿងក្តីនេះ នៅសវនាការវគ្គនេះ។ ខ្ញុំសូមអនុញ្ញាតបន្តសំណួរ។

**ប្រធានអង្គជំនុំ៖**

មេធាវីគប្បីច្បាស់លាស់ផងដែរ នូវការដែលតាំងសំណួរឲ្យសាក្សីឆ្លើយបុគ្គលជាក់ច្បាស់ ក្រៅពីបុគ្គលមួយចំនួនជាគោលដៅនៃការ-- អង្គជំនុំជម្រះនឹងអញ្ជើញមកធ្វើសក្ខីកម្ម ដែលជាលក្ខខណ្ឌផ្ទុយជាមួយនឹងអនុសញ្ញាស្តីពីការការពារសាក្សី។ សូមរំឭកទេៗ ប្រយ័ត្នប្រយែងបញ្ហានេះ ពីព្រោះអង្គជំនុំជម្រះប្រឹងប្រែងកំណត់នូវរហស្សនាម ហើយអង្គជំនុំជម្រះមិនតម្រូវសាក្សីដទៃទៀត សាក្សីដែលចូលរួមនៅក្នុងកិច្ចដំណើរការសវនាការហ្នឹង គឺឆ្លើយរហស្សនាមទេ ពីព្រោះរហស្សនាមសាក្សីទាំងអស់មិនបានទទួលព័ត៌មាន និងការយល់ដឹងអំពីការកំណត់ឲ្យហៅរហស្សនាមដល់សាក្សី ឬអ្នកជំនាញដែលមកផ្តល់សក្ខីកម្មទេ មានតែភាគីដែលពាក់ព័ន្ធប៉ុណ្ណោះដែលបានយល់ដឹងអំពីបញ្ហាការកំណត់រហស្សនាមដើម្បីហៅជំនួសសាក្សីជាក់លាក់ក្នុងន័យអនុវត្តនូវវិធានការការពារសាក្សី តាមអនុសញ្ញាអន្តរជាតិស្តីពីការការពារសាក្សីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។

[១៣:៤២:០៥]

**កញ្ញា លី ម៉ាញឿន៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំជ្រាបហើយគឺ គាត់បានផ្តល់ភស្តុតាងទាក់ទងទៅនឹងបុគ្គលនេះ គឺនៅក្នុងរឿងក្តី០០១ រួចទៅហើយ។ ដូច្នេះ ភស្តុតាង និងរឿងក្តី០០១ គឺនៅក្នុងសំណុំរឿងទាក់ទងទៅនឹងតួនាទីរបស់បុគ្គលទាំងអស់នេះ។ ខ្ញុំព្យាយាមបង្ហាញភស្តុតាងថា មានទំនាក់ទំនងជាខ្សែសង្វាក់មួយចំនួន ទាក់ទងទៅនឹងបញ្ហានេះ ដែលលោក កាំង ហ្កេកអ៊ាវ គាត់បានដឹង ហើយខ្ញុំមិនដឹងថា

មានបុគ្គលណាផ្សេងដែលបញ្ជាក់នៅក្នុងបញ្ហានេះទាក់ទងទៅនឹងរឿងនេះទេ ហើយមិនទាន់បានកោះហៅសាក្សីរូបនេះទេនៅក្នុងសវនាការវគ្គនេះនោះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៣:៣២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីមេធាវីអាចបន្តសំណួរបានណា! ការជំទាស់របស់មេធាវី ម៉ៃខល កាណាវ៉ាស គ្មានប្រសិទ្ធភាព ប៉ុន្តែសូមរំឭកថាការដេញដោលនៃកិច្ចដំណើរការសវនាការនេះ គឺយើងពិភាក្សាអំពីភស្តុតាងនានាជុំវិញបញ្ហាការចោទប្រកាន់ជាបន្ទុកទៅលើជនជាប់ចោទចំនួនបីរូប ដែលមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះកន្លងមក ដែលអង្គជំនុំជម្រះបានចាប់ផ្តើមប្រកាសបើកសវនាការសំណុំរឿង ០០២/០១នេះ។ អ៊ីចឹងបញ្ហាផ្សេងទៀត មិនមែន-- ត្រូវយល់ថាអ្នកដែលពាក់ព័ន្ធនៅក្នុងការតាំងសំណួរនេះ មិនមែនជាជនជាប់ចោទនៅក្នុងរឿងនេះទេ ក្រែងលោការបង្ហាញភស្តុតាងឈានដល់រកភស្តុតាងដាក់បន្ទុកចំពោះបុគ្គលដែលពាក់ព័ន្ធនឹងសំណួរដែលលោកស្រីបានសួរបញ្ជាក់នេះ។

[១៣:៤៤:៣៦]

**កញ្ញា លី ម៉ាញឿន៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំនឹងព្យាយាមធ្វើដូច្នោះ។ ខ្ញុំបង្ហាញជូនសាក្សីនូវឯកសារមួយ គឺសុំការអនុញ្ញាតពីតុលាការដើម្បីបង្ហាញ។ ឯកសារ D288/5.210។ អង់គ្លេស ERN 00178065, ខ្មែរ ERN00052994។ ខ្ញុំសូមអនុញ្ញាតឲ្យមន្ត្រីតុលាការយកឯកសារទៅបង្ហាញជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការទទួលឯកសារពីមេធាវី យកទៅជូនសាក្សីពិនិត្យ។

**កញ្ញា លី ម៉ាញឿន៖**

សូមមន្ត្រីសំណុំរឿងបង្ហាញឯកសារនៅលើអេក្រង់ផងដែរ លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត! បុគ្គលិកជំនួយការបញ្ចាំងឯកសារលើកញ្ចក់អេក្រង់ទូរទស្សន៍។

[១៣:៤៦:១៦]

**កញ្ញា លី ម៉ាញៀន៖**

**ស៖** លោកសាក្សីសូមមើលឯកសារនៅលើអេក្រង់ ហើយនិងឯកសារនៅលើដៃលោកផងដែរ ថាតើលោកអាចបញ្ជាក់ផងដែរទេ លោកបានឃើញឯកសារនេះពីមុនដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះខ្ញុំឃើញនៅក្នុងរយៈកាលសវនាការសំណុំរឿង០០១។

**ស៖** សូមលោកបញ្ជាក់ជូនតុលាការអំពីលក្ខណៈពិសេសរបស់តុលាការនេះ ថាតើលិខិតនេះជូនអ្នកណា ផ្ញើមកពីណា? ហើយកាលបរិច្ឆេទនៃឯកសារនេះផង។

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន កាលបរិច្ឆេទនៃឯកសារនេះគឺថ្ងៃ០១ ខែមេសា ១៩៧៧ ដែល សុន សេន ឲ្យ ស៊ូ ម៉េត សរសេរឯកសារនេះផ្ញើមកឲ្យខ្ញុំនៅចំពោះមុខគាត់។ ហើយគាត់ឲ្យមកខ្ញុំ គាត់ជាអ្នកឲ្យមកខ្ញុំ។ បញ្ហាអស់នេះខ្ញុំបានជម្រាបនៅក្នុងសវនាការ០០១ រួចអស់ហើយ។

**ស៖** តើលោកអាចសង្ខេបជូនតុលាការបានទេ តើឯកសារនេះនិយាយពីអ្វីខ្លះ?

[១៣:៤៨:១៧]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមអាន (ខ)ទីមួយ អ៎ (ខ)ទីពីរ ទីបី ទីបួន អត់ទេ! (ខ)ទីមួយ និងកថាខណ្ឌលេខបី លេខបួន ដូចតទៅ៖ "ក្រោយពីបានចម្លើយសារភាពរបស់ឈ្មោះ សោម ម៦២ យើងខ្ញុំបានបញ្ជូនមនុស្សទៅស-២១ ដូចតទៅ៖ ១) ឈ្មោះ ផន ប្រពន្ធឈ្មោះ ផល ខ្សែ សោម។ បញ្ជូនថ្ងៃ ៣០ ខែមីនា ១៩៧៧។ ២) ឈ្មោះ សៀ ប្រពន្ធឈ្មោះ ហៀង ក្បត់ ចាប់ហើយហើយជាខ្សែរបស់ឈ្មោះ សោម បញ្ជូននៅថ្ងៃ ៣១ ខែ០៣ ឆ្នាំ១៩៧៧។ ៣) ឈ្មោះ មុន សមាជិកវរសេនាតូច៥១១ ក្រោយចម្លើយឈ្មោះ ឈុំ-- តាមចម្លើយឈ្មោះ ឈុំ-- អ៎! ឈ្មោះ សារុំ និងឈ្មោះ សោម។ តាមចម្លើយឈ្មោះ សារុំ និងឈ្មោះ សោម ម៦២ បញ្ជូនយប់ថ្ងៃ ៣១ ខែ០៣ ៧៧។ ៤) ឈ្មោះ ផល សមាជិកវរសេនាតូចលេខ៥១៤ ចម្លើយឈ្មោះ សារុំ និងឈ្មោះ សោម ម៦២ បញ្ជូនព្រឹកថ្ងៃ ០១ ខែមេសា ១៩៧៧"។ នេះខ្ញុំសូមអាន នេះនិយាយអំពីគេផ្ញើមនុស្សតាមសេចក្ដីសម្រេចរបស់អង្គការមកឲ្យស-២១ ទាំងអស់វាបីលើក បួនលើក។ ឯចំណែកនៅក្នុង (ខ)ទីពីរ គេបញ្ជាក់ថា៖ "អ្នកដែលឈ្មោះដែលនៅសល់ ចាំសូមយោបល់ពីអង្គការ ហើយនិងមានវិធានការមកទៀត"។ នេះគឺថាអ្នកដែលគេមានឈ្មោះ និងចម្លើយហ្នឹងចាំគេសូមយោបល់អង្គការ សិន។ នេះសង្ខេបមកប៉ុណ្ណោះ។

[១៣:៥០:៥៦]

**ស៖** សូមអរគុណលោកសាក្សី។ លោកបាននិយាយនៅក្នុងភស្តុតាងពីខាងដើមថា ពាក្យថា "អង្គការ" គឺប្រើដោយបុគ្គលម្នាក់ៗ ពេលខ្លះគឺថាយើងសំដៅទៅលើស្ថាប័នផ្សេង ហើយលោកឱ្យឧទាហរណ៍ថា ណាត ប្រើពាក្យអង្គការដើម្បីគេហៅ គាត់។ ប៉ុន្តែលោកប្រើពាក្យ "អង្គការ" សំដៅតែលោក ប៉ុល ពត ឬក៏បុគ្គលផ្សេងទៀតដែលគេណែនាំ-- ដែល ប៉ុល ពត ណែនាំ។ សូមលោកជម្រាបបំភ្លឺប្រាប់តុលាការ តើអង្គការនៅក្នុងលិខិតនេះ សំដៅដល់អ្នកណា?

[១៣:៥១:៣៣]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន "អង្គការ"នៅក្នុងសំបុត្ររបស់ មិត្តម៉េត នេះសំដៅ ប៉ុល ពត តាមរយៈ សុន សេន។

**ស៖** សាក្សីលោកបាននិយាយពីខាងដើមថា សុន សេន បាន-- ជាអ្នកណែនាំឱ្យសរសេរសំបុត្រនេះ ហើយបញ្ជូនមកលោក។ តើមានន័យថា ទាំងលោក ទាំងអ្នកសរសេរលិខិតហ្នឹងត្រូវរាយ-ការណ៍ទៅឱ្យបុគ្គលម្នាក់ ឬក៏អ្នកក្រោមបង្គាប់របស់បុគ្គលម្នាក់នោះដែរឬទេ គឺ សុន សេន នោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន យើងខ្ញុំទាំងពីរនាក់រាយការណ៍ទៅមេបំផុតពីលើនោះតាមរយៈ សុន សេន។

**ស៖** លោកសាក្សីសូមឱ្យលោកបំភ្លឺផងដែរ ថាតើអ្វីត្រូវចាត់វិធានការបន្ថែមនៅក្នុងកថាខណ្ឌ (ខ)ពីរ នៃលិខិតនេះ មានន័យដូចម្ដេចឱ្យចាត់វិធាការបន្តទៀត?

[១៣:៥៣:០៥]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឈ្មោះដែលតាមចម្លើយ សោម ហើយនិងសារុំ ដែលមិត្តម៉េត បានការអនុញ្ញាតពីអង្គការឱ្យបញ្ជូនមកប៉ុន្មានបួននាក់នេះ។ ដូច្នេះនៅសល់អ្នកផ្សេងទៀត គាត់នឹងសូមយោបល់សម្រេចពីខាងលើតាមរយៈ សុន សេន ពីអង្គការតាមរយៈ សុន សេន។ ដល់បានការសម្រេចហើយ គាត់នឹងបញ្ជូនមកស-២១។ បន្តហ្នឹង វិធានការបន្តហ្នឹង គឺបញ្ជូន ឬមិនបញ្ជូន ស្រេចនៅអង្គការសម្រេច។

**កញ្ញា លី ម៉ាញឿន៖**

ខ្ញុំសូមអនុញ្ញាតុលាការ ដើម្បីបង្ហាញឯកសារមួយទៀតជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

ឱ្យលេខអត្តសញ្ញាណឯកសារ!

**កញ្ញា លី ម៉ាញៀន៖**

ចាសលោកប្រធាន ហើយឯកសារនោះ គឺD288/5.211 ERN ជាភាសាអង់គ្លេស គឺ 00178066, ERN ជាភាសាខ្មែរគឺ 00002416។

[១៣:៥៥:១១]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការទទួលឯកសារពីមេធាវីយកទៅបង្ហាញសាក្សី ឲ្យសាក្សីពិនិត្យ។

**កញ្ញា លី ម៉ាញៀន៖**

សូមអនុញ្ញាតឲ្យមន្ត្រីសំណុំរឿង ដើម្បីបង្ហាញឯកសារនៅលើអេក្រង់ផងដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**កញ្ញា លី ម៉ាញៀន៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា លី ម៉ាញៀន៖**

**ស៖** សាក្សីសូមលោកបញ្ជាក់មើល ថាតើលោកធ្លាប់បានឃើញឯកសារហ្នឹង តាំងពីមុនមកដែរឬទេ? ហើយលោកស្គាល់ឯកសារហ្នឹងដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះខ្ញុំឃើញនៅក្នុងសវនាការសំណុំរឿង០០១។

**ស៖** សូមលោកជម្រាបតុលាការឲ្យជ្រាបផង អំពីថាតើលិខិតហ្នឹងយ៉ាងដូចម្តេច? ផ្ញើចេញពីអ្នកណា? ជូនទៅអ្នកណា? ហើយកាលបរិច្ឆេទនៅថ្ងៃខែឆ្នាំណាដែរ?

[១៣:៥៦:៣៥]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន សំបុត្រនេះក៏នៅតែជាសំបុត្ររបស់មិត្ត ម៉េត ផ្ញើមកខ្ញុំ តាមការណែនាំឲ្យសរសេររបស់មេ។ ហើយផ្ញើមក-- គឺមេដែលបញ្ជូនមកខ្ញុំ មិនមែនមិត្តម៉េតទេ ហើយកាលបរិច្ឆេទនៃឯកសារនេះ គឺថ្ងៃ៣០ ខែ០៥ ឆ្នាំ១៩៧៧។

**ស៖** នៅពេលដែលបានបញ្ជូនតាមរយៈ មេរបស់លោកតើលោកមាននិយាយថាចេញមកពីមន្ទីររបស់មេមកមន្ទីររបស់លោកផ្ទាល់ ឬក៏ដូចម្តេច?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឯកសារអ៊ីចឹងៗគឺចេញពីដៃមេមកតាមរយៈនីរសារ ឬតាមរយៈអ្នកណា គឺមិនច្បាស់ទេ ខ្ញុំភ្លេចអស់ហើយ ប៉ុន្តែពិតជាដល់ដៃខ្ញុំ។ អត់មានដល់ដៃអ្នកណាផ្សេងទៀតទេ។

[១៣:៥៨:០៤]

**ស៖** សាក្សី សូមលោកបំភ្លឺតុលាការម្តងទៀត នៅក្នុងកថាខណ្ឌចុងក្រោយ ដែលនិយាយថា ប្រសិនបើអង្គការអនុញ្ញាត ខ្ញុំសូមចង់បានចម្លើយសារភាព ដើម្បីស្វែងរកខ្មាំងបន្ថែមទៀត តើអង្គការនៅត្រង់នេះសំដៅដល់អ្នកណា ក្នុងកថាខណ្ឌមួយនេះ?

**ឆ៖** អរគុណ។ សូមជម្រាបប្រសាសន៍លោកប្រធាន អង្គការនៅក្នុងកថាខណ្ឌទី៤ នេះពិតជាសំដៅទៅខាងលើ តាមរយៈ សុន សេន។

**ស៖** លោកសាក្សី ប្រសិនបើឯកសារហ្នឹងផ្ញើតាមរយៈ សុន សេន ផ្ទាល់ ហេតុអ្វីក៏លោកបញ្ជាក់ថា សុន សេន មិនមែនជាអ្នកចុះហត្ថលេខាហ្នឹងទៅវិញ?

**ឆ៖** អរគុណៗ។ ជម្រាបប្រសាសន៍លោកប្រធាន អក្សរ មិត្តម៉េត ប្លែកពីអក្សរ សុន សេន ហើយអក្សរស៊ីញ៉េនេះ ហត្ថលេខានេះគឺ ហត្ថលេខា មិត្តម៉េត ដាក់ទាំងឈ្មោះគេផង។

**ស៖** លោកសាក្សី លោកចង់និយាយថា អក្សរដៃរបស់ ម៉េត នោះគឺខុសពីអក្សរដៃរបស់លោក សុន សេន តើមែនទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន អក្សរដៃរបស់ មិត្តម៉េត ខុសពីអក្សរដៃបង សុន សេន។

[១៤:០០:០៥]

**កញ្ញា លី ម៉ាញឿន៖**

លោកសាក្សី ខ្ញុំមានឯកសារមួយទៀត សូមបញ្ហាំងជូនលោកប្រសិនបើតុលាការអនុញ្ញាតខ្ញុំសូមបញ្ចាំង។ ឯកសារ ERN ជាភាសាអង់គ្លេស គឺ 00224319 ឯកសារ D108/31.40 ERN ជាភាសាខ្មែរគឺ 00002078។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីយកទៅជូនសាក្សីពិនិត្យ! ហើយមន្ត្រីជំនួយការ គឺដាក់បញ្ចាំងឯកសារនៅលើអេក្រង់ទូរទស្សន៍!

**សួរដោយកញ្ញា លី ម៉ាញៀន៖**

**ស៖** លោកសាក្សី តើលោកធ្លាប់ឃើញឯកសារនេះពីមុនមកដែរឬទេ?

**ឆ៖** អរគុណ។

[១៤:០១:២៤]

**ស៖** តើលោកអាចកំណត់អត្តសញ្ញាណឯកសារនេះដូចមុនដែរឬទេ ដើម្បីបង្ហាញជូនតុលាការថាតើលិខិតនេះបញ្ជូនទៅនរណាគេដែរ ហើយចុះកាលបរិច្ឆេទថ្ងៃណាដែរ?

**ឆ៖** អរគុណ។ ឯកសារនេះ ជាសំបុត្ររបស់មិត្ត ម៉េត ផ្ញើមក--

**ប្រធានអង្គជំនុំ៖**

ខុចៗ កុំអាលឆ្លើយតប។ អញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមអភ័យទោសដែលខ្ញុំកាត់នៅត្រង់ចំណុចនេះ ក៏ប៉ុន្តែខ្ញុំមើលអត់ឃើញទេអេក្រង់របស់ខ្ញុំ គឺឯកសារមិនទាន់បញ្ចាំងទេ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅមន្ត្រីជំនួយការ? សូមអញ្ជើញ! មានហើយឥឡូវ អាចតាំងសំណួរបានហើយ។ អ្នកតាំងសំណួរចាំមើលឯកសារសិន ព្រោះបានស្នើសុំថាឲ្យដាក់ឯកសារហ្នឹងបញ្ជូនទៅសាក្សី ហើយនិងដាក់បញ្ចាំងនៅលើអេក្រង់ទូរទស្សន៍ ដើម្បីដេញដោល។ អ៊ីចឹងរង់ចាំមានលក្ខខណ្ឌទាំងពីរហ្នឹងសិន សុំចាប់ផ្ដើមនីតិវិធីនៃការតាំងសំណួរដេញដោលផ្សេងៗ ពាក់ព័ន្ធនឹងឯកសារដែលស្នើសុំដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ។ ចៀសវាងមានការតវ៉ាជំទាស់ ឬក៏ភាពមិនច្បាស់លាស់នៃការដេញដោលចំពោះឯកសារ ពីព្រោះនីតិវិធីនេះយើងធ្វើដូចជាច្រើនហើយ វាគួរតែត្រូវបានទទួលជាមានបទពិសោធន៍ល្អហើយនូវការដាក់ឯកសារ ដើម្បីដេញដោលនោះ។

[១៤:០៣:១៧]

**កញ្ញា លី ម៉ាញៀន៖**

សូមអរគុណលោកប្រធាន សូមអរគុណដែលបានរំឭកយើងខ្ញុំ។

**សួរដោយកញ្ញា លី ម៉ាញៀន៖**

**ស៖** លោកសាក្សីតើលោកអាចធ្វើការសង្ខេបបានដែរឬទេ តើឯកសារនេះនិយាយអំពីអ្វីខ្លះ? ខ្ញុំ

មិនមែនសុំឲ្យលោកឯកសារនេះទាំងអស់នោះទេ ក៏ប៉ុន្តែសូមឲ្យលោកបញ្ជាក់ដោយសង្ខេប តើនិយាយអំពីអ្វីដែរឯកសារនេះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាននៅក្នុងឯកសារនេះ មិត្តម៉េត តាមសំណូមពររបស់ខាងលើតឿនឲ្យផ្តល់ចម្លើយរបស់ឈ្មោះ សែម ឲ្យឆាប់ ដើម្បីគេសុំយោបល់អង្គការ និងមានវិធានការតាមចម្លើយ។ ឯកសារនេះចុះនៅថ្ងៃទី១០ ខែសីហា ១៩៧៧។

[១៤:០៤:៥០]

**ស៖** តើលោកអាចបញ្ជាក់ដូចមុនដែរឬទេថា តើប្រយោគចុងក្រោយនេះសរសេរថាយ៉ាងម៉េច? ថាជូនព័ត៌មានតាមរយៈអង្គការឲ្យ ម៉េត ផង? តើយ៉ាងម៉េចដែរ សូមឲ្យលោកបញ្ជាក់ពន្យល់ត្រង់ចំណុចទាំងអស់នេះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន អក្សរមួយតួខាងចុងនេះ ខ្ញុំនៅឃើញថា អានថា “ឆាប់ផង” អានេះបើតាមខ្លឹមសារ។ តែគាត់សរសេរនេះពិបាកយល់មែន។ បើតាមខ្លឹមសារគឺនិយាយថា ឲ្យឆាប់ផង។ ឯចំណែកពាក្យ “អង្គការ” ខ្ញុំអត់មានអីថាខុសនុ៎ងទេ ពីមុនទេ គឺសូមបញ្ជាក់របៀបពីមុន។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ លោកនិយាយថា “អង្គការ” នេះសំដៅទៅ ប៉ុល ពត ឬក៏ សុន សេន?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន សុន សេន គាត់មិនដែលតាំងខ្លួនគាត់ជាអង្គការទេ។ ប៉ុន្តែក្មេងៗចេះតែហៅគាត់ពីក្រោយខ្នងតែអ៊ីចឹង។ ខ្ញុំពីក្រោយខ្នង ខ្ញុំនិយាយក្នុងអង្គភាពខ្ញុំ អង្គការហ្នឹងក៏សំដៅ សុន សេន ដែរ។ អង្គការហ្នឹងក៏សំដៅ ពូនួន ដែរ។ ក៏ប៉ុន្តែតាមពិត សុន សេន គាត់មកនិយាយជាមួយខ្ញុំ គាត់ថា ឯកសារមិត្តគឺផ្ញើទៅអង្គការតាមរយៈខ្ញុំ ខ្ញុំមកណែនាំមិត្តក្នុងនាមអង្គការ។ ដូច្នេះ សុន សេន គាត់និយាយបញ្ជាក់អ៊ីចឹងច្បាស់ណាស់ តួអង្គគាត់។

[១៤:០៦:៤៧]

**ស៖** លោកសាក្សី ខ្ញុំកត់សម្គាល់ឃើញថា កាលបរិច្ឆេទគឺថ្ងៃ១០ ខែសីហា ឆ្នាំ៧៧ លោកបានផ្តល់ចម្លើយមុននេះថា នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៨ សុន សេន ត្រូវបានបញ្ជូនទៅអ្នកលឿង ហើយ នួន ជា កាន់កាប់ជំនួស សុន សេន តើលោកចាំទេចំណុចហ្នឹង?

**ឆ៖** អរគុណ។ មិនដឹងជាមេធាវីមានប្រសាសន៍ខុស ឬអ្នកប្រែខុសទេ។ សុន សេន ចេញ

ចោលខ្ញុំទៅនៅអ្នកលឿងនៅថ្ងៃ១៥ ខែសីហា ១៩៧៧ មិនមែន៧៨ ទេ។ រឿងនេះជារឿងពិត។ តាំងពីពេលហ្នឹងមក ខ្ញុំមិនដែលបានជួប សុន សេន ផ្ទាល់មុខទេ ក៏ប៉ុន្តែខ្ញុំទាក់ទងគ្នាជាមួយនឹងគាត់តាមអាកាសៗ។

**ស៖** ជាការពិត ប្រសិនបើ ខ្ញុំចាំមិនខុសនោះទេ លោកបានផ្តល់ចម្លើយខាងដើមថា នៅពេលដែល សុន សេន ចាកចេញទៅ នួន ជា គ្រប់គ្រងទៅលើផ្នែករបស់លោក សុន សេន។ ដូច្នេះហើយ នួន ជា នេះក្លាយទៅជាមេផ្ទាល់របស់លោក។ តើត្រឹមត្រូវដែរឬទេ?

[១៤:០៨:២២]

**ឆ៖** ត្រឹមត្រូវ!

**ស៖** ដោយមើលថ្ងៃខែនៅក្នុងនេះ គឺថ្ងៃខែនេះ ចុះប្រាំថ្ងៃមុន សុន សេន ទៅអ្នកលឿង។ ថាតើលិខិតនេះមានបញ្ជូនទៅឲ្យ នួន ជា ផ្ទេរដែរឬទេ ដើម្បីបង្ហាញអំពីភារកិច្ច និងតួនាទីនៅក្នុងអង្គភាពរបស់ សុន សេន ប្រាប់ទៅ នួន ជា?

**ឆ៖** អរគុណ។ ខ្ញុំសូមមិនឆ្លើយទេ ព្រោះបើនឹងឆ្លើយវាចូលក្នុងផ្លូវដែលយើងសន្និដ្ឋាន។ យើងនាំគ្នាសន្និដ្ឋាន។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកនៅតែបន្តលិខិតស្រដៀងគ្នាហ្នឹងទៅពីលោក ស៊្វ ម៉េត ទោះបីជាក្រោយពី សុន សេន បានធ្វើដំណើរទៅអ្នកលឿងនៅក្នុងឆ្នាំ១៩៧៧ ហើយក៏ដោយ។

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំចាំអត់ច្បាស់ទេ។

[១៤:១០:០០]

**ស៖** លោកសាក្សី តើអាចបញ្ជាក់បានដែរឬទេ ប្រព័ន្ធដែលគេប្រើនីរសារបញ្ជូនលិខិតទៅលោកនោះ តើគេប្រើនីរសារតាមមធ្យោបាយអ្វីដែរ?

**ឆ៖** អរគុណ។ នៅក្នុងជំនាន់នោះ សុន សេន គាត់ប្រើនីរសារពីរនាក់ចុះមកមន្ទីរស-២១ តែពីរនាក់គត់។ ទីមួយ ហើយដែលញឹកញាប់ខ្លាំងបំផុតគឺ មិត្តផន ១មកឡាន ព្រោះយកឯកសារទៅហ្នឹង សុន សេន ដូចជាប្រយ័ត្ន បើមិត្ត នឿន គាត់មកម៉ូតូ។ ឯកសារណាតិចតួចអី មិត្តនឿន គាត់មកជាម៉ូតូ។ ដោយឡែក ករណីក្រោយថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៧ បងនួន ប្រើនីរសារពីរនាក់ជាសំខាន់ដំបូង គឺ មិត្តទៀង ញឹកជាងគេ ហើយបន្ទាប់ពី មិត្តទៀង ហ្នឹង សូត្រ មិត្តជីវ ហៅ សូត្រ មិត្តសូត្រ ហៅ ជីវ។ ហើយដល់តាំងពី បងនួន គាត់អញ្ជើញទៅចិន ត្រឡប់មកវិញខានឃើញ មិត្តទៀង ហើយ វាលេចចេញ

មិត្តលីន ។ ហើយយូរៗម្តងចេញ មិត្តគី ប្រធាន ក-៧ ទៅអើតខ្ញុំ យកឯកសារទៅ។ ដូច្នេះ ខាងណោះប្រើបង្រោសដែរ ក៏ប៉ុន្តែដឹងតែចេញពីអង្គការ ចេញពី ប៉ុល ពត ផ្ទាល់តែម្តង។

[១៤:១១:៤០]

នេះរបៀបឯក-- របៀបនេ៎ះ អ្នកចេញចូលទៅយកឯកសារពីនុំង ដូច្នេះខាង ស-២១ គ្មានអ្នកណាម្នាក់មានសិទ្ធិទៅដល់ខាងអង្គការទេ មានតែខាងអង្គការយកជើងទៅជាន់ ស-២១។ អរគុណ សូមបញ្ជាក់ប៉ុណ្ណេះ។

**ស៖** ចាតើអ្នកជានីរសារនេះមានប្រើលេខកូដអ្វីជាសំខាន់ទេនៅពេលដែលបញ្ជូនលិខិត?

**ឆ៖** នីរសារហ្នឹងអត់មានលេខកូដអីជាសំខាន់ទេ។ សូមជម្រាបប្រសាសន៍លោកប្រធាន នីរសារហ្នឹងអត់មានលេខកូដអីជាសំខាន់ទេ។ បងខៀវ ប្រើមិត្តផន ហើយនិង មិត្តនឿន ហ្នឹងតាំងអើយ។តាំងពីខ្ញុំនៅជាមួយ ណាត។ ដល់ពេលដែលចេញទៅនេះ បងនួន នេះឧទ្ទេសនាមខ្ញុំ មិត្តប៉ង់។ ក៏ប៉ុន្តែមិត្តទឿង ក៏គាត់ឧទ្ទេសនាមមកដែរ ឲ្យមកយកឯកសារមកឲ្យខ្ញុំ។ ដូច្នេះ មេឧទ្ទេសនាមម្តងជាការស្រេច។ នេះអត់មានលេខកូដអីទេ។ មិត្តគី ក៏អ៊ីចឹង ហើយមិត្តលីន មិនបាច់និយាយទេ ខ្ញុំស្គាល់យូរហើយ យូរៗបន្តិចដែរហើយ។ មិត្តលីន និងមិត្តប៉ង់ នេះជាមនុស្សរបស់អង្គការ ខ្ញុំស្គាល់យូរបន្តិចដែរហើយ។ ដូច្នេះសរុបមក អ្នកទាំងអស់គ្នានេះអត់មានប្រើលេខកូដទេ ឧទ្ទេសនាមឲ្យស្គាល់គ្នាម្តងជាការស្រេច។

[១៤:១៣:៤២]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចូលទៅដល់ប្រធានបទមួយទៀត ដូចដែលខ្ញុំបានជម្រាបជូនអង្គជំនុំជម្រះកាលពីថ្ងៃមុនដូច្នោះ ខ្ញុំនឹងនិយាយអំពីការចាប់មន្ត្រីបរទេសមកកម្ពុជា។ ខ្ញុំសូមបង្ហាញរដ្ឋធម្មនុញ្ញជូនលោកសាក្សី ដោយសារតែរដ្ឋធម្មនុញ្ញនេះបានជូនទៅកាន់-- បានបញ្ចាំងរួចមកហើយ។ ដូច្នេះ ខ្ញុំសូមបញ្ជូនឯកសារនេះជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីយកទៅជូនសាក្សីពិនិត្យ!

[១៤:១៤:៣១]

**កញ្ញា លី ម៉ាញឿន៖**

តើលោកប្រធានចង់ឲ្យខ្ញុំអាន ERN ជាអង់គ្លេស និងជាភាសាខ្មែរដែរឬទេ? ខ្ញុំគិតថាដូចជាមិន

ចាំបាច់ទេ ដោយសារតែឯកសារនេះដូចជាបានបង្ហាញជូនសាក្សីម្តងរួចមកហើយ។

**ប្រធានអង្គជំនុំ៖**

ជាការពិតត្រូវតែអាន ដើម្បីឱ្យភាគីដែលពាក់ព័ន្ធហ្នឹងក្តាប់ឱ្យបានព្រោះឯកសារជាភាសាខ្មែរ ហើយនិងជាភាសាអង់គ្លេស ឬបារាំងហ្នឹង វាមានលេខ ERN ខុសគ្នា។

[១៤:១៥:០៤]

**កញ្ញា លី ម៉ាញឿន៖**

ខ្ញុំនឹងធ្វើការតាមការបង្គាប់បញ្ជា។ ឯកសារលេខ ERN គឺ 00184838 ឯកសារ D1.3.22.2 ខ្មែរ ERN គឺ0089841 បារាំង ERN គឺចាប់ផ្តើមពី 00012644។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតឱ្យបញ្ចាំង ឯកសារនេះ នៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

[១៤:១៥:៥៦]

**សួរដោយកញ្ញា លី ម៉ាញឿន៖**

**ស៖** លោកសាក្សី ខ្ញុំសូមឱ្យលោកមើលជំពូក១៦ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ។ ជាពិសេសនៅក្នុងកថាខណ្ឌទី២ នៃមាត្រា២១ តើលោកបានឃើញទេ លោកសាក្សី?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំបានឃើញ។

**ស៖** ត្រង់វាក្យខណ្ឌទី២ចែងថា “កម្ពុជាប្រជាធិបតេយ្យប្រកាន់ខ្ជាប់នូវនយោបាយឯករាជ្យ សន្តិភាព អព្យាក្រឹត្យ មិនចូលបក្សសម្ព័ន្ធណា មិនអនុញ្ញាតឱ្យបរទេសណាតាំងមូលដ្ឋានសឹកនៅក្នុងប្រទេសកម្ពុជាដាច់ខាត។ តស៊ូដាច់ខាត និងការជ្រៀតគ្រប់បែបយ៉ាងពីខាងក្រៅ មកក្នុងកិច្ចការផ្ទៃក្នុងប្រទេសកម្ពុជា។ តស៊ូដាច់ខាតនឹងអំពើវិទ្ធង្សនាឈ្លានពានគ្រប់បែបយ៉ាងពីខាងក្រៅមកលើប្រទេសកម្ពុជា ទោះជាវិទ្ធង្សនា ឬឈ្លានពានខាងយោធាក្តី ខាងនយោបាយក្តី ខាងវប្បធម៌ក្តី ខាងសេដ្ឋកិច្ចក្តី ខាងសង្គមកិច្ចក្តី ខាងការទូត ឬក៏តាមរូបភាពយកនាមថា មនុស្សធម៌ក្តី”។ តើលោកគិតថា កម្ពុជាប្រជាធិបតេយ្យបានអនុវត្តខ្ជាប់ខ្ជួនទៅលើចំណុចនេះដែរឬទេ?

[១៤:១៧:២៥]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន តាមការមើលឃើញជាក់ស្តែង គឺកម្ពុជាប្រជាធិបតេយ្យអនុវត្តចំណុចទាំងអស់នេះ ដាច់ខាត។

[១៤:១៧:៥៨]

**ស៖** តើកងវរសេនាធំ ឬក៏អង្គភាពមួយណានៃកងទ័ពបដិវត្តន៍កម្ពុជា ទទួលខុសត្រូវនៅក្នុងការការពារដែនសមុទ្រនៅក្នុងកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន កងការពារដែនសមុទ្រនៅកម្ពុជាប្រជាធិប-- របស់កម្ពុជាប្រជាធិបតេយ្យមិនមែនជាកងវរសេនាធំទេ ជាកងពលពេញ គឺកង១៦៤។

**ស៖** តើកងពលនោះ មានភារកិច្ចការពារការឈ្លានពានចូលទឹកដីដែនសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** អរគុណ។ កងពល១៦៤ នេះ វាការពារដែនសមុទ្រកម្ពុជា គឺបូរណភាពដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ។

[១៤:១៩:៣៨]

**ស៖** តើនរណាគេជាប្រធានកងពល១៦៤ ហើយតើតួនាទីរបស់គាត់នៅក្នុងគណៈមជ្ឈិមនេះជាអ្វីដែរ? គាត់មានតួនាទីអ្វីដែលនៅក្នុងកងគណៈមជ្ឈិម?

**ឆ៖** អរគុណ។ ជម្រាប្រសសន៍លោកប្រធាន ប្រធានកងពលជើងទឹកឈ្មោះ មុត គឺ មាស មុត នៅក្នុងមជ្ឈិមបក្ស គាត់ទើបតែនឹងចូលជាជំនួយការមជ្ឈិមទេ ជាមួយគ្នានឹង មិត្តម៉េត ដែរ។

**ស៖** តើលោកចាំថា នៅថ្ងៃទី២៩ ខែមីនា លោកបាននិយាយថា រដ្ឋមន្ត្រីការបរទេសទទួលខុសត្រូវ ខាងផ្នែកការបរទេស។ តើលោកបានលើកឡើងចំណុចនេះដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន រដ្ឋមន្ត្រីការបរទេសទទួលភារកិច្ចការងារបរទេស ខ្ញុំពិតជាបាននិយាយបញ្ហានេះ។

[១៤:២១:១៤]

**ស៖** លោកក៏បាននិយាយផងដែរថា អ្នកនេសាទនៅ-- អ្នកនេសាទប្រទេសថៃត្រូវបានបញ្ជូនទៅស-២១ ថ្ងៃ៣០ ខែមីនា ឆ្នាំ១៩៧៦។ តើការចាប់ខ្លួនអ្នកនេសាទទាំងអស់នោះ ដែលជាជនជាតិថៃនោះ គឺជាផ្នែកមួយនៃការការពារខាងនយោបាយការបរទេសដែរឬទេ?

**ឆៈ** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បញ្ហាចាប់អ្នកនេសាទនេះ ខ្ញុំឃើញបញ្ជីនៅសល់នៅស-២១។ ខ្ញុំសូមពន្យល់ដូចតទៅ៖ កិច្ចការនេះ កងពល១៦៤ចាប់ ក្រោមបញ្ជារបស់សេនាធិការ គឺក្រោមបញ្ជា សុន សេន មិនមែនក្រោមបញ្ជាក្រសួងការបរទេសទេ។

**សៈ** ដូច្នេះហើយ ការគោរពយ៉ាងរឹងប៉ឹង គឺបានគោរពដើម្បីការការពារតាមនយោបាយការបរទេស តាមរដ្ឋធម្មនុញ្ញ។ ដូច្នេះហើយទើបមានការធ្វើការប្រព្រឹត្តទៅលើជនជាតិបរទេសនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។

**ឆៈ** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ដូចអត់ឮសួរសួរ គ្រាន់តែអធិប្បាយឲ្យខ្ញុំស្តាប់ហើយ អត់ឮសួរសួរ។

**សៈ** សំណួរដែលខ្ញុំចង់សួរនោះ គឺតើគោលនយោបាយតាមជំពូក១៦ នៃរដ្ឋធម្មនុញ្ញបង្កើតជាមូលដ្ឋានមួយ ដើម្បីយកទៅធ្វើការប្រព្រឹត្តធ្វើបាបចំពោះពលរដ្ឋបរទេស ដោយរដ្ឋកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆៈ** អរគុណ។ ជម្រាបសាសន៍លោកប្រធាន។ បញ្ហានេះ យើងប្រើភាសាមិនត្រូវគ្នាទេ ភាសារបស់កម្ពុជាប្រជាធិបតេយ្យ ជាពិសេសកងពល១៦៤ គេៗមានភារកិច្ចការពារបូរណភាពដែនសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យរបស់គេ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

[១៤:២៤:២១]

**សៈ** តើលោកបានចាំដែរឬទេនៅក្នុងសំណុំរឿងមួយ ដែលលោកបាន-- នៅក្នុងករណីមួយនោះ គឺលោកបានលើកឡើងថា មានពលរដ្ឋបរទេសត្រូវបានឃុំឃាំងនៅស-២១។ តើលោកចាំទេ? មានបានលើកឡើងដូច្នេះ?

**ឆៈ** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ពលរដ្ឋបរទេសមាន ឃុំខ្លួននៅស-២១ ហើយក្រោយមកកម្ទេច។

[១៤:២៥:០៨]

**សៈ** ខ្ញុំសូមឲ្យលោកផ្តោតទៅលើពលរដ្ឋខាងបស្ចិមប្រទេស ដែលត្រូវបានគេចាប់យកទៅស-២១ ឃុំនៅទីនោះ គឺស្បែកស ជនជាតិស្បែកស អ្នកទាំងអស់នោះរួមមាន អូស្ត្រាលីពីរនាក់ អង់គ្លេសម្នាក់ បីអាមេរិកាំង និងញូវហ្សេឡេន ម្នាក់។ ដូច្នេះ តើលោកចាំទេ? មានចាប់ឃុំនៅស-២១ ដែរឬទេ?

**ឆ៖** អរគុណ។ បញ្ហានេះវាដឹងឮជាសកលអស់ទៅហើយ ពួកបស្ចិមប្រទេសទាំងបួនរូបនេះចូលទៅដល់-- សូមទោស! ពួកបស្ចិមប្រទេសទាំងអស់នេះចូលទៅដល់ស-២១ តែបួនរូបទេ។ បានទៅជាប់ឃុំនៅទីនោះ ហើយកម្ទេច ហើយទទួលបញ្ជាដាច់ខាតឱ្យដុតនឹងកង់ឡានឱ្យអស់ កុំឱ្យឆ្អឹងទៅទៀតនេះគឺពិត។

[១៤:២៦:១៩]

**ស៖** ខ្ញុំមានសំណួរមួយចំនួនទៀតអំពីបញ្ហានេះ ក៏ប៉ុន្តែមុនពេលដែលខ្ញុំសួរចំណុចនេះ។ ខ្ញុំសូមសួរជាមុនសិនថា តើជនបរទេសត្រូវបានគេចាត់ទុកជា អ្នកទោសពិសេស អ្នកទោសសំខាន់ដែរឬទេ នៅពេលដែលចាប់ចូលមកដល់ស-២១?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ពួកអ្នកនេសាទថៃ អត់ទុកជាសំខាន់ទេ មកដល់គេគិតតែពីកម្ទេចទៅ។ ខ្ញុំមិនទាំងដឹងផង នេះនិយាយជាក់ស្ដែង។ មិត្តហ៊ី ទេគេចាត់ចែងតាមបញ្ជារបស់ខាងលើ។ ឯចំណែកបុគ្គលខាងពួកបស្ចិមប្រទេសទាំងបួនរូបនេះ គេទុកជាសំខាន់។ ខ្ញុំឱ្យអ្នកសួរចម្លើយផ្ចិតផ្ចង់បន្តិចដែរ ជ្រើសរើសអ្នកដែលគេជាអ្នកសួរចម្លើយមានពិសោធន៍របស់ខ្ញុំឱ្យសួរ។

[១៤:២៧:៣៣]

**ស៖** ហេតុអ្វីបានជាបរទេស-- ជាតិបរទេសបស្ចិមបួនរូបនោះត្រូវបានគេកំណត់ថា មានឋានៈជនសំខាន់?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ពួកនេះចូលមកកម្ពុជាដោយគ្មានការអនុញ្ញាតអំពីក្រសួងការបរទេសទេ។ ដូច្នេះកម្ពុជាប្រជាធិបតេយ្យចាត់ទុកពួកនេះជាចារបុរស។ ដូច្នេះពួកភ្នែកសបស្ចិមប្រទេសនេះ គេជឿថា ជាមនុស្សដែលមានពិសោធន៍ខាងចារកម្ម។ ខ្ញុំសូមបញ្ចប់ចម្លើយខ្ញុំប៉ុណ្ណេះ។

**ស៖** តើលោកដឹងដែរឬទេ រដ្ឋមន្ត្រីការបរទេសបានចូលរួមនៅក្នុងកងពល ក្នុងការចាប់ខ្លួនបញ្ជូនជនបរទេសទាំងអស់នេះចូលមកស-២១?

[១៤:២៨:៥៩]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ជាគោលការណ៍ធ្វើការងារខ្ញុំមិនជឿថា រដ្ឋមន្ត្រីក្រសួងការបរទេសលូកដៃក្នុងបញ្ហានេះទេ។ វាតែបញ្ហាអគ្គបញ្ជាការដ្ឋានរបស់កងទ័ពជាតិកម្ពុជា ដែលមាន ប៉ុល ពត ជាប្រធាន ហើយនិង នួន ជា ជាអនុប្រធាន ហើយនិងសេនាធិការប៉ុណ្ណឹងឯង។

**ស៖** តើលោកអាចបញ្ជាក់ដែរឬទេ ថាតើអ្នកទោសពិសេសនោះត្រូវបានគេអនុវត្តគោលការណ៍នីតិវិធីចំពោះពួកគេហ្នឹងយ៉ាងម៉េចដែរ?

[១៤:២៩:៥៦]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន នៅស-២១ ពួកអស់នេះជាប់ឃុំ នៅក្នុងបន្ទប់ពិសេស ហើយអ្នកសួរនោះក៏ខ្ញុំបានជ្រើសរើសមនុស្ស ដែលមានពិសោធន៍ក្នុងការសួរច្បាស់លាស់របស់ខ្ញុំ។ ហើយដល់ចុងបញ្ចប់សួរ ក៏មានសេចក្ដីសម្រេចឱ្យកម្ទេច កម្ទេចតាមរូបភាពដុតនឹងកង់ឡានកុំឱ្យសល់ឆ្អឹង។

**ស៖** នៅក្នុងភស្តុតាងលោកបាននិយាយពីខាងដើមថា លោកបានពិគ្រោះយោបល់ជាមួយ នួន ជា ជាទៀងទាត់អំពីការកំណត់អត្តសញ្ញាណរបស់អ្នកទោសពិសេស តើលោកយល់ពិភាក្សាជាមួយ នួន ជា ទេក្នុងករណីអ្នកបរទេសបួននាក់ ដែលលោកបាននិយាយខាងដើមអំមិញនេះ?

[១៤:៣១:១០]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បើតាមខ្ញុំចាំអ្នកទោសទាំងបួននាក់នេះ មកជាពីរលើក។ លើកទីមួយ គឺនៅក្នុងដំណាក់ដែល នួន ជា-- អ៎! សុំទោស ក្នុងដំណាក់ដែល សុន សេន គាត់នៅគ្រប់គ្រងស-២១។ ដូច្នេះ ខ្ញុំទទួលគ្រប់ការណែនាំពីគាត់។ ដោយឡែក អ្នកមកជាលើកទីពីរនេះ គឺក្នុងរយៈពេលដែល នួន ជា គាត់មកគ្រប់គ្រងស-២១។ ដូច្នេះ ខ្ញុំរាយការណ៍ជូនគាត់ ខ្ញុំទទួលការណែនាំពីគាត់ និងអនុវត្តបទបញ្ជារបស់គាត់ជាដាច់ខាត។

**ស៖** លោកសាក្សី លោកនិយាយពីខាងដើមថា នួន ជា បានចេញបញ្ជាឱ្យលោក ឱ្យដុតជនបរទេសនោះដោយកង់ឡាន។ តើគាត់ចេញបញ្ជាឱ្យលោកហ្នឹង នៅថ្ងៃខែឆ្នាំណាដែរ លោកចាំទេកាលបរិច្ឆេទ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន មិនចាំទេ។

**ស៖** ហេតុអ្វីបានជាការចាំបាច់ត្រូវដុត អ្នកទោសបរទេសនោះដោយកង់ឡាន?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ដុតដោយកង់ឡានឱ្យសុស កុំឱ្យនៅសល់ ឆ្អឹងក៏មិនឱ្យសល់ដែរ។ បងនួន គាត់បញ្ជាក់ថា យើងមិនធ្វើដូចគុយបាទេ គុយបាគេទុកឆ្អឹងទាហានអាមេរិកសម្រាប់ដូរយកត្រាក់ទ័រ យើងមិនទាក់ទងរបៀបនុំងទេ។ នេះតាមការពន្យល់របស់គាត់នៅពេលនោះ។

[១៤:៣៣:១៣]

**ស៖** ហេតុអ្វីបានជាការចាំបាច់របស់បក្សកុម្មុយនីស្តកម្ពុជា ថាដុតឲ្យទៅជាផេះផង់កុំឲ្យសល់អ៊ីចឹង?

[១៤:៣៣:២៥]

**ឆ៖** អរគុណ។ ដុតឲ្យទៅជាផេះផង កុំឲ្យសល់នេះ គឺកុំឲ្យអ្នកណាគេទៅរកដានឃើញទៅថ្ងៃក្រោយ យើងមិនមានទុកឆ្អឹង ដើម្បីគាស់យកឆ្អឹងនោះទៅដូរយកគ្រាក់ទ័រទេ។

**ស៖** ថាតើអ្នកទោសបរទេសទាំងអស់នេះ ត្រូវបានគេសម្លាប់ជាមុន មុននឹងគេដុតនឹងកង់ឡានដែរឬទេ?

**ឆ៖** អរគុណ។ សូមជម្រាបប្រសាសន៍លោកប្រធាន អ្នកទោសទាំងអស់នេះ អត់មានអ្នកណាដុតទាំងរស់ទេ គេសម្លាប់ហើយបានគេដុត។

**ស៖** បន្ទាប់ពីគេដុតឲ្យសុសអស់ហើយ តើលោកត្រូវរាយការណ៍ទៅមេរបស់លោកទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំត្រូវតែរាយការណ៍ ថាភារកិច្ចបានអនុវត្តហើយ បទបញ្ជាបានអនុវត្តហើយ។

[១៤:៣៥:០០]

**ស៖** ថាតើលោកដឹងដោយវិធីណា ដែលថាបញ្ជានោះត្រូវបានអនុវត្តសព្វគ្រប់ហើយនោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំរាយការណ៍ទៅមេថា បទបញ្ជាបានអនុវត្តហើយ ឯចំណែកខ្ញុំបានទទួលសេចក្តីរាយការណ៍ពី មិត្តហ៊ី ដែលខ្ញុំបញ្ជាទៅឲ្យគេចាត់ចែងដុត។

**ស៖** តើលោកត្រូវបញ្ជូនភស្តុតាងអ្វីទៅថ្នាក់លើដើម្បីឲ្យថាការងារហ្នឹងអនុវត្តត្រឹមត្រូវ ហើយតើបានថតរូបសាកសពមុននឹងដុតហ្នឹងដែរឬទេ?

**ឆ៖** អរគុណ។ បុគ្គលបួននាក់នេះ អត់មានបានថតរូបសាកសពទេ។

**ស៖** ខ្ញុំចង់ឲ្យបំភ្លឺតុលាការ លោកបាននិយាយថាមានពីរវគ្គ គឺថាបរទេសដែលគេបញ្ជូនមក ស-២១ ពេលខុសគ្នា។ ទីមួយនោះ ដំបូង បាទវគ្គដំបូងដែលគេបញ្ជូនមកក្នុងអំឡុងពេលដែលនៅក្រោមបង្គាប់របស់ សុន សេន ហើយនៅទីពីរ នៅពេលដែលលោកស្ថិតនៅក្រោមការបញ្ជារបស់លោក នួន ជា តើត្រូវឬទេលោក?

[១៤:៣៦:៣៤]

**ឆ៖** អរគុណ។ ត្រឹមត្រូវ!

**ស៖** តើលោកនិយាយដែរថា ដែលមកលើកទីមួយនោះគឺថាមុនថ្ងៃទី១៧ សីហា ឆ្នាំ៧៧ ហើយពីរនាក់ទៀតដែលមកក្រោយនោះ គឺក្រោយថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៧៧?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន គឺពិតជាអ៊ីចឹងមែន ក៏ប៉ុន្តែមិនមែនមុន១៧ សីហា ១៩៧៧ ទេ គឺមុនថ្ងៃ១៥ សីហា ១៩៧៧ និងក្រោយ១៥ សីហា ១៩៧៧។

**ស៖** សូមអរគុណលោកសាក្សី ដែលលោកបានបញ្ជាក់បំភ្លឺ។ ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារជូនសាក្សី ឯកសារនេះបានបង្ហាញជូនសាក្សីដោយសហព្រះរាជអាជ្ញារួចហើយ គឺៗជាច្បាប់ចម្លងនៃទស្សនាវដ្ដីទង់បដិវត្ត។

[១១:៣៧:៥២]

**កញ្ញា លី ម៉ាញឿន៖**

លោក លោកស្រីចៅក្រម សូមអនុញ្ញាតឲ្យមន្ត្រីតុលាការជូនឯកសារនេះទៅសាក្សី។

លោកប្រធានសូមបំភ្លឺ ខ្ញុំសូមគឺថាឯកសារនោះ វគ្គ គឺថាអាខ្មែរ ERN ចាប់ពីផ្ដើមពី00064551 រហូតទៅដល់ 00064585។ អង់គ្លេស ERN 00185322 ហើយរហូតទៅដល់ 00185348។ អត្ថបទភាសាបារាំង 00524447 រហូតទៅដល់ 00524475។

**ប្រធានអង្គជំនុំ៖**

ឲ្យលេខឯកសារ លេខ-- D ឬក៏ E?

**កញ្ញា លី ម៉ាញឿន៖**

លោកប្រធាន ឯកសារ D IS11.14។

**កញ្ញា លី ម៉ាញឿន៖**

លោកសាក្សី តើលោកបានមានឯកសារហ្នឹងនៅក្នុងដៃហើយឬនៅ?

**លោក កាំង ហ្កេកអ៊ាវ៖**

អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ពិបាករកណាស់។ សូមផ្ដល់ឲ្យថ្មីមក។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទៅទទួលឯកសារពីមេធាវី ហើយយកទៅជូនសាក្សីដើម្បីពិនិត្យ! ហើយជំនួយការគឺអាចបង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍។

[១៤:៤០:០៣]

**ស៖** លោកសាក្សី តើលោកចាំទេថា សហព្រះរាជអាជ្ញាបានបង្ហាញលោកនូវឯកសារនេះ នៅថ្ងៃទី០២ ខែ០៣-- បាទថ្ងៃទី២៧ ខែ០៣ ឆ្នាំ២០១២ កាលពីថ្ងៃអង្គការនេះ។ ដើម្បីបញ្ជាក់អត្តសញ្ញាណ គឺថាទង់បដិវត្តច្បាប់ពិសេសខែឧសភា និងមិថុនា ឆ្នាំ១៩៧៧?

**អ្នកបកប្រែ៖**

សូមកែតម្រូវ ឆ្នាំ១៩៧៨ (ពីអ្នកបកប្រែ)។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំឃើញឯកសារនេះ បានខ្ញុំជឿច្បាស់ ខ្ញុំបានទទួលមែន។ ព្រោះខែឧសភា មិថុនា ៧៨ ខ្ញុំបាទពិតជាបានទទួលពីសហព្រះរាជអាជ្ញាមែន។

**ស៖** ជាភស្តុតាងនោះលោកបានបញ្ជាក់ថា លោកបានបង្រៀនខ្លឹមសារនៃឯកសារនេះទៅដល់បុគ្គលិកនៅស-២១។ តើលោកនៅចាំទេ?

[១៤:៤១:២៧]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ទស្សនាវដ្ដីទង់បដិវត្ត ជាប្រភពអប់រំមនោគមន៍វិជ្ជា ទាំងខាងនយោបាយ ទាំងខាងសតិអារម្មណ៍ ទាំងខាងចាត់តាំង។ ចួនអីខ្ញុំដកស្រង់ពីត្រង់នេះ ចួនអីខ្ញុំដកស្រង់ពីត្រង់នោះ យកទៅបង្រៀនអ្នកសួរចម្លើយជាពិសេស។ ដូច្នេះ សឹងតែនិយាយថាគ្រប់ទង់បដិវត្ត ខ្ញុំបានចោះត្រង់នេះបន្តិចត្រង់នោះបន្តិចយកទៅបង្រៀន។ ដោយឡែកទង់បដិវត្តលេខនេះ ខ្ញុំមិនដឹងជាបង្រៀនត្រង់ណាខ្លះទេ បើមេធាវីចង់ដឹងច្បាស់ សូមអនុញ្ញាតលោកប្រធានទៅ សួរខ្ញុំ។ អរគុណ។

**ស៖** លោកសាក្សីទៅទំព័រ២៦ នៃអត្ថបទភាសាខ្មែរនៃទង់បដិវត្ត ERN 00185332-- សូមអភ័យទោស ជា ERN អង់គ្លេសទេ។ ខ្មែរ ERN គឺ 00064566។ នៅក្នុងចំណងជើងទីនេះនិយាយថា "តើអ្វីជាទំនាស់រវាងបដិវត្តន៍យើង និងប្រឆាំងបដិវត្តន៍តើជាទំនាស់អ្វី? កម្លាំងអ្វីដែលប្រឆាំងនឹងបដិវត្តន៍យើង?" តើលោកបានឃើញទេចំណុចនេះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំបានឃើញចំណុចទាំងអស់នេះ។

**ស៖** ឯកសារនេះក៏បានបង្ហាញលើអេក្រង់ផងដែរ។ ផ្នែកខ្លះយើងបានដាក់ប្រអប់ជាពណ៌ក្រហម ខ្ញុំនឹងពិនិត្យមើលចំណុចមួយៗ។ ប្រអប់ទីមួយមានចំណងជើងថា "ពីព្រោះបញ្ហានេះជាបញ្ហានយោបាយ។ ទីបី តាមសកលលោកធ្លាប់-- បាទសកលលោក គឺជាទំនាស់រវាងសង្គមនិយម និងនាយទុន។ បញ្ហានេះ

ត្រឹមត្រូវ ត្រឹមត្រូវជាមូលដ្ឋាន"។ ទីបួន ប្រអប់ទីបួន "ក្រោយរំដោះភ្លាម វាចាប់ផ្តើមវាយយើងភ្លាម។ តើនរណាវាយយើង? តើ សេ.អ៊ី.អា យួន កា.ហ្សេ.បេ?"

[១៤:៤៤:០៧]

ចូលទៅខាងក្រោមនៃឯកសារ ប្រអប់ទីប្រាំមួយ និយាយថា "ក្បាលដែលត្រូវវាយ គឺ សេ.អ៊ី.អា យួន និង កា.ហ្សេ.បេ។ តាំងពីឆ្នាំ១៩៧៥ មក កម្លាំងដែលវាយយើងសុទ្ធតែ សេ.អ៊ី.អា និងយួន"។ រហូតទៅខាងក្រោម កថាខណ្ឌដដែលនោះ និយាយអំពី សេ.អ៊ី.អា ដែរ។ "គ្រាន់តែ សេ.អ៊ី.អា មួយវាធ្ងន់ជាងអាមេរិកាំង អាមួយធ្ងន់ជាងយួនជាង-- ខាងយួនជាង"។

ប្រអប់នៅខាងក្រោមមួយទៀត ចង់និយាយថា "នេះចង់បញ្ជាក់ថា ពួកខ្សែក្បត់នេះ វានៅតែជាមួយ សេ.អ៊ី.អា នៅតែជាមួយយួន ហើយផ្ទៃក្នុងយួន សេ.អ៊ី.អា វាគ្របដណ្តប់ហើយ"។ នៅខាងក្រោមទៀតនោះនៅក្នុងកថាខណ្ឌនោះ ក្នុងប្រអប់នោះបាននិយាយថា "កងជំទាស់ទាំងអស់ សេ.អ៊ី.អា យួន ហើយនិងចារកិច្ចសូវៀត ហើយកម្លាំងទាំងអស់នេះ យើងត្រូវតែវាយប្រហារ"។ កថាខណ្ឌបន្ទាប់ពីហ្នឹងទៅទៀតនោះសរសេរថា "ដើម្បីសរុបទំនាស់ជាមួយយើងមាន សេ.អ៊ី.អា មានយួន ហើយនិង កា.ហ្សេ.បេ ក្នុងន័យនេះគឺជាពិសពុលជាងគេ គឺពួកយួន" ប្រអប់មួយទៅទៀតគឺថា "មួយវាយអាស្រួចជាងគេ គឺយួនឈ្លានពានវាតទីទឹកដី។ ទីពីរ ព្រមជាមួយនេះ វាយ សេ.អ៊ី.អា និង កា.ហ្សេ.បេ។ បន្ទាប់មកទៀតនោះ នៅទំព័រមួយទៀត ទំព័រ៣០ នៃឯកសារខ្មែរមានសេចក្តីថ្លែងការណ៍នៅក្នុងប្រអប់នោះគឺថា មានតែ សេ.អ៊ី.អា យួន ហើយនិងកងកម្លាំងសូវៀតទេ ដែលវាយប្រហារបដិវត្តន៍យើង។

លោកសាក្សី តើលោកអាចពន្យល់តុលាការបានទេថា តើលោកយល់អំពី សេ.អ៊ី.អា កាលសម័យនោះ គេសំដៅលើអ្វី?

[១៤:៤៦:៣៥]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន សេ.អ៊ី.អា សម័យនោះគឺសំដៅខ្មែរនៅក្នុងស្រុកខ្មែរដែលទទួលការចាត់តាំងពីភ្នាក់ងាររបស់អាមេរិក ដែលគេហៅថាភ្នាក់ងារ សេ.អ៊ី.អា។ នេះគេសំដៅអ៊ីចឹង។

**ស៖** អ្វីដែលលោកយល់ សេ.អ៊ី.អា តាមឯកសារឃោសនាតាមនេះ តាមពីទង់បដិវត្ត តើលោកនិយាយក្នុងភស្តុតាងទេដែលជាភស្តុតាង ឬក៏ជាឯកសារដែលសរសេរដោយលេខាបក្សហ្នឹងដែរឬទេ ដែលកំណត់ជា សេ.អ៊ី.អា នោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន សត្រូវស្លាប់រស់របស់បដិវត្តន៍កម្ពុជាទាល់តែលេខាបក្សបានកំណត់បាន គ្មានអ្នកណាប៉ានកំណត់ទេ។

**ស៖** សូមលោកជម្រាបតុលាការ តើយួននោះគេសំដៅរកពួកមនុស្សបែបណា?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន យួនគឺសំដៅយួនដែលនៅក្នុងទឹកដីខ្មែរ តាមពិតគឺសំដៅខ្មែរដែលមាននិន្នាការយួន។ បើនិយាយឲ្យចំគឺសំដៅកម្លាំងអតីតរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា។

[១៤:៤៨:៣៤]

**ស៖** តើមាគ៌ាបក្សនេះយ៉ាងដូចម្ដេច ទាក់ទងទៅនឹងខ្មាំងយួន?

**ឆ៖** អរគុណ។ គោលនយោបាយរបស់បក្សឲ្យតែខ្មាំង គឺត្រូវតែកម្ទេច ចាប់បានគេបញ្ជូនមកនគរបាលសួរចម្លើយអស់ហើយគេកម្ទេចចោល។

**ស៖** នៅក្នុងភស្តុតាងកាលពីអាទិត្យមុន លោកនិយាយថា សុន សាន-- អ៊ំ សុន សេន បានណែនាំឲ្យ ស-២១ ហ្នឹងគឺធ្វើម៉េចវែកមុខពួក សេ.អ៊ី.អា ពួក កា.ហ្សេ.បេ ពួកខ្មាំងយួន ហើយពួកយួនឈ្លានពានផងដែរ ដែលបក្សត្រូវតែកម្ទេច ហើយនិងសម្លាប់ចោល។ តើលោកអាចបញ្ជាក់បានទេ តើពួកក្រុមខ្មាំងហ្នឹងដែលបក្សកុម្មុយនីស្តកម្ពុជាសំដៅយកហ្នឹង គឺមានពួក សេ.អ៊ី.អា ពួក កា.ហ្សេ.បេ ពួកខ្មាំងយួន តើអ៊ីចឹងឬទេ?

[១៤:៤៩:៥០]

**ឆ៖** អរគុណ។ សត្រូវជាយុទ្ធសាស្ត្រដែលមានគ្រោះថ្នាក់ជាសត្រូវស្លាប់រស់របស់បក្សកុម្មុយនីស្តកម្ពុជា គឺបីហ្នឹងឯង សេ.អ៊ី.អា កា.ហ្សេ.បេ ហើយនិងខ្មាំងយួន ភ្នាក់ងារយួន។ គេហៅថា "ភ្នាក់ងារយួន"ៗ។

**ស៖** លោកសាក្សី ដើម្បីឲ្យយើងច្បាស់ប្រាកដនៅទីនេះ ពីព្រោះលោកបានពន្យល់ថា យួនគឺសំដៅជនជាតិយួននៅក្នុងទឹកដីខ្មែរ ហើយខ្មែរដែលមាននិន្នាការជាប់ខ្សែយួន តើលោកសំដៅរកតែជនជាតិវៀតណាម ជនជាតិយួនហ្នឹងទេ កាលណាលោកនិយាយថា យួនហ្នឹង?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ពាក្យមួយម៉ាត់ យើងស្ដាប់គ្នាច្រឡំហើយប្រហែលជាខ្ញុំនិយាយច្រឡំក៏មិនដឹង។ និយាយអំពីរកខ្មាំង-- តែអាខ្មាំងយួននៅក្នុងទឹកដីខ្មែរ ភ្នាក់ងារអាខ្មាំងយួននៅក្នុងទឹកដីខ្មែរ។ យើងអត់បានទៅចាប់ភ្នាក់ងារ-- អាខ្មាំងយួននៅក្នុងទឹកដីយួនទេ។ ដូច្នេះ

គេមិនសំដៅនេះទេ គេសំដៅភ្នាក់ងារអាខ្មាំងយួន។ ហើយបានចុងបញ្ចប់ ខ្ញុំបាននិយាយថា បក្សកុម្មុយនីស្តកម្ពុជាសំដៅទៅរក "កម្លាំងចាស់របស់អតីតបក្សប្រជាជនបដិវត្តន៍កម្ពុជា"។

**ស៖** លោកសាក្សី សូមអរគុណ។ ប៉ុន្តែយើងនៅតែច្រឡំពាក្យដែលហៅថា "យួន" ដើម្បីពន្យល់ពាក្យថា "យួន" ហ្នឹង។ អ៊ីចឹង យើងត្រូវតែឲ្យច្បាស់ តើយួនហ្នឹង មានន័យថា ជាមនុស្សជាប្រជាជន ដែលមានសញ្ជាតិ ជាតិពន្ធុ ជាវៀតណាម ឬក៏ជាមានសញ្ជាតិជាវៀតណាមហ្នឹង ឬយ៉ាងដូចម្តេច?

[១៤:៥១:៥៧]

**ឆ៖** អរគុណ។ ក្នុងការអនុវត្តជាក់ស្តែងហើយនិងក្នុងទ្រឹស្តី។ ក្នុងទ្រឹស្តី គឺគេសំដៅភ្នាក់ងារយួន ឈ្លានពានវាតទីលេបទឹកដី ប្រល័យពូជសាសន៍ អាហ្នឹងគេដាក់នាមឲ្យមកអ៊ីចឹង។ ដូច្នេះ គេសំដៅខ្មែរ ដែលមាននិន្នាការយួន។ ខ្មែរដែលនៅស្មោះត្រង់នឹងសហព័ន្ធឥណ្ឌូចិន។ និយាយមួយម៉ាត់គឺកម្លាំងរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា។ នេះគឺគេសំដៅអ៊ីចឹង។ ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង យើងឃើញទាំងអស់គ្នា ទាំងលន់ នល់ ក៏ដូច ប៉ុល ពត ឲ្យតែសញ្ជាតិយួន នៅស្រុកខ្មែរមិនបានតែម្តង។ ចេះតែមើលលើ មើលក្រោម ចាប់អារម្មណ៍។ ហ្នឹងគឺក្នុងការអនុវត្តជាក់ស្តែង វាទៅអ៊ីចឹង។ នេះ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ។

[១៤:៥៣:១៣]

**ស៖** ខ្ញុំសូមអនុញ្ញាតទៅខាងមុខទៀត។ ក្នុងការបង្ហាញភស្តុតាងកាលពីនោះ លោកនិយាយថា សុន សេន បានអប់រំ ឬក៏ព្រមាន-- គឺថាមិនឃើញមានចម្លើយសារភាពពី សេ.អ៊ី.អា ពី កា.ហ្សេ.បេ អ្វីសោះនៅស-២១។ តើលោកនៅចាំទេ ដែល សុន សេន ព្រមានលោកពីចារកមិនឃើញអ៊ីចឹង នៅចាំកាលបរិច្ឆេទទេ?

**ឆ៖** អរគុណ។ ខ្ញុំមិនចាំកាលបរិច្ឆេទទេ ក៏ប៉ុន្តែបរិយាកាសដែលគាត់ហៅខ្ញុំទៅ ពេលនោះណាត នៅជាមួយនៅឡើយទេ។ ខ្ញុំនៅជាអនុប្រធានសួរចម្លើយ។ គាត់យកក្រដាសមួយសន្លឹក តែមួយសន្លឹកគត់។ ថាឥឡូវខាងនគរបាលតំបន់៣២ គេរកឃើញ សេ.អ៊ី.អា។ វានិយាយថា សេ.អ៊ី.អា តែជ្រមុជទឹក គឺសេ.អ៊ី.អា ហើយ។ ទោះខានប្រជុំជីវភាពប៉ុន្មានឆ្នាំក៏ដោយ ក៏នៅជា សេ.អ៊ី.អា ដែរ មិនមែនដូចយើងទេ។

[១៤:៥៤:២៤]

ឥឡូវមន្ទីរតំបន់ នែ៎ មន្ទីរសន្តិសុខតំបន់៣២ គេរកឃើញ សេ.អ៊ី.អា ចុះ ស-២១ ម៉េចក៏រកឃើញ-- មិនឃើញ សេ.អ៊ី.អា ហ្នឹងគេ។ ហើយដល់ទៅគាត់មិនឲ្យខ្ញុំមើលទេ ក្រដាសហ្នឹង សេចក្ដីសារភាពហ្នឹង គាត់មិនប្រគល់មកឲ្យខ្ញុំមើលទេ។ គាត់កាន់អីអីចឹង គាត់ថាប្រធានមន្ទីរនគរបាលរបស់គេ បញ្ជាក់ថាចម្លើយនេះយកបានដោយមិនបាច់ទារុណកម្ម។ ប្រធានមន្ទីរនគរបាលរបស់គេឈ្មោះ ចាប ណម។ ដូច្នេះមកវិញ ប្រហែលពេលនោះ ប្រហែលជាក្នុងខែ១១ ឬខែ១២ អាចខែ១២ច្រើនជាង ព្រោះខ្ញុំចាំថាដូចជាមុនខ្ញុំការ។ ដល់ក្រោយមក សួរពួកមកពីសូវៀត អតីតនិស្សិតនៅរៀននៅសូវៀត។ ដល់ទៅសួរ ពួកនោះឆ្លើយថា សេ.អ៊ី.អា។ ដល់ សេ.អ៊ី.អា សុន សេន គាត់ថា អ្ហឺ! សូវៀត សេ.អ៊ី.អា ម៉េចទេវ៉ី? បានទៅសួរម្ដងទៀត ថាចារបុរស អង្គការចារកម្មរបស់សូវៀតនោះឈ្មោះ កា.ហ្សេ.បេ ប្រែថា "គណៈកម្មាធិការជាតិខាងព័ត៌មាន"។ លេចចេញ កា.ហ្សេ.បេ មួយទៀត សេ.អ៊ី.អា, កា.ហ្សេ.បេ។ បានក្រោយមកទៀត បាន១លេចចេញបក្សកំណត់ខ្មាំងសត្រូវទីបី ហើយសំខាន់ជាងគេ គឺភ្នាក់ងារយួនលេបទឹកដី។ កុំភ្លេចភ្នាក់ងារមួយម៉ាត់។ ដូច្នេះ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

[១៤:៥៦:០១]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទីចាប់ ពីពេលនេះ រហូតដល់ម៉ោងបីដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ អនុរក្សមន្ទីរឃុំឃាំងអញ្ជើញសាក្សីទៅកាន់បន្ទប់សម្រាក ហើយនិងឲ្យអញ្ជើញគាត់មកកាន់បន្ទប់សវនាការវិញនៅម៉ោងបីដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៥៦ នាទី ដល់ម៉ោង ១៥:១៤ នាទី)*

[១៥:១៤:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តនេះ សូមផ្តល់វេទិកាជូនទៅដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលសិទ្ធិ។

លោកៗ មេធាវីអន្តរជាតិការពារក្តី នួន ជា ចង់មានបញ្ហាអីទេ?

សូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិន៖**

សូមអភ័យទោសលោកប្រធាន ដែលខ្ញុំក្រោកឈរម្តងទៀត។ ខ្ញុំមានសំណួរមួយចំនួនដោយហេតុថា ជាក់ស្តែងនោះ លោកប្រធាន លោកបានបញ្ជាក់បញ្ហាមួយចំនួនអំពី ពីថ្ងៃជូនទៅមេធាវីការពារដើម្បីសួរដេញដោលសាក្សីសរុប ដែលមិនត្រូវបានបកប្រែច្បាស់លាស់ទៅជាអង់គ្លេសសោះ។ ខ្ញុំមិនយល់ច្បាស់ថា តើខ្ញុំបានទទួលព័ត៌មានច្បាស់លាស់ពីលោកប្រធានដែរឬអត់? ថាតើមានពេលបីថ្ងៃសម្រាប់ក្រុមមេធាវីគ្រប់ក្រុមទាំងអស់ ឬក៏ប៉ុន្មានលោកប្រធានបាទ?

[១៥:១៥:១៥]

**ប្រធានអង្គជំនុំ៖**

បាទ តាមពេលវេលាដែលបានគ្រោងទុកនេះ គឺក្រុមមេធាវីការពារក្តីទាំងបីក្រុមមានពេលវេលាបីថ្ងៃ ចាប់ពីស្អែកទៅ។ ហើយអង្គជំនុំជម្រះក៏មិនទាន់កំណត់ឲ្យបានជាក់ច្បាស់ដែរ លើបញ្ហាថាតើពេលវេលាដូច្នេះហ្នឹងត្រូវបែងចែកយ៉ាងដូចម្តេច? វាអាស្រ័យទៅលើភាគីមេធាវីទាំងបីក្រុម។ ពីព្រោះការអនុវត្តក្នុងកិច្ចដំណើរការសួរដេញដោលកន្លងមក គឺទាំងបីក្រុមហ្នឹងតែងតែមានការប្រើប្រាស់ពេលវេលាខុសគ្នា។ មានក្រុមមេធាវីខ្លះក៏ប្រើប្រាស់ពេលវេលាហ្នឹងច្រើនវែងទៅ ហើយមេធាវីក្រុមខ្លះក៏ប្រើប្រាស់ពេលវេលាហ្នឹងតិចទៅ ហើយរហូតដល់មានមេធាវីក្រុមខ្លះហ្នឹងមិនបានប្រើសិទ្ធិរបស់ខ្លួននៅក្នុងការតាំងសំណួរទេ រយៈពេលកន្លងមក ទោះបីគាត់បានស្នើសុំតាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ថាគាត់ត្រូវការពេលវេលាកន្លះថ្ងៃ ឬក៏ពេលវេលាប៉ុណ្ណោះ ប៉ុណ្ណោះក៏ដោយ។ ដល់ទីបញ្ចប់ គឺគាត់មិនបានប្រើប្រាស់ពេលវេលានោះទេ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះបានលើកឡើងអំមិញថា បីថ្ងៃចុងក្រោយនៃសប្តាហ៍នេះ គឺដល់វេទិការបស់មេធាវីការពារក្តីក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[១៥:១៦:៣៨]

អ៊ីចឹងហើយបានជាអង្គជំនុំជម្រះមិនផ្តល់ពេលវេលាឲ្យទៅមេធាវីការពារក្តី នាំមុខតំណាងដើម

បណ្តឹងរដ្ឋប្បវេណីនូវពេលវេលាបន្ថែមសម្រាប់ពេលស្អែកនោះទេ។ ដោយមានការបង្ហាញពីមេធាវី អឺ! ម៉ៃខល កាណាវ៉ាស ផង។

**លោក ម៉ៃខល ផេសមិន៖**

ដោយសារយើងខ្ញុំបានបញ្ជាក់ខាងថាដើមថា គាត់មិនដឹងថាយើងត្រូវការប្រើពេលប៉ុន្មាននោះទេ គឺអាស្រ័យទៅលើសំណួរដែលសួរ ហើយនិងចម្លើយដែលឆ្លើយទៅនឹងសំណួរ។ ការប៉ាន់ប្រមាណរបស់ខ្ញុំហ្នឹង គឺថាយើងនឹងត្រូវការប្រហែលជាពីរថ្ងៃសម្រាប់ការសួរដេញដោលរបស់យើង។ មិនដឹងថាក្រុមផ្សេងទៀត លោកត្រូវការប៉ុន្មានទេបាទ។

[១៥:១៧:៣៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ចំពោះរូបខ្ញុំ គឺថាជាបឋម ទាក់ទងនឹងថារយៈពេលនៃការសំណួរសួរដេញដោលទៅលើសាក្សីរូបនេះ គឺខ្ញុំចង់គូសបញ្ជាក់បង្ហាញនូវការលំបាកដ៏សម្បើមដែលថាមានលក្ខណៈមិនច្បាស់លាស់នៃនីតិវិធី ទាក់ទងទៅនឹងរបៀបនៃការប្រើប្រាស់ធាតុផ្សំរបស់អង្គជំនុំជម្រះ។ ខ្ញុំពន្យល់មូលហេតុ ខ្ញុំបានពិភាក្សាជាមួយភាគីដែលមានវត្តមាននៅទីនេះ លើកលែងតែខាងសហព្រះរាជអាជ្ញា ហើយគ្មាននរណាម្នាក់ដែលអាចឆ្លើយទៅនឹងសំណួរដូចតទៅនេះទេ។

នៅចុងបញ្ចប់នៃការជម្រះសេចក្តីនេះ តុលាការនឹងធ្វើសេចក្តីសម្រេច ហើយនិងនៅក្នុងក្របខ័ណ្ឌនៃការសម្រេចនេះ តើតុលាការនឹងប្រើប្រាស់នូវសំណុំឯកសារទាំងស្រុងតែម្តង? ឯកសារនៃការស៊ើបសួរ ឬក៏កំណត់មកត្រឹមតែឯកសារដែលខ្លួនយល់ឃើញថា ឯកសារទាំងអស់នេះបានបង្ហាញនៅក្នុងសវនាការ ហើយនិងដេញដោលពិភាក្សាជាសាធារណៈ ហើយនិងដែលបានទទួលលេខសម្គាល់សមស្រប ដែលមានថាចំណាត់ថ្នាក់សមស្រប។

[១៥:១៩:២៩]

ខ្ញុំនិយាយអំពីបញ្ហានេះ ពីព្រោះថានៅពេលដែលយើងចោទសំណួរទៅមនុស្សម្នាក់។ ឧទាហរណ៍ជាពិសេស គឺថាដូចលោកសាក្សីនេះជាដើមដែលថាគាត់ហ្នឹងត្រូវបានគេស្តាប់៦៥ដង នៅក្នុងការ-- នៅដំណាក់កាលស៊ើបសួរនោះ។ អ៊ីចឹងតុលាការ បើសិនជាតុលាការប្រើនូវការសក្ខីកម្ម របស់គាត់

នោះទាំង៦៥ដងនោះ នេះគឺថាវាជាបញ្ហាមួយ ហើយបើសិនជាអង្គជំនុំជម្រះយកតែប្រតិចារឹក ឬក៏ឯកសារដែលបង្ហាញនៅក្នុងបន្ទប់សាលសវនាការនេះ វាជារឿងផ្សេងមួយទៀត។ ដូច្នេះ ខ្ញុំមិនមែនជាមនុស្សតែម្នាក់ឯងនោះទេ ក្នុងការចោទសំណួរនេះ។ អ៊ីចឹងត្រូវតែផ្តល់សារៈសំខាន់ទៅលើចំណុចនេះ ហើយដើម្បីឲ្យយើងអាចដឹងថា-- ចំណុចមួយទៀតគឺថាយើងត្រូវការរយៈពេល-- ដឹងថារយៈពេលប៉ុន្មានដើម្បីសួរទៅលើសាក្សីនេះ។

**ប្រធានអង្គជំនុំ៖**

លោកត្រូវការពេលប៉ុន្មានទៅជាក់ស្តែងអំមិញគឺខាងមេធាវីការពារក្តីលោក នួន ជា បានបង្ហាញ ហើយគេស្នើសុំប្រមើលមើលប្រហែលជាពីរថ្ងៃ ចំណែកឯលោកប្រហែលជាប៉ុន្មាន-- ប្រមើលមើលប្រហែលជាប៉ុន្មានទៅ? ពីព្រោះមានក្រុមការពារក្តីមួយចំនួនដូចជាការបទពិសោធន៍របស់អង្គជំនុំជម្រះបានជួប គឺថាស្នើសុំពេលវេលាមួយថ្ងៃ ឬក៏កន្លះថ្ងៃ ប៉ុន្តែដល់ពេលដេញដោលទៅបន្ទាប់ពីក្រុមមេធាវីការពារក្តីផ្សេងទៀតតាំងសំណួរចំពោះសាក្សីជាក់លាក់ ឬក៏អ្នកជំនាញខ្លួនថាមិនមានសំណួរអ្វីទេសួរទេ។

[១៥:២១:១២]

អ៊ីចឹងវាការលៃលកពេលវេលានៅក្នុងការបែងចែកពេលវេលាវាជាការលំបាក ពីព្រោះអង្គជំនុំជម្រះ បានជម្រាបហើយលើបញ្ហានៃការកំណត់ពេលវេលាក្នុងការបែងចែកសម្រាប់ភាគី ក្នុងការសួរដេញដោលទៅលើគោលដៅសាក្សីនីមួយៗ ទៅលើដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ទៅលើអ្នកជំនាញនីមួយៗ។ វាមានលក្ខណៈខុសគ្នាអាស្រ័យទៅលើការយល់ដឹងរបស់គាត់ ដែលគាត់បានដឹងពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់មកធ្វើសវនាការ ដោយមិនដូច ដូចគ្នាទេ។ អ៊ីចឹងហើយបានជាការកំណត់ពេលវេលាក្នុងការបែងចែកពេលវេលា គឺអង្គជំនុំជម្រះមិនទាន់ប៉ានកំណត់ឲ្យបានជាក់ច្បាស់នៅឡើយទេ ចំពោះសាក្សី តាំងពីដើមទីរហូតដល់ពេលនេះ។ ដោយសារយើងលៃពេលវេលាក្នុងការគិតគូរពិចារណាអំពីលទ្ធភាពក្នុងការធ្វើសក្តីកម្ម ក្នុងការសួរដេញដោលនេះ វាមិនបានច្បាស់លាក់ទេ។ វាមិនអាចកំណត់ដូចៗគ្នាបានទេ។ អ៊ីចឹងហើយបានជាការប៉ាន់ប្រមើលមើលនៅពេលដែលដំណើរការ ហើយនិងការស្នើសុំរបស់ភាគីតាមរយៈកិច្ចប្រជុំនៅថ្ងៃសុក្រ ជាមួយនិងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដើម្បីឲ្យអង្គជំនុំជម្រះមានមូលដ្ឋានគិតគូរពិចារណាលើមូលដ្ឋាននោះជាបឋម។ បន្ទាប់មក គឺដើម្បីកំណត់នូវបញ្ហាជាក់ស្តែងនៅពេលដែល តម្រូវការជាក់ស្តែងនៃការសួរដេញដោល។

[១៥:២២:៣៥]

ទោះបីយ៉ាងណាក៏ដោយអង្គជំនុំជម្រះក៏បានគិតគូរផងដែរថា ប្រសិនបើសួរសំណួរនីតិវិធីសួរច្រំដែល សួររបៀបមិនជាក់ច្បាស់អ៊ីចឹងគឺធ្វើឲ្យខាតពេលវេលា អង្គជំនុំជម្រះក៏រំឭកភាគីរួចហើយ ជាក់ស្ដែងព្រឹកមិញយើងបានរំឭកគូភាគីរួចហើយ អំពីបញ្ហានៃចំណាត់ការដើម្បីធ្វើឲ្យការប្រើប្រាស់ពេលវេលាមានប្រសិទ្ធភាព។

**លោក អាកទួរ វែកកែន៖**

បាទ លោកប្រធាន ខ្ញុំយល់នូវបញ្ហារបស់តុលាការ។ ខ្ញុំយល់ទាំងស្រុង ដោយអាស្រ័យដោយហេតុនេះហើយ ដូច្នេះហើយបានថា ដើម្បីឲ្យឆ្លើយតបទៅនឹងការព្រួយបារម្ភរបស់តុលាការនេះ យើងខ្ញុំសូមឲ្យបំភ្លឺឲ្យបានឆាប់បំផុតប្រសិនជាអាចធ្វើបាននោះ ឥឡូវតែម្ដង។ ឆ្លើយតបតែពីររបៀបដែលនៃដំណើរការសវនាការនេះ។ ខ្ញុំចង់ដឹងឲ្យបានច្បាស់តែម្ដង ហើយខ្ញុំចង់-- ខ្ញុំចង់ដឹងថាត្រូវពេលវេលាប៉ុន្មានដើម្បីចោទសួរទៅសាក្សីនេះ? ខ្ញុំចង់ដឹងផងដែរ នូវឯកសារដែលអង្គជំនុំជម្រះនឹងប្រើ ដើម្បីធ្វើសេចក្ដីសម្រេចនៅពេលក្រោយ។ បើសិនជាយកឯកសារនៃដំណាក់កាលស្រាវជ្រាវស៊ើបអង្កេតទាំងអស់នោះ គឺថាវាតម្រូវឲ្យមានការចោទសួរដេញដោលនេះវែង ពីព្រោះថាវាមិនពាក់ព័ន្ធតែភស្តុតាងដែលបង្ហាញនៅក្នុងសវនាការនេះទេ។

[១៥:២៤:២៨]

ក៏ប៉ុន្តែផ្ទុយទៅវិញ បើសិនជាតុលាការជម្រាបមកយើងថា ឯកសារតុលាការនឹងប្រើដើម្បីធ្វើជាមូលដ្ឋាន ធ្វើសេចក្ដីសម្រេចនោះ គឺថាគ្រាន់តែជាឯកសារ ប្រតិចារឹកនោះ ឬក៏ថាឯកសារដែលបានទទួលកំណត់សម្គាល់ចំណាត់ថ្នាក់នោះ នេះវាធ្វើកំណត់ពេលវេលានៃការសួរដេញដោលផ្សេងទៀត។ ដូច្នេះ ខាងការពារក្ដីក៏ដូចជាខាងសហព្រះរាជអាជ្ញាដែរ គឺថាយើងត្រូវការដឹង ឬក៏ទទួលបានចម្លើយច្បាស់លាស់ ហើយសាមញ្ញ ហើយចាប់ពីពេលនោះទៅគឺថា យើងអាចឆ្លើយតបទៅនឹង នៃការព្រួយបារម្ភរបស់តុលាការ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារក្ដីលោក អៀង សារី តើមានបញ្ហាអីទេលើការ-- លើនីតិវិធីនៃការដេញដោលទាំងពេលវេលាផងដែរ សម្រាប់សួរសាក្សីរូបនេះ?

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៦:៥៧]

សូមអញ្ជើញលោក ម៉ែខល កាណាវាស!

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ មកដល់ពេលនេះ ខ្ញុំបានរៀបចំខ្លួនសម្រាប់ពីរថ្ងៃសម្រាប់ការតាំងសំណួរ ក៏ប៉ុន្តែគឺផ្អែកទៅលើថាតើខ្ញុំត្រូវការប៉ុណ្ណឹង ឬក៏អត់ គឺវាអាស្រ័យទៅលើអ្វីទាក់ទងទៅនឹងក្រុម នួន ជា ហើយនិងដើម្បីខ្ញុំជាមូលដ្ឋាន ដើម្បីកែតម្រូវថាតើគាត់បានគ្របដណ្តប់លើផ្នែក ដែលខ្ញុំនឹងបម្រុងសួរដែរឬក៏អត់? អ៊ីចឹង បើសិនជាមានការគ្របដណ្តប់ហើយ ខ្ញុំអាចជម្រាបតុលាការថា ប្រហែលខ្ញុំត្រូវការតែមួយថ្ងៃទេ។ ខ្ញុំព្យាយាមធ្វើម៉េចឲ្យមានប្រសិទ្ធភាពបំផុត ប៉ុន្តែខ្ញុំត្រៀមពីរថ្ងៃមុននឹងខ្ញុំមកអង្គុយចុះ ខ្ញុំថា ហើយប្រហែលជាយើងបានធ្វើឲ្យខាតពេលជិតកន្លះម៉ោងរបស់ដើមបណ្តឹងរដ្ឋប្បវេណីហើយ។ ដូច្នេះយើងឃើញថា ដើម្បីឲ្យយុត្តិធម៌ ដើម្បីនឹងផ្តល់ពេលឲ្យគាត់មួយម៉ោងសម្រាប់ថ្ងៃស្អែក ដោយសារគាត់ខាតពេលថ្ងៃនេះច្រើនណាស់។ សូមអរគុណលោកប្រធាន និងតុលាការ។

[១៥:២៨:១១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតបទៅមេធាវីការពារក្តីលោក ខៀវ សំផន គឺថា អាចជាជំហររបស់សហព្រះរាជអាជ្ញា គឺថាសាក្សីទាំងអស់-- ចម្លើយរបស់សាក្សីពីមុនទាំងអស់គឺថានឹងត្រូវយកមកពិចារណា ហើយនិងសក្ខីកម្មរបស់គាត់ពីមុន អង្គជំនុំជម្រះបានសម្រេចរួចមកហើយថា សេចក្តីថ្លែងការណ៍របស់គាត់ពីមុន គឺត្រូវដាក់ថាចំពោះមុខអង្គជំនុំជម្រះហើយ ក៏យើងអាចសួរដេញដោលបានតាមទម្លាប់អនុវត្តក្រមព្រហ្មទណ្ឌអន្តរជាតិ គឺទាក់ទងទៅនឹងសកម្មភាព និងអំពើរបស់ជនជាប់ចោទ គឺសាក្សីត្រូវតែមានវត្តមានសម្រាប់សួរដេញដោល។ ឥឡូវនេះ គាត់មកវត្តមានហើយ យើងស្នើតុលាការថា យើងសូមបញ្ជាក់ថា រាល់សេចក្តីថ្លែងការណ៍ និងចម្លើយរបស់គាត់ ពីមុនទាំងអស់ នឹងត្រូវរាប់ចូលជាឯកសារសម្រាប់ដាក់ដេញដោល ហើយនិងប្រើប្រាស់នៅក្នុងសវនាការនេះ។

[១៥:២៩:២២]

**ប្រធានអង្គជំនុំ៖**

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព។ ខ្ញុំមានការកត់សម្គាល់ពីរបី ជាបឋមគឺលើអ្វីដែលលើកដោយភាគីការពារក្តី ទាក់ទងនឹងពេលវេលាដែលយើងស្នើសុំ ខ្ញុំគិតថា ជាការលំបាកណាស់ក្នុងការវាយតម្លៃពេលវេលា ឲ្យបានច្បាស់លាស់ដោយមិនពាក់ព័ន្ធទៅនឹងឯកសារនោះ ព្រោះថា ឥឡូវនេះ យើងមិនទាន់ដឹងអំពីសំណួរដែលភាគីផ្សេងៗទៀត នឹងចោទសួរនោះទេ។ ដូច្នេះ យើងគ្រាន់តែអាចធ្វើការប៉ាន់ប្រមាណ ហើយខ្ញុំយល់គឺថាខាងភាគីការពារក្តីនោះមិនអាច-- ដូចយើងផងដែរ គឺថាមិនអាចកំណត់ពេលវេលាច្បាស់លាស់មួយ។

[១៥:៣០:១២]

ទាក់ទងទៅនឹងបញ្ហាឯកសារ ខ្ញុំគិតថាត្រូវតែបំភ្លឺនូវអ្វីដែលគេថាជាឯកសារតុលាការយកទៅធ្វើការពិភាក្សាសម្រេច។ ចំពោះខ្ញុំ ខ្ញុំគិតថាជាការ វាច្បាស់ណាស់នៅថារាល់ឯកសារដែលបង្ហាញនៅក្នុងសាលសវនាការអាចយកទៅប្រើពិភាក្សាសម្រេចបាន ក៏ប៉ុន្តែប្រហែលជាយើងសូមឲ្យតុលាការពន្យល់អំពីឯកសារ ដែលថាបង្ហាញនៅក្នុងសាលសវនាការ ហើយឯកសារ-- បើសិនជាមានការប្រែប្រួលក្នុងការយកឯកសារទៅធ្វើមូលដ្ឋាននេះ ប្រហែលជាពេលវេលាសួរដេញដោលនឹងអាចអូសបន្លាយ ហើយខ្ញុំសូមចូលដល់និយាយរឿងពេលវេលាដែលយើងសុំនេះ គឺថាយើងមានការយល់គ្នាមិនច្បាស់ ទាក់ទងនឹងការសុំពន្យារពេល។ ខ្ញុំមិនសុំថា ឲ្យរយៈពេលម៉ោងនោះវាច្រើនទៀតទេ ក៏ប៉ុន្តែព្រឹកមិញនេះយើងបានចាប់ផ្តើមដោយយឺតកន្លះម៉ោងដោយសារមានបញ្ហា ដែលមិនពាក់ព័ន្ធនឹងយើងនោះទេ។ អ៊ីចឹងដូច្នេះយើងសូមឲ្យយើងទាំងអស់គ្នាហ្នឹងគឺថា អាចយកពេលវេលា៣០នាទីនេះមកវិញ ឬក៏ថា-- ២៥នាទីទៀតនេះដែលយើងកំពុងតែយើងពិភាក្សាពីបញ្ហាមួយដ៏សំខាន់។ ដូច្នេះខ្ញុំសប្បាយចិត្តណាស់ដែលថាសហការីខាង អៀង សារី នេះ ក្រុមមេធាវី អៀង សារី បានផ្តល់មកឲ្យយើងកន្លះម៉ោងឥឡូវ២៥នាទីទៀត អ៊ីចឹងបានន័យថាមួយម៉ោង។

[១៥:៣១:៥៧]

អ៊ីចឹងបើសិនជាយើងអាចបានរយៈពេលមួយម៉ោងនៅពេលព្រឹកស្អែកនោះ ជាការប្រសើរហើយ ពីព្រោះថាឥឡូវនេះយើងខាតពេលអស់៤៥នាទីបាត់ទៅហើយ ហើយនេះមិនមែនជាការកំហុសរបស់

យើងនោះទេ។ អ៊ីចឹងយើងសុំឱ្យតុលាការផ្ដល់ពេលឱ្យយើងមួយម៉ោងនៅព្រឹកស្អែក។ ហើយជារឿងធម្មតាទេដែលថា ភាគីអាចសុំរយៈពេលបន្ថែម បើសិនជាយល់ឃើញថាជាការចាំបាច់។ ហើយខ្ញុំគិតថាយើងមិនគួរកំណត់ពេលវេលាការពិភាក្សានេះនោះទេ បើសិនជាភាគីយល់ឃើញថាជាការសំខាន់ក្នុងការបង្ហាញឯកសារមួយ ដោយយើងត្រូវការពេលចាំបាច់មួយក្នុងការបង្ហាញឯកសារនោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីឱ្យលោក ខៀវ សំផន! ហើយជាការលើកចុងក្រោយរបស់លោកផងនៅសម្រាប់រសៀលនេះ!

[១៥:៣២:៥០]

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំ បាទខ្ញុំចង់បញ្ជាប់ទៅលើបញ្ហានេះ។ បាទ ខ្ញុំគ្រាន់តែចង់ឆ្លើយតបទៅនឹងលោកសហព្រះរាជអាជ្ញា និងចង់និយាយថាខុសស្រឡះអំពីអ្វីដែលគាត់និយាយ គឺថាការអនុវត្តនៅតុលាការអន្តរជាតិនេះ គឺថាវាមិនដូច្នោះនោះទេ ដូចអ្វីដែលគាត់បានលើកឡើងនោះទេ គឺថាយើងប្រើនីតិវិធីភាសាខាងបារាំង ហើយគឺថានៅពេលពិភាក្សាសម្រេចនោះ គឺថាត្រូវតែយកតែឯកសារដែលយើងបានបង្ហាញក្នុងសវនាការនេះទេ ហើយខ្ញុំសូមរំឭកផងដែរថា នៅប្រទេសបារាំងនីតិវិធីបារាំងនោះ វាដូចហ្នឹងនីតិវិធីយើងនេះដែរ គឺថាគេពិភាក្សាគ្នា ចៅក្រមពិភាក្សាគ្នា ដោយតែលើឯកសារដែលបង្ហាញជូននៅក្នុងអង្គជំនុំជម្រះនោះទេ។ ឧទាហរណ៍ដូចជារឿងករណីក្ដីនៅរវ៉ាន់ដា គឺថាខុសស្រឡះពីអ្វីដែលលោកសហព្រះរាជអាជ្ញាបានលើកឡើង គឺថាចៅក្រមបានមិនៗមែនពិចារណា ឬក៏យកឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងជាមូលដ្ឋាននោះទេ។ នេះពិតជាមិនត្រឹមត្រូវទាល់តែសោះ។

[១៥:៣៤:១១]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅចង់ចុងក្រោយដែរលោក ផេសមិន? នេះជាចុងក្រោយរបស់លោក ឬក៏លោកត្រូវអាចអង្គុយលើក ងើបរបៀបនេះប៉ុន្មានដងទៀតនៅរសៀលនេះ សម្រាប់រសៀលនេះ?

**លោក ម៉ៃខល ផេសមិន៖**

នេះជាលើកចុងក្រោយហើយ វាមានលក្ខណៈច្រឡំដោយសារតែមានការពិភាក្សាគ្នាពីរលើចំណុចពីរពេលតែមួយ។ ហើយខ្ញុំមិនបានឮមេធាវីខាង ខៀវ សំផន លើកឡើងជំហរទៅលើបញ្ហាជាក់

លាក់មួយ។ ដូច្នេះខ្ញុំគិតថា យើងឃើញដូចជាមានបញ្ហាពីរបីប្អូននៅត្រង់ចំណុចនេះ ក៏ប៉ុន្តែតាមអ្វីដែលខ្ញុំបានស្តាប់សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺពួកគាត់សរុបទៅប្រហែលជាប្រាំមួយថ្ងៃឯណោះ ក្នុងការតាំងសំណួររបស់គាត់ គាត់ មានរយៈពេលប្រាំមួយថ្ងៃកន្លះ។ ដូច្នេះហើយខ្ញុំក៏មានសិទ្ធិទទួលនូវការដេញដោលសាក្សីក្នុងពេលវេលាមួយសមតុល្យ។ ការពិភាក្សារបស់យើងនេះ គឺយើងក៏ត្រូវគិតពិចារណាអំពីតម្លៃនៃឯកសារជាភស្តុតាងនៅ-- ចំពោះឯកសារនៅចំពោះមុខចៅក្រមស៊ើបអង្កេត។

[១៥:៣៥:២៦]

យើងបានពិភាក្សាទៅលើបញ្ហាឯកសារនេះជាមួយនឹងខាងមន្ត្រីច្បាប់ជាន់ខ្ពស់។ លោកស្រីក៏បានជម្រាបខ្ញុំផង ខ្ញុំកត់ត្រាទុកហើយ។ លោកស្រីគាត់គិតថា អង្គជំនុំជម្រះសាលាដំបូងគិតថាមានតែដំណាកស្រង់ចេញពីឯកសារជាក់លាក់តែប៉ុណ្ណោះ ដែលបាន-- ដែលអនុញ្ញាតឲ្យប្រើប្រាស់ដេញដោលជាមួយសាក្សីរូបនេះ។ ដូច្នេះយើងមិនអាចយកសេចក្តីប្រកាសណាមួយ ឬក៏ឯកសារណាផ្សេងមកធ្វើការដេញដោលនៅចំពោះសាក្សីនេះ ក្នុងតុលាការនេះឡើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណ លោកប្រធាន។ ខ្ញុំគិតថា មានចំណុចមួយចំនួនមានលក្ខណៈច្រឡំគ្នានៅទីនេះ។ ទីមួយគឺសហព្រះរាជអាជ្ញាមិនស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកកំណត់ហេតុរបស់សាក្សីរូបនេះ និងប្រតិចារឹកដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះទេ។ យើងខ្ញុំបានដាក់នៅក្នុងបញ្ជីហើយ ឯកសារប្រតិចារឹកណាខ្លះដែលយើងស្នើសុំដាក់បញ្ចូល ហើយអង្គជំនុំជម្រះបានបញ្ជាក់ហើយថា នៅពេលដែលសាក្សីចូលខ្លួន ឯកសារទាំងអស់នោះគឺវាជាឯកសារដែលយើងត្រូវយកមកពិនិត្យនៅចំពោះមុខអង្គជំនុំជម្រះ។ សាលាក្តី អាយ.ស៊ី.ធី.វ៉ាយ យើងដឹងហើយថា ប្រសិនបើសាក្សីចូលខ្លួន សក្ខីកម្ម ចម្លើយរបស់សាក្សីរូបនេះអាចដាក់បញ្ចូលបានស្របជាមួយនឹងសក្ខីកម្មដែលផ្តល់នៅក្នុងតុលាការ។

[១៥:៣៧:០២]

ដូច្នេះចម្លើយរបស់សាក្សីនេះ អាចឲ្យអង្គជំនុំជម្រះយកមកពិចារណាក្នុងករណីដែលសាក្សីមិនចូលខ្លួនក៏ដោយ ដែលយើងអាចពិចារណាទៅលើទង្វើរបស់ជនជាប់ចោទ។ ដូច្នេះហើយសាក្សីរូប

នេះមកផ្តល់សក្ខីកម្ម ផ្តល់សក្ខីកម្មលើចម្លើយរបស់គាត់។ ដូច្នេះសេចក្តីអនុវត្តរបស់តុលាការអន្តរជាតិបានន័យថា សក្ខីកម្មរបស់គាត់រួមទាំងចម្លើយរបស់គាត់ផងដែរ អាចយកមកដាក់នៅចំពោះមុខអង្គជំនុំជម្រះឲ្យគិតគូរបាន។

[១៥:៣៧:៣៦]

**លោក ម៉ៃខល កាណាវាស៖**

មេធាវីសូមអភ័យទោសលោកប្រធាន ខ្ញុំសុំអភ័យទោស។

**ប្រធានអង្គជំនុំ៖**

យើងអត់ទាន់ឲ្យនិយាយផង។ អត់ទាន់សុំយើងផង។

សុំទេ? ឥឡូវលោកសុំនិយាយទេឬក៏លោកចុចក្បាលមេក្រូនិយាយអ៊ីចឹង ព្រោះលោកបានសន្យារួចហើយថាមុននឹងនិយាយគឺសុំអនុញ្ញាតពីយើង។

ឥឡូវនេះយើងសម្រេចបញ្ហាទីមួយ លើការខកខាននៃការចំណាយពេលវេលាដល់ការសួរដេញដោលរបស់ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះសាក្សីរូបនេះ។ ដោយសារមានការខកខានព្រឹកមិញលើបញ្ហាស្ទះផ្លូវ អង្គជំនុំជម្រះមានបំណងថា ពន្យារការដេញដោលរសៀលនេះរហូតដល់ម៉ោងបួនម្ភៃនាទី។ ប៉ុន្តែមិននឹកស្មានថា អំឡុងពេលដែលយើងចូលមកនេះ ការត្រៀមរបស់យើងត្រូវបានគិតខុស ដោយសារមូលហេតុជ្រៀតជ្រែក ជ្រៀតនូវបញ្ហាផ្សេងៗដោយភាគីទៅលើបញ្ហានានាពាក់ព័ន្ធនឹងការដេញដោល ដែលរហូតមកដល់ពេលនេះនៅតែមិនទាន់ជ្រះស្រឡះនៅឡើយ។

[១៥:៣៨:៥៤]

អ៊ីចឹង នាំឲ្យខាតពេលវេលារបស់ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ អ៊ីចឹងដើម្បីជាក់ច្បាស់ ហើយមានសមានចិត្តបានបង្ហាញជំហរថា គប្បីបន្ថែមពីក្រុមមេធាវីការពារក្តីលោក អៀង សារី ផង ដែលមានការគាំទ្រ គឺអង្គជំនុំជម្រះសម្រេចបន្ថែមពេលវេលាឲ្យក្រុមមេធាវីការពារ-- មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនូវពេលវេលាមួយម៉ោងសម្រាប់ព្រឹកថ្ងៃស្អែក ដើម្បីបន្តការតាំងសំណួរចំពោះសាក្សីរូបនេះ។

[១៥:៣៩:២៩]

បញ្ហាទីពីរ ចំពោះពាក់ព័ន្ធទៅនឹងឯកសារដែលត្រូវធ្វើជាមូលដ្ឋាននៅក្នុងការសម្រេចសេចក្តីអង្គជំនុំជម្រះយល់ឃើញថា នៅក្នុងវិធាននៃភស្តុតាងត្រង់កថាខណ្ឌ៣ អង្គជំនុំជម្រះគិតថាមិនទាន់មាន

ការវិសោធនកម្មកែប្រែឲ្យផ្ទុយពីនេះទេ។ អង្គជំនុំជម្រះជាក់ស្តែង យើងជាភាគីជាតិនៃអង្គជំនុំជម្រះសាលាដំបូង មិនទាន់មានគំនិតឯណាថា ឲ្យដើរខុសពីខ្លឹមសារនៃវិធាន៨៧(៣) នៃវិធានផ្ទៃក្នុងនេះទេ។

វិធាន៨៧(៣)៖ "អង្គជំនុំជម្រះដំបូងធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង។ ប្រសិនបើភាគីយកភស្តុតាងទាំងនោះមកដាក់ចំពោះមុខអង្គជំនុំជម្រះ ឬប្រសិនបើ អង្គជំនុំជម្រះខ្លួនឯងយកភស្តុតាងទាំងនោះ មកដាក់នៅចំពោះមុខភាគី។ ភស្តុតាងដែលមានសំណុំរឿង ត្រូវចាត់ទុកថាបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី ប្រសិនបើខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬត្រូវបានកំណត់អត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ"។ នេះជាខ្លឹមសារមូលដ្ឋាននៃឯកសារធ្វើជាមធ្យោបាយសម្រាប់ឈានដល់ការគិតពិចារណាក្នុងការសម្រេចសេចក្តី។

[១៥:៤១:០៥]

បញ្ហាទីពីរ ដោយសារអង្គហេតុចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយមានទំហំធំធេង អង្គជំនុំជម្រះបានអនុវត្តតាមវិធាន៨១-- វិធាន៨៩ ស្ទួន២ បំបែកកិច្ចដំណើរការនីតិវិធីយកមកដេញដោលនៅក្នុងដំណាក់កាលដំបូងនៃកិច្ចដំណើរការសវនាការនេះ គឺសំណុំរឿង០០២/០១។

នេះជាដែនកំណត់ដែលនាំឲ្យគិតគូរមួយជំហានទៀត វាខុសពីដីកាដំណោះស្រាយ។ វិសាលភាពនៃការដេញដោលនៅក្នុងដំណាក់កាលដំបូងនេះ គឺក្នុងក្របខ័ណ្ឌសំណុំរឿង០០២/០១។ ដែលនៅក្នុងនោះ អង្គជំនុំជម្រះបានកំណត់នូវបណ្តាកថាខណ្ឌពាក់ព័ន្ធជាលេខ ដែលដកស្រង់ចេញពីកថា-- ដីកាដំណោះស្រាយយ៉ាងជាក់ច្បាស់រួចហើយ ហើយជូនភាគីរួចហើយ។ ក្នុងករណីមានការវិសោធនកម្ម ឬក៏មានការកែប្រែដកចេញ ឬក៏ដកចេញ ដូចជាករណីពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ គឺអង្គជំនុំជម្រះបានសម្រេចដកចេញរួចហើយ តាមអនុស្សរណៈបន្ថែម។

[១៥:៤២:២២]

ដើម្បីបញ្ជាក់បញ្ហានេះឲ្យបានច្បាស់លាស់ និងជ្រះស្រឡះ ហើយអង្គជំនុំជម្រះសូមប្រគល់វេទិកានេះ ជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបញ្ជាក់បន្ថែមឲ្យកាន់តែច្បាស់ថែមទៀត ពីព្រោះព័ត៌មានការពាក់ព័ន្ធទៅនឹងប្រព័ន្ធនៃការដំណើរការនីតិវិធីបែបបារាំងច្រើន នៅក្នុងកិច្ចដំណើរការនីតិវិធី ដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក យើងនេះ។ សូមអញ្ជើញលោក ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនដឹងថា តើការយោងទៅលើច្បាប់បារាំងនោះ មានពាក់ព័ន្ធ

ភាពពាក់ព័ន្ធ ឬក៏អត់ទេ។ ប៉ុន្តែអ្វីច្បាស់នោះ គឺថាលោកបានយោងទៅលើវិធាន៨៧ អនុវិធាន៣ ច្បាស់លាស់ណាស់។ គឺវិធាននេះ អនុវត្តសម្រាប់សវនាការនេះ ហើយវិធាននេះ ក៏បានបញ្ជាក់ច្បាស់ថាដើម្បីសម្រេចសេចក្តីនោះ អង្គជំនុំជម្រះនឹងផ្អែកទៅលើឯកសារ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយបានជជែកដេញដោល នៅចំពោះមុខសវនាការ។

[១៥:៤៣:៣៤]

ហើយយើងត្រូវច្បាស់ផងដែរថា យើងនឹងមិនប្រើប្រាស់ៗតែទៅលើឯកសារដែលបានអាននោះទេ។ គឺមានន័យថា ឯកសារទាំងអស់ ទាំងស្រុងតែម្តងដែលត្រូវនឹងយកមកពិចារណា មិនមែនត្រឹមតែផ្នែកដែលត្រូវបានអាននោះទេ។ ហើយអានេះ ជាអ្វីដែលយើងបានបញ្ជាក់រួចមកហើយ នៅពេលដែលសាក្សីមកផ្តល់សក្ខីកម្មនោះ គឺអ្វីដែលគាត់បានផ្តល់ពីមុនមក គឺបានចាត់ថាបានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ តើមានន័យថាម៉េច? មានន័យថា ភាគីទាំងអស់ ប្រសិនបើចង់ ពួកគាត់មានឱកាសក្នុងការផ្អែកទៅលើឯកសារទាំងអស់នោះ ជាមូលដ្ឋានដើម្បីសួរសំណួរ ហើយនេះជាការជជែកដេញដោលនៅចំពោះមុខ។ ហើយលទ្ធភាពនោះ គឺបានផ្តល់ជូនទៅដល់ភាគី។ ប្រសិនបើភាគីចង់ប្រើប្រាស់ ភាគីអាចប្រើប្រាស់បាន បើមិនប្រើប្រាស់ទេ គឺស្រេចលើពួកគាត់។

អង្គជំនុំជម្រះអាចប្រើប្រាស់ឯកសារទាំងអស់នេះជាមូលដ្ឋាន សម្រាប់ការសម្រេចការពិចារណារបស់ខ្លួន។ ខ្ញុំគិតថានេះ គឺជាការផ្តល់សេចក្តីលម្អិតហើយ ហើយខ្ញុំមិនមានអ្វីបញ្ជាក់បន្ថែមទៀតទេ គឺថាសូម-- គឺថាយើងធ្វើម៉េចយោងទៅលើវិធាន៨៧ អនុវិធាន៣។

[១៥:៤៤:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីតាំងសំណួរ។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកទៀតទេ លោកបានជម្រាបហើយ ថាលោកជាការងើបឈរ ដើម្បីនិយាយចុងក្រោយ។ យើងសួរច្បាស់ណាស់។

អញ្ជើញមេធាវីបន្តការសួរ! អង្គជំនុំជម្រះនឹងពន្យារពេលឲ្យ២០នាទី ម៉ោងបួនម្ភៃនាទី។

[១៥:៤៥:២៦]

**កញ្ញា លី ម៉ាញឿន៖**

សូមអរគុណច្រើនលោកប្រធាន។

**សួរដោយកញ្ញា លី ម៉ាញៀន៖**

**ស៖** មុនពេលឈប់សម្រាក លោកសាក្សីខ្ញុំបានសួរអំពីការដែល សុន សេន គាត់ធ្វើការព្រមាន និងដាក់ទណ្ឌកម្មលោកអំពី សេ.អ៊ី.អា។ ខ្ញុំសួរកាលបច្ឆេទថ្ងៃណាដែលគាត់ធ្វើការស្តីបន្ទោសលោក នោះ? លោកបានលើកឡើងថា គាត់ស្តីបន្ទោសលោកនៅក្នុងខែធ្នូ។ ដូច្នេះខ្ញុំសូមសួរបញ្ជាក់តើក្នុង ឆ្នាំណាដែរ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណនឹងសេចក្តីសួរបញ្ជាក់នេះ។ ជម្រាបប្រសាសន៍លោកប្រធាន គឺនៅក្នុងខែ១២ ឆ្នាំ១៩៧៥ មុនខ្ញុំការ។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកមានហាក់ដូចជាការដាក់សម្ពាធពីលោក សុន សេន ទេ នៅពេលដែលគាត់សុំឱ្យយកចម្លើយសារភាព សេ.អ៊ី.អា ពីស-២១ នោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន នៅពេលនោះ ខ្ញុំយល់ថានេះ វាជាការដាក់ បញ្ជា ជាជាងការពន្យល់ឱ្យជ្រួតជ្រាប ភ្ញាក់រលឹកដោយខ្លួនឯង។

[១៥:៤៧:០៤]

**ស៖** ដូច្នេះហើយ លោកដឹងថា លោកត្រូវតែធ្វើតាមបញ្ជានោះ តើមែនដែរឬទេ?

**ឆ៖** អរគុណ។ បទបញ្ជារបស់បក្ស មិនអាចអ្នកណាប្រកែកបានទេ។ ទាហាន គឺត្រូវគោរព បទបញ្ជា។

**ស៖** តើ សុន សេន គាត់ទទួលសម្ពាធដូចលោកដែរឬទេ? តើរូបគាត់ហ្នឹងមានទទួលសម្ពាធពី ថ្នាក់លើដូចលោកទេ នៅពេលដែលគេសុំឱ្យយកចម្លើយសារភាព សេ.អ៊ី.អា ពីស-២១នោះ?

**ឆ៖** អរគុណ។ បញ្ហានេះ ខ្ញុំសូមមិនឆ្លើយទេ។ បើសិនជាខ្ញុំឆ្លើយ វាចូលទៅក្នុងសេចក្តីសន្និដ្ឋាន ហើយ។

[១៥:៤៨:១៣]

**ស៖** តើ នួន ជា ធ្លាប់បង្គាប់បញ្ជា ឬក៏ដាក់សម្ពាធលើលោក ដើម្បីឱ្យលោកទាញយកចម្លើយ សារភាពពីខ្មាំង អ្នកទោសនៅស-២១ ដែលចាត់ទុកជា សេ.អ៊ី.អា នោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ដោយឡែកក្នុងពេលដែល សុន សេន និយាយ ពីរឿងថាម៉េចក៏ស-២១ សេ.អ៊ី.អា មិនឃើញ? អាហ្នឹងវាមានលក្ខណៈមួយ គឺថាគេចាប់បង្ខំ ឬក៏ជា

ភារកិច្ចដែលដាក់មក។ ក្រោយពីអនុវត្តមួយលើក ពីរលើក វាទៅជាទម្លាប់ទៅហើយ។ ដូច្នេះពេលដែល នួន ជា គាត់ចូលមកគ្រប់គ្រងស-២១នេះ ស-២១ស្ថិតនៅក្នុងបរិយាកាសមួយដែលមាគ៌ាបក្សកំណត់ ខ្មាំងសត្រូវរបស់បដិវត្តន៍គឺ សេ.អ៊ី.អា, កា.ហ្សេ.បេ និងភ្នាក់ងារយួនលេបទឹកដី។ ទាំងអស់គ្នាត្រូវតែ ឯកភាពគ្នា អនុវត្តមាគ៌ានេះរបស់បក្ស គោលការណ៍នេះរបស់បក្ស។

**ស៖** តើហេតុអ្វីមានភាពចាំបាច់ទាញយកចម្លើយសារភាព សេ.អ៊ី.អា ពីស-២១ នោះ?

[១៥:៥០:០៣]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ភារកិច្ចរបស់ស-២១ គេហៅថា ជាអង្គភាព មួយអនុវត្តភារកិច្ចប្រតិចារកម្ម *"កុងត្រេះស្ប្យណាល់"* ។ ដូច្នេះ នុំងហើយដែលគេនាំយើងខ្ញុំទៅឲ្យរក សេ.អ៊ី.អា ទៅឲ្យរក កា.ហ្សេ.បេ ទៅឲ្យរកភ្នាក់ងារយួនលេបទឹកដី។

**កញ្ញា លី ម៉ាញៀន៖**

លោកប្រធាននៅពេលនេះ ខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារមួយទៀតដល់សាក្សី គឺឯកសារលេខ D57 ERN 00008876 ឯកសារនេះមានតែជាភាសាខ្មែរតែប៉ុណ្ណោះ។ ទីបី ជាមានការសរសេរ អង់គ្លេសមួយចំនួនលើកឯកសារខ្មែរនោះក៏ដោយ។ សូមអនុញ្ញាតបញ្ចាំងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! បគ្គលិកជំនួយការបញ្ចាំងឯកសារនៅលើអេក្រង់ទូរទស្សន៍! ហើយ មន្ត្រីច្បាប់ទទួលយកឯកសារពីមេធាវីជូនសាក្សីពិនិត្យ!

[១៥:៥១:៥២]

**កញ្ញា លី ម៉ាញៀន៖**

លោកប្រធាន ខ្ញុំសូមបញ្ជាក់ថា ឯកសារនេះក៏បានលេខ D108/26.272។

**សួរដោយកញ្ញា លី ម៉ាញៀន៖**

**ស៖** លោកសាក្សីតើលោកធ្លាប់ឃើញឯកសារនេះពីមុនមកដែរឬទេ? ហើយលោកស្គាល់ ឯកសារនេះដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះបានបង្ហាញឲ្យយើងខ្ញុំឃើញ-- ឲ្យខ្ញុំបាទឃើញនៅពេលសវនាការសំណុំរឿងលេខ ០០១ ក៏ប៉ុន្តែឯកសារនេះបើបើកទៅក្នុងទៀត បាន

ឃើញថា អ្នកណាសួរ? ហើយជាអក្សររបស់អ្នកណា? កម្មាភិបាលខ្ញុំសួរមិនដឹងជានរណាទេ ឬមិត្តប៉ុន ឬបង ម៉ម ណៃ។ ដូច្នេះបើបើកទៅខាងក្នុងទៀតបានច្បាស់។

[១៥:៥២:៥៥]

**ស៖** ខ្ញុំសូមឱ្យលោកកំណត់អត្តសញ្ញាណឯកសារជាមុនសិន បន្ទាប់មកយើងនឹងមើលខ្លឹមសារលម្អិត។ សូមបើកទៅទំព័រដែលមានតារាងកាលវិភាគ។ សូមឱ្យលោកមើលឯកសារជាតារាងនេះនៅខាងលើ តើឈ្មោះចំណងជើងឯកសារនេះឈ្មោះអ្វីដែរ នៅក្នុង*កូឡោន*ខាងលើ?

**ឆ៖** អរគុណ។ នៅកូឡោនខាងលើចំណងជើងថាវា "ឈ្មោះអ្នកទោសចូលថ្ងៃទី២៦ ខែវិច្ឆិកា ១៩៧៨"។

**ស៖** តើមានចំណុចកំណត់សម្គាល់ណាមួយនៅក្នុងតារាងនេះដែរឬទេ? មានសរសេរឈ្មោះ អាយុ ភេទ ហើយនិងមកពីកន្លែងណាដែរឬទេ តើមានសរសេរដូច្នេះដែរឬទេ?

**ឆ៖** អរគុណ។ នៅក្នុងឯកសារនេះមានសរសេរ អាយុ២៩ឆ្នាំ ទាំងពីរនាក់ ភេទប្រុស ហើយមជ្ឈដ្ឋានដែលបញ្ជូនមកគឺកំពង់សោម។ ហើយជនរងគ្រោះទាំងពីរនាក់ដែលត្រូវចាប់បានយកមកសួរចម្លើយនេះ ដែលគេចាត់ទុកថាជា ចារបុរសរបស់បរទេស បស្ចិមប្រទេសនេះមកពីហាវ៉ៃ។

[១៥:៥៥:០៤]

**ស៖** លោកសាក្សី លោកកំពុងតែនិយាយអំពីឈ្មោះពីរនាក់ ដែលមាននៅក្នុងឯកសារនេះ។ តើលោកអាចអានឈ្មោះពីរនាក់ដំបូង ដែលមាននៅក្នុងឯកសារនេះ បានដែរឬទេ?

**ឆ៖** មួយឈ្មោះ គ្រីស្តូហ្វែរ អេដវ៍ ឌីឡង់។ មួយទៀតឈ្មោះ ម៉ៃខល ស្កុតគីម៉ូ។

**ស៖** ដើម្បីជាកំណត់ហេតុយើង ឈ្មោះនេះគឺឈ្មោះ ម៉ៃខល ស្កុតឌីត តើលោកធ្លាប់បានឃើញចាំថាធ្លាប់បានឃើញអ្នកទោសពីរនាក់នេះនៅស-២១ បានដែរឬទេ?

[១៥:៥៦:១១]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ដែលខ្ញុំបានចូលទៅជួបតែម្នាក់ទេ អង់គ្លេស មិនដឹងឈ្មោះស្អីទេ ភ្លេចទៅ ឯចំណែកអ្នកពីរនាក់ផ្សេងទៀត-- អ្នកបីផ្សេងទៀត ខ្ញុំគ្រាន់តែដឹងថា គេបានចូលទៅ។

**ស៖** តើលោកធ្លាប់ឃើញចម្លើយសារភាពរបស់ គ្រីស្តូហ្វែរ អេដវ៍ ឌីឡង់ ហើយនិង ម៉ៃខល ស្កុតឌីត ក្នុងពេលដែលលោកកាន់ការនៅស-២១ ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន អត់មានការបកប្រែជាខ្មែរទេ។

**ស៖** តើលោក-- លោកសាក្សី ខ្ញុំនឹងសួរម្តងទៀត។ តើលោកឮហើយឬនៅ? សំណួរ លោកសាក្សី ខ្ញុំចង់សួរថា តើលោកធ្លាប់ឃើញចម្លើយសារភាពរបស់ គ្រីស្តូហ្វែរ អេដវ៉ ឌីឡង់ និងចម្លើយសារភាព ម៉ៃខល ស្កុតឌីត ក្នុងពេលលោកកាន់ការនៅស-២១ ដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ចម្លើយរបស់ជនទាំងបួននាក់នេះ ខ្ញុំឃើញទាំងអស់ ហើយឥឡូវនេះ បើសិនជាចង់សួរបញ្ជាក់ខ្ញុំ ហុចចម្លើយណាមួយមកក៏បានដែរ។

[១៥:៥៨:១៦]

**កញ្ញា លី ម៉ាញឿន៖**

លោក លោកស្រីចៅក្រម ខ្ញុំនឹងជូននូវច្បាប់ចម្លងនៃចម្លើយសារភាពរបស់ ម៉ៃខល ស្កុតឌីត ទៅលោកសាក្សី ជាឯកសារដ៏វែង ហើយខ្ញុំគិតថា អាចនឹងជួយឲ្យសាក្សីលោកនឹកឃើញនូវខ្លឹមសារឡើងវិញមួយចំនួនដែរ។ ERN នៃឯកសារនេះគឺ 000211734 ERN របស់ភាសាខ្មែរ នៃឯកសារនេះ ឯកសារ D22/21/3 ហើយអត្ថបទអង់គ្លេសនេះគឺ ERN00335569 ភាសាបារាំង ERN00323822។

តុលាការ សូមខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារជូនទៅលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

គោលបំណងនៃការសួរពាក់ព័ន្ធនឹងឯកសារកំណត់ហេតុនេះ យ៉ាងម៉េចទៅលោកស្រីមេធាវី?

**កញ្ញា លី ម៉ាញឿន៖**

លោកចៅក្រម យើងបានស្តាប់សាក្សីអំពីមាគ៌ាបក្ស ទាក់ទងទៅនឹងភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារយួន ហើយ កា.ហ្សេ.បេ។ ឯកសារនេះសំខាន់ណាស់លោកប្រធាន គឺថាជាឯកសារដ៏វែង ហើយមាននូវសេចក្តីលម្អិតដ៏ច្រើន អំពីប្រតិបត្តិការ សេ.អ៊ី.អា ការបណ្តុះបណ្តាល ហើយនិងឧបករណ៍ទំនាក់ទំនង ហើយឧបករណ៍បច្ចេកទេស បេសកកម្ម ហើយនិងគោលបំណង ព្រមទាំងការស៊ើបការណ៍របស់តំបន់ដែលបក្សកុម្មុយនីស្តកម្ពុជាបង្ក្រាបតាមគោលនយោបាយទៅលើក្រុមទាំងអស់នោះ។ ហើយខ្ញុំចង់បង្ហាញសាក្សីនេះ ដើម្បីឲ្យគាត់ពន្យល់ ឬក៏បញ្ជាក់ពីមតិ ថាតើមានហេតុការណ៍អី ឬក៏ដោយវិធីណា ដែលជនរងគ្រោះអាចនឹងសារភាពអំពីហេតុការណ៍ទាំងអស់នេះ? ឬក៏ចង់ដឹងអំពីដំណើរការ ឬកិច្ចប្រឹងប្រែងរបស់កម្ពុជាប្រជាធិបតេយ្យ ដើម្បីទាញយកនូវព័ត៌មានដ៏លម្អិតបែបនេះពីជនរងគ្រោះនោះ?

[១៦:០១:១៩]

ចម្លើយសារភាពនេះ លោកប្រធាន លោក លោស្រីចៅក្រម ហើយយើងខ្ញុំមិនប្រើដើម្បីបង្ហាញអំពីខ្លឹម-- បង្ហាញភស្តុតាងអំពីខ្លឹមសារនោះទេ។ ខ្លឹមសារនេះគឺមិន យើងខ្ញុំមិនពឹងផ្អែកលើខ្លឹមសារនោះទេ ឯកសារទាំងអស់នេះគឺត្រូវបានទទួលបានក្រោមអំពើទារុណកម្ម ហើយខ្ញុំគិតថា គឺមានយុត្តិសាស្ត្រដ៏សមស្របមួយ ដែលថាចម្លើយសារភាពដែលទទួលបានដោយអំពើទារុណកម្ម គឺមិនអាចយកមកជាបង្អែកបានទេ។

ព័ត៌មានដែលកើតចេញមកពីអំពើទារុណកម្មនោះ គឺត្រូវស្ថិតនៅក្នុងរយៈពេលនៃអំពើទារុណកម្ម និងក្នុងចម្លើយសារភាព ហើយនិងគំនិតនយោបាយ ដែលបញ្ជាក់នៅក្នុងព័ត៌មាន ហើយវាឆ្លុះបញ្ចាំងអំពីព័ត៌មានឃោសនា ជាពិសេសព័ត៌មានដែលប្រមូលបានអំពីជនរងគ្រោះទាំងនោះឯង។

[១៦:០២:១៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៤:០៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបដិសេធ មិនអនុញ្ញាតឲ្យមេធាវីដាក់ឯកសារនេះដេញដោលទេ។ មេធាវីអាចបន្តនូវសំណួរផ្សេងទៀត។

សូមអញ្ជើញ!

[១៦:០៤:៣៦]

**កញ្ញា លី ម៉ាញឿន៖**

លោកប្រធាន លោក លោកស្រីចៅក្រម បើសិនជំទាស់ខ្ញុំនៅនេះ ខ្ញុំមិនអាចទៅមុខបានទេ។ បើសិនជាអង្គជំនុំជម្រះបានសម្រេចរួចហើយថា នៅក្នុងរឿងក្តី០០១-- សូមអភ័យទោសគឺសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងរឿងក្តី០០២ ហើយនៅក្នុងទាក់ទងទៅនឹងអង្គបុរេជំនុំជម្រះ ឯកសារ D130/8 ហើយជាដីកាសម្រេចអំពីការប្រើសេចក្តីប្រកាស ឬក៏កំណត់ដែលទទួលបានមកពីទារុណកម្មក្នុងឆ្នាំ២០០១ នោះគឺថា កថាខណ្ឌទី២៧ នៅក្នុងឯកសារនោះនិយាយថា ទាក់ទងទៅភាពអាចទុកចិត្តបាននៃឯកសារដែលទទួលបានពីការធ្វើទារុណកម្មនោះ គឺមិនផ្អែកលើព័ត៌មានហ្នឹងមិនត្រូវយកព័ត៌មានមកប្រើដោយមិនបញ្ជាក់ពីភាពនៃព័ត៌មាន ប៉ុន្តែបក្សកុម្មុយនីស្តកម្ពុជាបានពឹងផ្អែក

ទៅលើព័ត៌មាននេះ ដើម្បីបន្តអនុវត្តនៅលើបទឧក្រិដ្ឋ ដែលបទឧក្រិដ្ឋទាំងអស់នោះស្ថិតនៅយុត្តាធិការរបស់ អ.វ.ត.ក។ ហើយក៏បន្តទៅទៀតនិយាយថា ជាឧទាហរណ៍ចម្លើយសារភាពអាចនឹងមានបញ្ជីមនុស្សមួយចំនួនដែលថា អ្នករងគ្រោះទទួលទារុណកម្ម ហើយឆ្លើយដាក់ជនក្បត់។ ហើយបញ្ជីទាំងអស់ហ្នឹងគឺក្រោយមកត្រូវគេចាប់ទៅតាមបញ្ជីហ្នឹង ហើយអាចបង្ហាញភស្តុតាងថា ជនជាប់ចោទបានប្រើបញ្ជីទាំងអស់នេះ ដើម្បីធ្វើការចាប់ខ្លួន និងសម្លាប់ខ្លួនអ្នកទាំងអស់នោះ។ ហើយព័ត៌មានដែលនៅក្នុងចម្លើយសារភាពហ្នឹងក៏មិនបានបញ្ជាក់ពីការពិតនៃខ្លឹមសារហ្នឹងទេ ក៏ប៉ុន្តែ-- ហើយគឺគ្រាន់តែបង្ហាញថាគេប្រើដើម្បីប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងនឹងជនដែលមានឈ្មោះនៅក្នុងចម្លើយសារភាពតែប៉ុណ្ណោះ។

[១៦:០៦:២៨]

នៅក្នុងករណីនេះ ចម្លើយសារភាពនោះគឺយើងខ្ញុំមិនប្រើបង្ហាញថា ព័ត៌មានទាំងអស់នោះជាការពិតទេ ក៏ប៉ុន្តែដើម-- បើសិនជាអង្គជំនុំជម្រះមិនឲ្យខ្ញុំប្រើ ខ្ញុំមិនអាចបន្តទៅបានទេ ប៉ុន្តែខ្ញុំនឹងសួរសាក្សីអំពីការចងចាំរបស់គាត់វិញ។

[១៦:០៧:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៩:០១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកស្រីបន្តសំណួរ។

សូមអញ្ជើញ!

[១៦:០៩:១២]

**កញ្ញា លី ម៉ាញៀន៖**

លោក លោកស្រីចៅក្រម ដើម្បីឲ្យច្បាស់ ឲ្យខ្ញុំបន្តសួរសាក្សីតាមការចងចាំរបស់គាត់ ឬក៏ប្រើឯកសារ? ខ្ញុំយល់បាន។

**សួរដោយកញ្ញា លី ម៉ាញៀន៖**

**ស៖** លោកសាក្សី--

**ប្រធានអង្គជំនុំ៖**

ការផ្អែកលើឯកសារ អង្គជំនុំជម្រះបានបដិសេធរួចហើយ។ អ៊ីចឹង សំណួរចុងក្រោយអំមិញ

គឺតាមការចងចាំរបស់សាក្សី ដែលនាំឲ្យអង្គជំនុំជម្រះក៏ពិភាក្សាបន្ថែមលើបញ្ហានេះ ហើយបញ្ហានេះអង្គជំនុំជម្រះយល់ថា អនុញ្ញាតឲ្យសួរ។ អង្គជំនុំជម្រះនឹងស្ដាប់ តាមដានស្ដាប់នូវសំណួររបស់លោកស្រីចំពោះសាក្សីថា តើសំណួរហ្នឹងវាពាក់ព័ន្ធ ឬមិនពាក់ព័ន្ធ។ អង្គជំនុំជម្រះនឹងសម្រេចអំពីបញ្ហានោះជាបន្តទៀត ទាំងឆន្ទានុសិទ្ធិ ទាំងការជំទាស់ពីភាគីម្ខាងទៀត។

**កញ្ញា លី ម៉ាញឿន៖**

សូមអរគុណ លោកប្រធាន លោក លោកស្រីចៅក្រម។

**សួរដោយកញ្ញា លី ម៉ាញឿន៖**

**ស៖** លោកសាក្សីបានបញ្ជាក់ខាងដើមនេះ លោកចងចាំអំពីចម្លើយសារភាពរបស់ជនបរទេសដែលត្រូវបានឃុំខ្លួននៅស-២១ បើនិយាយជាទូទៅ តើចម្លើយសារភាពហ្នឹងប្រវែងប៉ុន្មាន? ឬក៏រយៈពេលប៉ុន្មាន? គឺមានប៉ុន្មានទំព័រ? ជាឧទាហរណ៍លោកចាំទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ខ្ញុំមិនចាំទេ ប៉ុន្តែវែង។

**ស៖** តើចម្លើយសារភាពនេះបញ្ជូន-- ផ្ដល់មកដល់លោកជាភាសាអង់គ្លេស ឬក៏ជាភាសាខ្មែរ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ចម្លើយសារភាពនេះមកទាំងពីរ ទាំងអង់គ្លេស ទាំងខ្មែរ។

**ស៖** តើអ្នកទោស គឺជាពួកបស្ចិមប្រទេស ជាអ្នកទោសនោះ គេសរសេរជាភាសាកំណើតរបស់គេជាអង់គ្លេសឬ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន អ្នកទោសដែលជាអ្នកនិយាយភាសាអង់គ្លេសហ្នឹង គេសរសេរសេចក្ដីសារភាពរបស់គេជាភាសាអង់គ្លេស។

[១៦:១១:៥៥]

**ស៖** ហើយបន្ទាប់មក គេបានបកប្រែហ្នឹងទៅជាអង់គ្លេស ឬក៏បកប្រែក្នុងពេលជាមួយគ្នានៅពេលដែលបានទទួលចម្លើយសារភាពភ្លាមបកប្រែភ្លាម អ៊ីចឹងឬដូចម្ដេច?

**ឆ៖** អរគុណ។ ជម្រាបប្រសសន៍លោកប្រធាន ក្នុងការសួរចម្លើយជនបស្ចិមប្រទេសទាំងបួនរូបនេះ ខ្ញុំបានគេឲ្យគេជ្រើសរើសអ្នកទោសជាខ្មែរ ដែលចេះអង់គ្លេសស្ទាត់ជំនាញម្នាក់ឲ្យទៅជួយការងារនៅទុំង បកប្រែមួយម៉ាត់ទៅម៉ាត់ មួយឃ្លាទៅមួយឃ្លា តាំងពីសួរមកម្ល៉េះ។

**ស៖** ដូច្នេះការសួរចម្លើយ ហើយនិងការបកប្រែនូវចម្លើយសារភាពនោះ ហើយត្រូវបានធ្វើដោយមនុស្សពីរនាក់មែនទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន អ្នកបកប្រែម្នាក់ ហើយកម្មាភិបាលសួរចម្លើយម្នាក់។

**ស៖** តើលោកយល់ស្របដែរឬទេ ក្រោយពីបានអានចម្លើយសារភាពទាំងអស់នោះ ព័ត៌មាននៅក្នុងចម្លើយសារភាពនោះ គឺថាស្របទៅតាមសាររបស់បក្សកុម្មុយនីស្តកម្ពុជា ដែលគេចង់បញ្ជូនទៅឲ្យសមាជិករបស់ខ្លួនអនុវត្តដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនយល់សំណួរនេះទេ សូមមេធាវីសួរបែបថ្មី ដើម្បីឲ្យស្រួលយល់ ស្រួលឆ្លើយ។

**ស៖** លោកសាក្សី ពេលដែលលោកអានចម្លើយសារភាពទាំងអស់នោះ ហើយលោកយល់ខ្លឹមសារទាំងអស់នោះ តើត្រូវដែរឬទេ?

[១៦:១៤:00]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់ប៉ានបដិសេធទាំងស្រុង ហើយខ្ញុំក៏មិនទទួលស្គាល់ថាត្រូវទាំងស្រុងដែរ ពីព្រោះរឿង វាដាច់ដោយឡែកពីគ្នា។ សេចក្តីសារភាពនេះ វាជាអត្ថបទថ្មី សភាពការណ៍ថ្មីមួយសម្រាប់ខ្ញុំ។

**ស៖** លោកសាក្សី សូមលោកបំភ្លឺជូនតុលាការ ដែលលោកយល់ថាមិនបដិសេធ ហើយមិនទទួលទាំងអស់នោះ គឺតើលោកចង់ពន្យល់យ៉ាងដូចម្តេចក្នុងពាក្យនេះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ ធម្មតាទេ ស្អីដែលថ្មី ស្អីដែលចម្លែក ខ្ញុំមិនដែលប៉ានបដិសេធទាំងស្រុងភ្លាមទេ។ ខ្ញុំចងចាំទុក ហើយក៏មិនទទួលស្គាល់ថាវាត្រឹមត្រូវតាមការពិតទាំងស្រុងដែរ គ្រាន់តែចងចាំទុកក្នុងអារម្មណ៍មួយប៉ុណ្ណោះ។

**ស៖** នៅក្នុងពេលដែលសំណួរចម្លើយ តើមានគោលការណ៍ណែនាំទៅដល់អ្នកសួរ ដើម្បីថាចង់បានព័ត៌មានអ្វីពីជនរងគ្រោះនោះដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន គោលការណ៍ណែនាំ ហើយនិងសំណូមពរចង់បាននេះ វាៗអនុវត្តមកហូរហែ គេក៏យល់ចិត្តថ្លើមខាងលើរបស់អង្គការរួចអស់ទៅហើយ។ ខ្ញុំក្នុងឋានៈជាប្រធានស-២១ ខ្ញុំគ្រាន់តែចង់ដឹងថា តើអ្នកបកប្រែហ្នឹង ចេះអង់គ្លេសច្បាស់លាស់ទេ។ ខ្ញុំទៅ ខ្ញុំ

ឃើញអ្នកបកប្រែ ខ្ញុំបាននិយាយពីរបីម៉ាត់ជាមួយនឹងគ្នា។ ហើយខ្ញុំទទួលស្គាល់ថា គេពិតជាមានសមត្ថភាពភាសាអង់គ្លេសមែន។ ដូច្នេះ ខ្ញុំបានតែប៉ុណ្ណឹងឯង ឯចំណែកកិច្ចដំណើរការសួរស្ទី១ គេធ្លាប់រួចហើយ។ ខ្ញុំអត់បានគិតគូរអីបន្ថែមទៀតទេ។ នេះ សូមបញ្ជាក់ប៉ុណ្ណោះ។

**ស៖** លោកសាក្សី អ្វីដែលខ្ញុំចង់ដឹងនោះ តើអ្នកសួរចម្លើយ សួរអ្វីទៅជនរងគ្រោះដើម្បីទាញយកចម្លើយសារភាព ដើម្បីធ្វើម៉េចឲ្យបញ្ជាក់ថាគេសារភាពថា គេជាភ្នាក់ងារ សេ.អ៊ី.អា នោះ?

[១៦:១៧:១២]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ ដោយឡែកករណីចំពោះ-- ជាចំពោះមួយនេះ ខ្ញុំឆ្លើយមិនរួចទេ ខ្ញុំគ្រាន់តែជម្រាបថា មនុស្សដែលខ្ញុំប្រគល់ឲ្យសួរចម្លើយជនបស្ចិមប្រទេសទាំងបួនរូបនេះ គឺជាមនុស្សដែលខ្ញុំធ្លាប់បណ្តុះបណ្តាលទាំងពីនៅ ម-១៣ ជាមួយគ្នា តាំងពីឆ្នាំ១៩៧១។ តាំងពីរបៀបសួរ របៀបពិចារណា ហើយទៅសួរឡើងវិញ ដកថយខ្លួនមកគិតពិចារណាសិន ទាំងអស់។

**ស៖** តើខ្លឹមសារនៃឯកសារទាំងអស់នោះ ដូចជាទង់បដិវត្តនោះ អ្នកសួរចម្លើយយកទៅប្រើដើម្បីសួរចម្លើយទៅជនរងគ្រោះដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឯកសារទង់បដិវត្ត និយាយអំពីខ្មាំងសត្រូវរបស់ជាតិ មាន សេ.អ៊ី.អា, កា.ហ្សេ.បេ, ភ្នាក់ងារយួនលេបទឹកដី។ អ្នកណាក៏បំពាក់ឲ្យជ្រួតជ្រាបក្នុងសតិអារម្មណ៍ឲ្យក្លាយទៅជាគោលជំហរដែលត្រូវតែធ្វើរួចអស់ទៅហើយ។ គេមិនយកទៅពន្យល់អ្នកទោសអីទេ។ គេសួរ គេមានល្បិចគេសួរទៅផ្សេង។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសមល្មមនឹងសម្រាកហើយ សម្រាប់កិច្ចដំណើរសវនាការរសៀលនេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកទី៣ ខែមេសា ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំសាក្សីទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនឹងឲ្យនាំគាត់មកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែក ត្រឹមម៉ោងប្រាំបួន។ ហើយដូចគ្នាបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ។ ហើយនឹងឲ្យនាំខ្លួនគាត់មកបន្ទាប់សវនាការនេះនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:២០ នាទី)*